សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

## បត្យាប័ន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ហាក់ ស្រីនីត**

ណែនាំដោយ

លោកគ្រូ **ហោ សុភ័ណ្ឌា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# **សេចក្ដីថ្លែងអំណរគុណ**

នាងខ្ញុំឈ្មោះ **ហាក់ ស្រីនីត** ជានិសិត្សថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០២០ដល់២០២៤។ នាងខ្ញុំបានសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយជ្រើសរើសប្រធានបទបត្យាប័ន។

## **សូមថ្លែងអំណរគុណនិងអរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

ជាដំបូងនាងខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះលោកឪពុកឈ្មោះ **គិត ហាក់** និងអ្នកម្ដាយឈ្មោះ **ហេង ស៊ាន់** ដែលបានផ្ដល់កំណើត និងខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការចិញ្ចឹមបីបាច់ថែរក្សានិងបង្ហាត់បង្រៀនកូនតាំងពីតូចឱ្យកូនចេះគោរពចាស់ទុំនិងបានបញ្ជូនកូនចូលរៀនតាំងពីបឋមសិក្សារហូតមកដល់មហាវិទ្យាល័យដោយជួយទំនុកបម្រុងលើការសិក្សារបស់កូន លោកទាំងពីរតែងតែនៅក្បែរនិងលើកទឹកចិត្តកូនៗជានិច្ច។

នាងខ្ញុំសូមថ្លែងអំណរគុណ **ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំង សាកលវិទ្យាធិការរង គណៈគ្រប់គ្រង និងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានលះបង់កម្លាំងកាយចិត្តនិងពេលវេលាដ៏មានតម្លៃដើម្បីរកវិធីសាស្ត្រក្នុងការបង្ហាត់បង្រៀនទៅដល់យុវជនក្នុងគោលបំណងបណ្តុះបណ្តាលធនធានមនុស្សឱ្យក្លាយជាសសរទ្រូងសម្រាប់ប្រទេសជាតិទាំងមូល។

ជាពិសេសនាងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកគ្រូ **ហោ សុផ័ណ្ណា** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាដោយគាត់បានចំណាយពេលវេលាដ៏មានតម្លៃមកណែនាំនិងបង្ហាត់បង្រៀននាងខ្ញុំកន្លងមក យ៉ាងយកចិត្តទុកដាក់ជាទីបំផុត។

ជាទីបញ្ចប់នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅដល់ លោកឪពុកអ្នកម្ដាយ បងប្រុសបងស្រី សាកលវិទ្យាធិការ គណៈកម្មការ សាស្ត្រាចារ្យណែនាំ និងលោកគ្រូអ្នកគ្រូទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឱ្យជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីនាងខ្ញុំបានឆ្លងកាត់នូវការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្នុងរយៈពេល៤ឆ្នាំ នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច នាងខ្ញុំទទួលបាននូវចំណេះដឹងពីសំណាក់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យ ដែលបានខិតខំបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ ដើម្បីឱ្យនិស្សិតទទួលបាននូវចំណេះដឹងដែលគាត់បានផ្ទេរមកឱ្យតាមរយៈការខិតខំស្វែងរកគន្លឹះឬបច្ចេកទេសក្នុងការបង្រៀនទៅដល់សិស្ស ដើម្បីឱ្យសិស្សឆាប់ចាប់មេរៀនបាន អាចបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យនិងទទួលបាននូវចំណេះជំនាញពិតប្រាកដ។

នាងខ្ញុំបានសម្រេចជ្រើសរើសប្រធានបទ"បត្យាប័ន" មកសរសេរសារណាដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ដោយសារតែនាងខ្ញុំចង់ស្វែងយល់ពីនីតិវិធីក្នុងការបញ្ជូនបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តនូវបទល្មើសហើយរត់គេច ទៅជ្រកកោននៅរដ្ឋមួយផ្សេងទៀត។ម្យ៉ាងទៀតសព្វថ្ងៃនេះ ការប្រព្រឹត្តបទល្មើសមានការកើនឡើង ហើយជនល្មើសតែងតែរត់ទៅកាន់ប្រទេសមួយទៀត ដើម្បីគេចពីការទទួលទោស ដែលជាមូលហេតុធ្វើឱ្យមានការបង្កើតសន្ធិសញ្ញាបត្យាប័ន ដើម្បីឱ្យរដ្ឋទាំងនេះសហការគ្នាក្នុងចាប់បញ្ជូនជនល្មើសមកកាន់រដ្ឋដាក់សំណើវិញ។

គោលបំណងនៃសារណានេះធ្វើឡើង ដើម្បីសិក្សាឱ្យបានស៊ីជម្រៅអំពីលក្ខខណ្ឌដែលអនុញ្ញាតឱ្យមានការធ្វើបត្យាប័ន និងនីតិវិធីនៃការធ្វើបត្យាប័ន និងស្ថាប័នណាដែលមានសមត្ថកិច្ចក្នុងការធ្វើបត្យាប័ន។

នាងខ្ញុំជឿជាក់ថាខ្លឹមសារនៃកិច្ចការមួយនេះ មិនទាន់ល្អនោះទេ ដោយសារតែមានផលលំបាកក្នុងស្វែងរកឯកសារដែលពាក់ព័ន្ធក្នុងការធ្វើបត្យាប័ន ប៉ុន្តែយ៉ាងណាក៏នាងខ្ញុំបានខិតខំធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ ឱ្យអស់ពីសមត្ថភាពរបស់នាងខ្ញុំ ដែលជាសមទ្ធិផលមួយដ៏សំខាន់ក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រដែលនាងខ្ញុំបានសិក្សាអស់រយៈពេល៤ឆ្នាំ ។

ជាចុងបញ្ចប់នាងខ្ញុំសូមខន្តីអភ័យទោសទុកជាមុន ពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ នូវរាល់កំហុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនា ចំពោះខ្លឹមសារនិងអក្ខរាវិរុទ្ធនៅក្នុងកិច្ចការមួយនេះ នាងខ្ញុំរង់ចាំទទួលការរិះគន់ក្នុងន័យស្ថាបនាទៅលើប្រធានបទមួយនេះ ដើម្បីកែប្រែកិច្ចការ មួយនេះឱ្យមានភាពល្អឡើង។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........................................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃបត្យាប័ន**

**ផ្នែកទី១ អត្ថន័យនិងក្របខណ្ឌពិសេសក្នុងការធ្វើបត្យាប័ន** .................... ៥

១.១.និយមន័យ .................................................... ៥

១.២.ក្របខណ្ឌពិសេសក្នុងការធ្វើបត្យាប័ន ................................ ៦

១.៣.ក្របខណ្ឌច្បាប់ផ្សេងៗ ............................................. ៦

**ផ្នែកទី២ កាតព្វកិច្ចនិងគោលការណ៍ណែនាំអន្តរជាតិស្តីពីបត្យាប័ននិងការធ្វើបត្យាប័ននៅកម្ពុជា** .................................................... ៧

២.១.កាតព្វកិច្ចនិងគោលការណ៍ណែនាំអន្តរជាតិស្តីពីការធ្វើបត្យាប័ន .............. ៧

២.២.ការធ្វើបត្យាប័ននៅក្នុងប្រទេសកម្ពុជា ................................ ៨

២.៣.បញ្ហានៃការធ្វើបត្យាប័ននៅប្រទេសកម្ពុជា .............................. ៨

**ជំពូកទី២**

**លក្ខខណ្ឌក្នុងការធ្វើបត្យាប័ន**

**ផ្នែកទី១ ការធ្វើបត្យាប័នផ្អែកតាមសន្ធិសញ្ញា** ................................ ១១

១.១.ការបង្កើតសន្ធិសញ្ញាស្តីពីបត្យាប័ន .................................. ១១

១.២.ករណីមានចែងក្នុងអនុសញ្ញា .......................................... ១៥

**ផ្នែកទី២ ការធ្វើបត្យាប័នផ្អែកតាមច្បាប់ ឬករណីមិនមានសន្ធិសញ្ញា** .............. ១៨

២.១.ករណីមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ពិសេស ............................ ១៨

២.២.ការអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ................................. ២០

**ជំពូកទី៣**

**នីតិវិធីក្នុងការធ្វើបត្យាប័ន**

**ផ្នែកទី១ នីតិវិធីនៃការដាក់សំណើរបស់ព្រះរាជាណាចក្រកម្ពុជា** ................. ២៨

១.១.ការដាក់ពាក្យសុំធ្វើបត្យាប័ន ........................................ ២៩

១.២.ការដាក់ពាក្យសុំចាប់ខ្លួនបណ្តោះអាសន្ន ................................ ៣១

១.៣.ការចូលទៅបង្ហាញខ្លួននៅដំណាក់កាលសភាស៊ើបសួរ ........................ ៣៣

១.៤.ការអនុវត្តក្នុងអំឡុងពេលផ្តល់បត្យាប័ន ..................................................................... ៣៣

**ផ្នែកទី២ នីតិវិធីនៃការទទួលសំណើរបស់ព្រះរាជាណាចក្រកម្ពុជា** ........................ ៣៥

២.១.ការទទួលពាក្យសុំធ្វើបត្យាប័នតាមរយៈក្រសួងការបរទេស ........................................ ៣៦

២.២.ការទទួលពាក្យស្នើសុំចាប់បុគ្គលដែលគេទាមទារ ................................................. ៣៧

២.៣.នីតិវិធីនៅដំណាក់កាលសភាស៊ើបសួរ .................................................................. ៣៨

២.៤.សេចក្តីសម្រេចពីបត្យាប័ន ................................................................................ ៣៩

**សេចក្តីសន្និដ្ឋាន** ............................................................................................... ៤២

**អនុសាសន៍** ....................................................................................................... ៤៤

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

បត្យាប័ន សំដៅដល់នីតិវិធីក្នុងការប្រគល់ឬបញ្ជូនជនល្មើសពីប្រទេសមួយទៅកាន់ប្រទេសមួយទៀត ដែលអាចហៅបានថារដ្ឋមួយជារដ្ឋដាក់សំណើ ហើយរដ្ឋមួយទៀតជារដ្ឋទទួលសំណើ។ បត្យាប័ន ជានីតិវិធីនៃការស្នើសុំជនល្មើសដែលកំពុងស្នាក់នៅលើដែនដីនៃរដ្ឋទទួលសំណើ ដោយឱ្យរដ្ឋទទួលសំណើបញ្ជូនជនល្មើសមកឱ្យអាជ្ញាធរនៃរដ្ឋផ្ញើសំណើ ដើម្បីធ្វើការចោទប្រកាន់ ឬជំនុំជម្រះ និងផ្តន្ទាទោសតាមផ្លូវច្បាប់នៃរដ្ឋផ្ញើសំណើ។

គោលបំណងនៃការបង្កើតបត្យាប័នគឺជាការនាំជនល្មើសដែលបានរត់ទៅស្នាក់នៅលើដែនដីនៃរដ្ឋមួយទៀត មកធ្វើការចោទប្រកាន់ និងជំនុំជម្រះចំពោះមុខយុត្តាធិការនៅក្នុងប្រទេសផ្ញើសំណើ។ បច្ចុប្បន្ននៅតាមបណ្តាប្រទេសមានការរីកចម្រើនផ្នែកបច្ចេកវិជ្ជានិងកាន់តែទំនើបជាងមុនដែលធ្វើឱ្យជនល្មើសងាយស្រួលរត់គេចពីការទទួលខុសត្រូវ និងបង្កជាឧបសគ្គដល់ការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព។ហេតុនេះបានជាមានការចុះសន្ធិសញ្ញាស្តីពីបត្យាប័ន ដោយកិច្ចព្រមព្រៀងនេះជាការសហការគ្នារវាងប្រទេសជាគូភាគីដែលមានកាតព្វកិច្ចក្នុងការរកដំណោះស្រាយក្នុងករណីដែលមានជនល្មើសបានរត់គេចពីកន្លែងប្រព្រឹត្តបទល្មើសទៅជ្រកកោននៅប្រទេសមួយទៀត ដើម្បីគេចវេះពីការទទួលទោស និងជាយុទ្ធសាស្ត្រក្នុងការចាប់ជនល្មើសបញ្ជូនឱ្យគ្នាទៅវិញទៅមក។

ជាការពិតតាមរយៈការបង្កើតសន្ធិសញ្ញាស្តីពីបត្យាប័ន បានផ្តល់ភាពងាយស្រួលក្នុងកិច្ចសហការរវាងរដ្ឋនឹងរដ្ឋ ហើយជាផ្នែកមួយជួយជម្រុញឱ្យទំនាក់ទំនងការទូតឱ្យកាន់តែមានភាពល្អប្រសើរជាងមុន និងជាការផ្តល់ព័ត៌មានអំពីនីតិវិធីក្នុងការធ្វើបត្យាប័នរវាងគូភាគី។ ម្យ៉ាងទៀតក្នុងអំឡុងពេលបង្កើតសន្ធិសញ្ញាស្តីពីបត្យាប័នគឺតម្រូវឱ្យប្រទេសដែលជាគូភាគីត្រូវតែគោរពតាមនីតិវិធីមួយជារួមនិងធ្វើយ៉ាងណាស្របតាមច្បាប់ជាធរមាន។ មិនតែប៉ុណ្ណោះក្រៅពីបត្យាប័នក៏អាចមានជំនួយផ្នែកច្បាប់ទៅវិញទៅមក ដែលជាទម្រង់មួយនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសផ្សេងគ្នា ក្នុងគោលដៅប្រមូលនិងផ្លាស់ប្តូរព័ត៌មាន ហើយក៏មានការប្រមូលនិងផ្តល់ភស្តុតាងដល់ប្រទេសមួយ ដើម្បីជួយសម្រួលដល់នីតិវិធីជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌនៅក្នុងប្រទេសផ្សេង។

ទន្ទឹមនឹងការបង្កើតសន្ធិសញ្ញាស្តីពីបត្យាប័ននូវតាមបណ្តាប្រទេសផ្សេងៗ បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាក៏បានចុះសន្ធិសញ្ញាស្តីពីបត្យាប័នចំនួនប្រាំពីរសន្ធិសញ្ញារួមមាន ៖

១.សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩

២.សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន ត្រូវបានអនុម័ត កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០

៣.សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលត្រូវបានអនុម័តកាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥

៤.កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ(ខាងត្បូង) ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០

៥.សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម ត្រូវបានអនុម័តកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤

៦.សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨

៧.អនុសញ្ញាស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០។

ជាពិសេសនោះការធ្វើបត្យាប័នក៏មានការចូលរួមពីស្ថាប័នពាក់ព័ន្ធមួយចំនួន ដើម្បីរួមចំណែកក្នុងការអនុវត្តកិច្ចការឱ្យមានភាពរលូននិងទទួលបានប្រសិទ្ធភាពខ្ពស់។

ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការធ្វើបត្យាប័នមាន ៖

ក.ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការដឹកនាំនិងគ្រប់គ្រងវិស័យការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។

ខ.ក្រសួងយុត្តិធម៌មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងវិស័យយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងយុត្តិធម៌ក៏បានបង្កើតអាជ្ញាធរកណ្តាលនៃក្រសួងផងដែរ ដើម្បីជួយសម្របសម្រួលលើការងារជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌ រដ្ឋប្បវេណី ពាណិជ្ជកម្ម បត្យាប័ននិងការបញ្ជូនទណ្ឌិត។

គ.សភាស៊ើបសួរគឺជាសភាពិសេសនៃសាលាឧទ្ធរណ៍ សភាស៊ើបសួរមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ។ ប៉ុន្តែក្នុងការធ្វើបត្យាប័នសភាស៊ើបសួរមានតួនាទីពីរយ៉ាងគឺផ្តល់យោបល់ទៅលើការស្នើសុំដោយរដ្ឋបរទេស និងពិនិត្យអំពីនិយតភាពនៃបត្យាប័នដែលស្នើសុំដោយរាជរដ្ឋាភិបាលកម្ពុជា។

ចំពោះបេសកកម្ម តួនាទី និងភារកិច្ចរបស់អាជ្ញាធរកណ្តាលនៃក្រសួងយុត្តិធម៌មាន៖

- ✓ ទទួលពិនិត្យ និងសម្របសម្រួលលើសំណើ នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រដ្ឋប្បវេណី ពាណិជ្ជកម្ម បត្យាប័ននិងការបញ្ជូនទណ្ឌិត
- ✓ បញ្ជូនសំណើទៅភ្នាក់ងារពាក់ព័ន្ធ និងបញ្ជូនសំណើត្រឡប់ទៅភាគីម្ចាស់សំណើ

- ✓ រៀបចំបញ្ចូលព័ត៌មាន និងតាមដានរាល់សំណើដែលបានទទួល និងបញ្ជូន ដើម្បីធានាឱ្យមានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងឱ្យបានឆាប់រហ័ស
- ✓ ដើរតួជាអង្គភាពបង្គោល ដើម្បីសម្របសម្រួលរាល់បញ្ហាទាក់ទងនឹងជំនួយផ្នែកច្បាប់
- ✓ ធ្វើការទំនាក់ទំនងដោយផ្ទាល់ ឬតាមរយៈផ្លូវទូត ជាមួយស្ថាប័នជាតិ និងអន្តរជាតិដើម្បីសម្របសម្រួលលើការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់
- ✓ រៀបចំពិនិត្យ និងសម្របសម្រួល ការបកប្រែភាសាលើសំណើសុំឯកសារ សំណុំរឿង ភស្តុតាង និងឯកសារពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់
- ✓ រៀបចំទិន្នន័យនៃសំណើសុំជំនួយផ្នែកច្បាប់ និងចងក្រងឯកសារច្បាប់ដោយបញ្ជូនទៅក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យដោយបង្ហោះនៅលើគេហទំព័ររបស់ក្រសួងយុត្តិធម៌
- ✓ រក្សាការសំងាត់ចំពោះសំណើសុំជំនួយ ខ្លឹមសារ និងឯកសារគាំទ្រសំណើ ហេតុការណ៍នៃការផ្តល់ជំនួយ និងចំណាត់ការណាមួយដែលអនុវត្តទៅតាមសំណើ
- ✓ ធានានូវព័ត៌មាន និងភស្តុតាងត្រូវបានការពារមិនឱ្យបាត់បង់ និងការទទួលបានការប្រើប្រាស់ ការកែប្រែ ការបង្ហាញដោយគ្មានការអនុញ្ញាត ឬការប្រើប្រាស់មិនត្រឹមត្រូវ ផ្សេងៗ
- ✓ រៀបចំផែនការសកម្មភាព នៃការអភិវឌ្ឍលើការងារសម្របសម្រួល ការចំណាយ ដំណើរទស្សនកិច្ចសិក្សា ចូលរួមសិក្ខាសាលា និងកិច្ចប្រជុំ ទាំងក្នុងនិងក្រៅប្រទេស
- ✓ ធ្វើការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកជំនួយក្នុងការបណ្តុះបណ្តាលធនធានមនុស្ស
- ✓ បង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីសម្របសម្រួល លើការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់
- ✓ ធ្វើរបាយការណ៍រៀងរាល់ខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- ✓ ទទួល និងអនុវត្តភារកិច្ចចាំបាច់ផ្សេងទៀត តាមការប្រគល់ជូនរបស់ឯកឧត្តមរដ្ឋមន្ត្រី។

តាមរយៈប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលនៃក្រសួងយុត្តិធម៌មានតួនាទី និងភារកិច្ចក្នុងការទទួលពិនិត្យ និងសម្របសម្រួលលើសំណើធ្វើបត្យាប័ន។

ដើម្បីធ្វើបត្យាប័ននៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន តើត្រូវអនុវត្តនូវលក្ខខណ្ឌនិងនីតិវិធីអ្វីខ្លះ?

មុនឈានដល់ការបកស្រាយឱ្យលម្អិតពីប្រធានបទខាងលើ យើងខ្ញុំនឹងបង្ហាញពីចំណុចដែលធ្វើឱ្យដំណើរការនៃការធ្វើបត្យាប័នអាចប្រព្រឹត្តទៅបាន ដោយបែងចែកជាបីជំពូក ក្នុងជំពូកនីមួយៗមានពីរផ្នែក ៖

**ជំពូកទី១ សញ្ញាណទូទៅនៃបត្យាប័ន**

**ផ្នែកទី១ អត្ថន័យនិងក្របខណ្ឌពិសេសក្នុងការធ្វើបត្យាប័ន**

១.១.និយមន័យ

១.២.ក្របខណ្ឌពិសេសក្នុងការធ្វើបត្យាប័ន

១.៣.ក្របខណ្ឌច្បាប់ផ្សេងៗ

**ផ្នែកទី២ កាតព្វកិច្ចនិងគោលការណ៍ណែនាំអន្តរជាតិស្តីពីបត្យាប័ន និងការធ្វើបត្យាប័ននៅកម្ពុជា**

២.១.កាតព្វកិច្ចនិងគោលការណ៍ណែនាំអន្តរជាតិស្តីពីការធ្វើបត្យាប័ន

២.២.ការធ្វើបត្យាប័ននៅក្នុងប្រទេសកម្ពុជា

២.៣.បញ្ហានៃការធ្វើបត្យាប័ននៅប្រទេសកម្ពុជា

**ជំពូកទី២ លក្ខខណ្ឌក្នុងការធ្វើបត្យាប័ន**

**ផ្នែកទី១ ការធ្វើបត្យាប័នផ្អែកតាមសន្ធិសញ្ញា**

១.១ .ការបង្កើតសន្ធិសញ្ញាស្តីពីបត្យាប័ន

១.២ .ករណីមានចែងក្នុងអនុសញ្ញា

**ផ្នែកទី២ ការធ្វើបត្យាប័នផ្អែកតាមច្បាប់**

២.១ .ករណីមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ពិសេស

២.២ .ការអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឬករណីមិនមានសន្ធិសញ្ញា

**ជំពូកទី៣ នីតិវិធីក្នុងការធ្វើបត្យាប័ន**

**ផ្នែកទី១ នីតិវិធីនៃការដាក់សំណើរបស់ព្រះរាជាណាចក្រកម្ពុជា**

**ផ្នែកទី២ នីតិវិធីនៃការទទួលសំណើរបស់ព្រះរាជាណាចក្រកម្ពុជា**

# ជំពូកទី១

# សញ្ញាណទូទៅនៃបណ្តាញ

# ជំពូកទី១

# សញ្ញាណទូទៅនៃបត្យាប័ន

ការកកើតនៃបត្យាប័ន នៅពេលរដ្ឋបរទេសដាក់សំណើស្នើសុំឱ្យព្រះរាជាណាចក្រកម្ពុជា ប្រគល់អាណិកជនបរទេសណាមួយកំពុងស្នាក់នៅក្នុងប្រទេសកម្ពុជា ដើម្បីយកបុគ្គលដែលទាមទារនោះមកធ្វើការចោទប្រកាន់តាមផ្លូវតុលាការ ឬផ្តន្ទាទោសដាក់ពន្ធនាគារដោយតុលាការនៃរដ្ឋដាក់សំណើ។

បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជា ពិនិត្យមើលនិយតភាពនៃការស្នើសុំធ្វើបត្យាប័ន រួចសម្រេចប្រគល់អាណិកជនបរទេសនោះឱ្យរដ្ឋស្នើសុំ ពេលនោះកកើតមាននូវការធ្វើបត្យាប័ន ហើយបុគ្គលដែលរដ្ឋបរទេសទាមទារ គឺជាកម្មវត្ថុនៃការធ្វើបត្យាប័ន។

ការធ្វើបត្យាប័នអាចត្រូវបានកំណត់និយមន័យថា ជាការប្រគល់ខ្លួនបុគ្គលម្នាក់ដោយរដ្ឋ (រដ្ឋដែលត្រូវបានស្នើសុំ) ទៅឱ្យអាជ្ញាធររបស់រដ្ឋមួយទៀត (រដ្ឋដែលបានធ្វើការស្នើសុំ) ក្នុងគោលបំណងផ្តន្ទាទោស ឬការអនុវត្តការកាត់ទោស។ ទោះបីជាការធ្វើបត្យាប័នមិនមែនជាទស្សនៈថ្មីក៏ដោយ សកលភាវូបនីយកម្ម និងការធ្វើដំណើររបស់ប្រជាជន ឆ្លងកាត់ព្រំដែន និងយុត្តាធិការរដ្ឋ បានធ្វើឱ្យគោលការណ៍ណែនាំជាក់លាក់សម្រាប់ការធ្វើបត្យាប័ន ឧក្រិដ្ឋជនដែលត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសក្លាយទៅជាភាពចាំបាច់។

## ផ្នែកទី១ អត្ថន័យនិងក្របខណ្ឌពិសេសក្នុងការធ្វើបត្យាប័ន

### ១.១.និយមន័យ

- បត្យាប័ន ជានីតិវិធីនៃការប្រគល់ខ្លួនបុគ្គលម្នាក់ដោយរដ្ឋ(រដ្ឋទទួលសំណើ) ទៅឱ្យអាជ្ញាធររបស់រដ្ឋមួយផ្សេងទៀត(រដ្ឋដាក់សំណើ) ក្នុងគោលបំណងដើម្បីយកជននោះមកធ្វើការចោទប្រកាន់ចំពោះមុខយុត្តាធិការរបស់ខ្លួន ឬយកជននោះមកអនុវត្តទោសនៅក្នុងប្រទេសរបស់ខ្លួន។ បត្យាប័នកើតមានឡើងនៅពេលដែលរដ្ឋមួយជារដ្ឋស្នើសុំ ដែលអាចហៅថារដ្ឋដាក់សំណើឬរដ្ឋធ្វើសំណើ បានធ្វើការស្នើសុំទៅរដ្ឋមួយផ្សេងទៀត ដើម្បីធ្វើបត្យាប័នដែលរដ្ឋនោះអាចហៅបានថារដ្ឋទទួលសំណើ។
- បត្យាប័ន ជានីតិវិធីនៃការប្រគល់ឬបញ្ជូនខ្លួនជនល្មើសពីរដ្ឋមួយទៅរដ្ឋមួយទៀត។

ជារួមបត្យាប័ន សំដៅដល់នីតិវិធីមួយដែលរដ្ឋដាក់សំណើបានធ្វើសំណើសុំជនណាម្នាក់ទៅរដ្ឋមួយទៀត ដើម្បីយកជននោះមកធ្វើការចោទប្រកាន់ចំពោះមុខយុត្តាធិការរបស់ខ្លួន ឬយកមកអនុវត្តទោសនៅក្នុងប្រទេសរបស់ខ្លួន។

ពាក្យដែលប្រើប្រាស់ក្នុងការធ្វើបត្យាប័ន ៖រដ្ឋធ្វើសំណើ ,បុគ្គលដែលគេទាមទារ

- ✓ រដ្ឋធ្វើសំណើ សំដៅដល់រដ្ឋបរទេសដែលស្នើសុំឱ្យធ្វើបត្យាប័នអាណិកជនបរទេស
- ✓ បុគ្គលដែលគេទាមទារ សំដៅដល់អាណិកជនបរទេសដែលស្នាក់លើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មវត្ថុនៃពាក្យស្នើសុំឱ្យធ្វើបត្យាប័ន។

## ១.២.ក្របខណ្ឌពិសេសក្នុងការធ្វើបត្យាប័ន

ក្របខណ្ឌច្បាប់សម្រាប់អនុលោមក្នុងការធ្វើបត្យាប័នមានបីគឺ៖

- ➢ ក្របខណ្ឌនៃបត្យាប័នពិសេស៖ នឹងត្រូវអនុលោមទៅតាមសន្ធិសញ្ញាស្តីពីបត្យាប័នដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន។ សន្ធិសញ្ញានេះមានចែងលម្អិតអំពីនីតិវិធីនៃការធ្វើបត្យាប័ន។
- ➢ ក្របខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិពិសេស៖ ក្នុងករណីដែលមានច្បាប់ពិសេសស្តីពីបត្យាប័នគឺត្រូវអនុវត្តតាមនីតិវិធីនៃបត្យាប័នទៅតាមច្បាប់ពិសេសនោះ (មាត្រា៥៦៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- ➢ ក្របខណ្ឌនៃបត្យាប័នតាមក្រមនីតិវិធីព្រហ្មទណ្ឌ៖ នៅពេលដែលមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយរដ្ឋធ្វើសំណើបត្យាប័នទេ ជាគោលការណ៍ត្រូវអនុវត្តតាមនីតិវិធីរួមស្តីពីបត្យាប័នដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

ចំពោះប្រទេសមួយចំនួនដែលមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយប្រទេសកម្ពុជា បើមានការស្នើសុំធ្វើបត្យាប័នត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

## ១.៣.ក្របខណ្ឌច្បាប់ផ្សេងៗ

### ក.រដ្ឋធម្មនុញ្ញ

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានបញ្ញត្តិត្រង់មាត្រា៣៣ " ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេសឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក។ មិនតែប៉ុណ្ណោះប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។ចំពោះការទទួលសញ្ជាតិខ្មែរត្រូវបានកំណត់ក្នុងច្បាប់។"

### ខ.សន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិស្តីពីការធ្វើបត្យាប័ន

ផ្អែកតាមមាត្រា៣នៃសន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិស្តីពីការធ្វើបត្យាប័ន បានចែងថា ការធ្វើបត្យាប័នមិនត្រូវបានអនុញ្ញាត ប្រសិនបើបុគ្គលដែលត្រូវបានស្នើសុំឱ្យធ្វើបត្យាប័ន អាចពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម ហើយការធ្វើបត្យាប័នអាចនឹងត្រូវបានបដិសេធ ប្រសិនបើរដ្ឋដែលត្រូវបានស្នើសុំ ចាត់ទុកថាបទល្មើសដែលត្រូវស្នើឱ្យមានការធ្វើបត្យាប័នមានពាក់ព័ន្ធនឹងនយោបាយ ឬយោធា។ រដ្ឋដែលត្រូវបានស្នើឱ្យធ្វើបត្យាប័ន ត្រូវបដិសេធសំណើសុំធ្វើបត្យាប័ន ប្រសិនបើរដ្ឋដែលធ្វើការស្នើសុំ មានការកាត់ទោសប្រហារជីវិត

ចំពោះបទល្មើស លុះត្រាតែមានការធានាថា នឹងមិនមានការអនុវត្តការកាត់ទោសប្រហារជីវិត។ក្នុងករណីបែបនេះ សេចក្តីសម្រេចថា មិនធ្វើបត្យាប័នមានលក្ខណៈស្របច្បាប់។

ទោះបីជាច្បាប់អន្តរជាតិ មិនបានផ្តល់កាតព្វកិច្ចឱ្យរដ្ឋធ្វើបត្យាប័នក៏ដោយ ក៏សន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិ ស្តីពីការធ្វើបត្យាប័ន បានចែងអំពីគំរូសម្រាប់ច្បាប់ជាតិ និងកិច្ចព្រមព្រៀងទ្វេភាគីដែលពាក់ព័ន្ធនឹងការធ្វើបត្យាប័ន ព្រមទាំង មានបំណងចែងអំពីប្រទេសដែលមានមូលដ្ឋានបែបនេះ ដើម្បីធានាថាដំណើរការនៃការធ្វើបត្យាប័នឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។

## ផ្នែកទី២ ភាតព្វកិច្ចនិងគោលការណ៍ណែនាំអន្តរជាតិស្តីពីបត្យាប័ន និងការធ្វើបត្យាប័ននៅកម្ពុជា

### ២.១.ភាតព្វកិច្ចនិងគោលការណ៍ណែនាំអន្តរជាតិស្តីពីការធ្វើបត្យាប័ន

កាតព្វកិច្ចធ្វើបត្យាប័ន មានក្នុងទម្រង់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬសន្ធិសញ្ញា ពហុភាគីឬទ្វេភាគី ដូចជាសន្ធិសញ្ញារវាងកម្ពុជានិងរដ្ឋបរទេសមួយចំនួន។ប្រទេសខ្លះព្រមធ្វើបត្យាប័ន ដោយមិនចាំបាច់មានកិច្ចព្រមព្រៀងទេ តាមគោលការណ៍បដិការ។ដោយរដ្ឋនៃប្រព័ន្ធស៊ីវិលឡភាគច្រើនប្រកាន់យក។រដ្ឋក្រុមនេះ ជាទូទៅមិនធ្វើបត្យាប័នជនជាតិខ្លួនទេ ដែលតម្រូវឱ្យមានយុត្តាធិការទូលាយ សម្រាប់កាត់ទោសប្រជាពលរដ្ឋខ្លួន ដែលប្រព្រឹត្តបទល្មើសនៅក្រៅប្រទេស តាមគោលការណ៍ Active Nationality Principle។ដំណើរការបត្យាប័ន រដ្ឋនៃប្រព័ន្ធស៊ីវិលឡ ទាមទារតែឯកសារគាំទ្រមួយចំនួនខុសគ្នានឹងប្រទេសនៃប្រព័ន្ធកុំមុនឡ ដែលទាមទារនូវកម្រិតភស្តុតាងបង្ហាញថា បុគ្គលដែលគេទាមទារ បានប្រព្រឹត្តបទល្មើស។បន្ថែមពីនេះប្រទេសកុំមុនឡ ប្រកាន់យកយុត្តាធិការចង្អៀត មានសមត្ថកិច្ចកាត់ទោសតែបទល្មើសកើតក្នុងដែនដីខ្លួន។ការធ្វើបត្យាប័នទៅរួច ជាទូទៅលុះត្រាមានកិច្ចព្រមព្រៀង។ទោះបីជាយ៉ាងនេះក្តី កាតព្វកិច្ចធ្វើបត្យាប័ន ក្នុងសន្ធិសញ្ញាមិនទាន់មានភាពដាច់ខាតនៅឡើយ។

គោលការណ៍ណែនាំអន្តរជាតិក្នុងការធ្វើបត្យាប័នអន្តររដ្ឋ តាមទំនៀមទម្លាប់ត្រូវបានគ្រប់គ្រងដោយសន្ធិសញ្ញាទ្វេភាគី ដែលបានបញ្ជាក់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការធ្វើបត្យាប័នឧក្រិដ្ឋជនដែលត្រូវបានចោទប្រកាន់ នៅក្នុងប្រទេសពីរ។ សន្ធិសញ្ញាក្នុងតំបន់ ដូចជាអនុសញ្ញាអន្តរអាមេរិកកាំងស្តីពីការធ្វើបត្យាប័ន ក៏ត្រូវបានអនុម័តផងដែរសម្រាប់បម្រើគោលបំណងនៃការធ្វើបត្យាប័ន ទោះបីជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) មិនទាន់បានបង្កើតសន្ធិសញ្ញាបែបនេះក៏ដោយ។[៩]

[៩]កម្រងឯកសារស្តីពីការធ្វើចំណាត់ថ្នាក់ច្បាប់របស់ ម.ស.ម.ក វគ្គ៧ "ច្បាប់ស្តីពីការធ្វើបត្យាប័ន"ខែកក្កដា ឆ្នាំ២០១២

## ២.២.ការធ្វើបត្យាប័ននៅក្នុងប្រទេសកម្ពុជា

ការធ្វើបត្យាប័នប្រជាពលរដ្ឋខ្មែរ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងក្នុងមាត្រា៣៣ថា "ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក។" ជាងនេះទៅទៀត រដ្ឋធម្មនុញ្ញបានចែងថា សន្ធិសញ្ញាអន្តរជាតិដែលមានកម្មវិធីជាភាគី ត្រូវដាក់បញ្ចូលក្នុងច្បាប់ជាតិ។ កម្ពុជាគឺជាប្រទេសដែលបានចុះហត្ថលេខាលើសន្ធិសញ្ញាបែបនេះជាច្រើន ដែលមានបំណងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ហេតុនេះហើយ កម្ពុជាត្រូវអនុវត្តតាមសន្ធិសញ្ញានេះនៅពេលធ្វើសេចក្ដីសម្រេចបត្យាប័ន។

ការធ្វើបត្យាប័នត្រូវបានរៀបរាប់យ៉ាងលម្អិតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ក្រមនេះអាចយកមកអនុវត្តក្នុងការស្នើសុំធ្វើបត្យាប័ន នៅពេលអវត្តមាននៃសន្ធិសញ្ញានៃការធ្វើបត្យាប័ន រវាងប្រទេសកម្ពុជា និងរដ្ឋដែលស្នើសុំការធ្វើបត្យាប័ន។ ក្រមនេះបានរៀបរាប់យ៉ាងលម្អិតអំពីដែនកំណត់នៃការធ្វើបត្យាប័ន និងមូលហេតុដែលការធ្វើបត្យាប័នអាចត្រូវបានបដិសេធ ព្រមទាំងបានរួមបញ្ចូលបទបញ្ជាដែលមានការទទួលស្គាល់ ក្នុងសន្ធិសញ្ញាអន្តរជាតិ។ ក្រមនេះក៏បានរៀបរាប់ អំពីនីតិវិធីនៃការស្នើសុំធ្វើបត្យាប័នផងដែរ។[២]

## ២.៣.បញ្ហានៃការធ្វើបត្យាប័ននៅប្រទេសកម្ពុជា

មានភាពមិនស៊ីសង្វាក់គ្នាមួយចំនួនរវាងសន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិ និងបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីការធ្វើបត្យាប័នរបស់កម្ពុជា ដូចជារយៈពេលនៃការឃុំខ្លួនជនសង្ស័យដែលត្រូវបានអនុញ្ញាត នៅពេលពិចារណាលើសំណើធ្វើបត្យាប័ន៖ ខណៈពេលដែលសន្ធិសញ្ញាគំរូរបស់ អ.ស.ប អនុញ្ញាតឱ្យមានរយៈពេលត្រឹម ៤០ថ្ងៃ ក្រមនេះអនុញ្ញាតឱ្យមានរយៈពេល៦០ថ្ងៃ។ ជាងនេះទៅទៀត ក្រមនេះមិនបានចែងអំពីបញ្ហាសិទ្ធិមនុស្សសំខាន់ៗឡើយ។ ដោយខុសប្លែកពីសន្ធិសញ្ញាគំរូរបស់ អ.ស.ប ក្រមនេះមិនបានចែងថា ការដាក់ទណ្ឌកម្មគឺជាមូលហេតុចាំបាច់ ឬមានលក្ខណៈខុសប្លែក ដើម្បីបដិសេធការស្នើសុំធ្វើបត្យាប័ន។ស្រដៀងគ្នានេះដែរ ក្រមនេះមិនបានចែងឱ្យបានច្បាស់ថា ការធ្វើបត្យាប័នត្រូវបានបដិសេធ នៅពេលដែលបុគ្គលដែលគេធ្វើបត្យាប័ន ត្រូវកាត់ទោសប្រហារជីវិតនៅក្នុងប្រទេសដែលស្នើសុំធ្វើបត្យាប័នឡើយ។ ដោយហេតុថាក្រមនេះចូលជាធរមានចំពោះការស្នើសុំធ្វើបត្យាប័ន នៅពេលមិនមានសន្ធិសញ្ញាដែលពាក់ព័ន្ធ និងទោះបីជាប្រទេសកម្ពុជាមានសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងធ្វើបត្យាប័នតិចតួចក៏ដោយ ភាពខ្វះចន្លោះនេះគឺជាបញ្ហាដែលគួរឱ្យបារម្ភ។[៣]

[២] កម្រងឯកសារស្តីពីការធ្វើចំណាត់ថ្នាក់ច្បាប់របស់ ម.ស.ម.ក វគ្គ៧ "ច្បាប់ស្តីពីការធ្វើបត្យាប័ន"ខែកក្កដា ឆ្នាំ២០១២

[៣]កម្រងឯកសារស្តីពីការធ្វើចំណាត់ថ្នាក់ច្បាប់របស់ ម.ស.ម.ក វគ្គ៧ "ច្បាប់ស្តីពីការធ្វើបត្យាប័ន"ខែកក្កដា ឆ្នាំ២០១២

ករណីទើបនឹងកើតឡើងថ្មីៗរបស់អ្នកជំនួញជនជាតិរុស្ស៊ី អាឡិចហ្សេនដឺ ត្រូហ្វីមូវ ប្រធានក្រុមវិនិយោគ ដែលដំណើរការនៅប្រទេសកម្ពុជា គឺជាឧទាហរណ៍នៃភាពខ្វះចន្លោះ ក្នុងក្របខណ្ឌច្បាប់នៃការធ្វើបត្យាប័ន នៅប្រទេសកម្ពុជា។ត្រូហ្វីមូវ ត្រូវបានលើកលែងទោសនៅខែធ្នូ ឆ្នាំ២០១១ ទោះបីជាមានការកាត់ឱ្យជាប់ទោសរយៈពេលបួនឆ្នាំ ជាជាងប្រាំបីឆ្នាំ ដោយការបំពានលើកុមារមិនទាន់ពេញវ័យ និងទោះបីជាមានការស្នើសុំពីប្រទេសរុស្ស៊ីឱ្យធ្វើបត្យាប័នគាត់ ពីបទឧក្រិដ្ឋប្រហាក់ប្រហែលគ្នាដែលគាត់បានប្រព្រឹត្តនៅទីនោះ។ នៅពេលដែលគាត់ត្រូវបានចាប់ខ្លួនម្តងទៀតនៅប្រទេសកម្ពុជានៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២ ជាថ្មីម្តងទៀត រដ្ឋាភិបាលកម្ពុជាជ្រើសរើសមិនពិចារណាចំពោះសំណើធ្វើបត្យាប័ន ហើយបន្ទាប់មក បែរជាបញ្ជូនគាត់ទៅប្រទេសកូរ៉េខាងត្បូងយ៉ាងឆាប់រហ័ស។ ការបដិសេធជាញឹកញាប់ របស់រាជរដ្ឋាភិបាលកម្ពុជា (រ.ដ.ក) ក្នុងការធ្វើបត្យាប័ន ត្រូហ្វីមូវបង្ហាញអំពីបំណងរបស់ រ.ដ.ក ដើម្បីជៀសផុតពីច្បាប់ស្តីពីការធ្វើបត្យាប័ន។[៩]

[៩] កម្រងឯកសារស្តីពីការធ្វើចំណាត់ថ្នាក់ច្បាប់របស់ ម.ស.ម.ក វគ្គ៧ "ច្បាប់ស្តីពីការធ្វើបត្យាប័ន"ខែកក្កដា ឆ្នាំ២០១២

# ជំពូកទី២

# លក្ខខណ្ឌក្នុងការធ្វើបត្យាប័ន

# ជំពូកទី២

# លក្ខខណ្ឌក្នុងការធ្វើបត្យាប័ន

បើពិនិត្យមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ត្រង់មាត្រា១២និងមាត្រា៧ ដោយមាត្រា១២ បានចែងពីគោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា "ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃ ព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹង ដែនដីនៃព្រះរាជាណាចក្រកម្ពុជា"។ ក៏ប៉ុន្តែក្នុងមាត្រា៧ បានបញ្ញត្តិអំពីលក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ កម្ពុជា "ក្នុងរឿងព្រហ្មទណ្ឌ ដែនអនុវត្តច្បាប់កម្ពុជាក្នុងលំហ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ"។ ហេតុដូចនេះ បុគ្គលដែលបានប្រព្រឹត្តបទល្មើសនៅក្នុងដែនដីនៃ ព្រះរាជាណាចក្រកម្ពុជាមិនថាជនល្មើសនេះមានសញ្ជាតិណា ឬជាជនជាតិណាក៏ដោយ ត្រូវតែអនុវត្តតាម ច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលើកលែងក្នុងករណីមានសន្ធិសញ្ញាឬកិច្ចព្រមព្រៀងអន្តរជាតិ ដោយត្រូវអនុលោមតាមសន្ធិសញ្ញាដែលគូភាគីបានព្រមព្រៀងគ្នា។ចំពោះករណីជនបរទេសដែលបានប្រព្រឹត្ត បទល្មើសនៅក្នុងដែនដីនៃប្រទេសកម្ពុជា ហើយគ្មានសន្ធិសញ្ញាអន្តរជាតិទេ បុគ្គលនោះត្រូវអនុវត្តទោសតាម ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌឬច្បាប់របស់រដ្ឋដែលជាទីកន្លែងប្រព្រឹត្តបទល្មើស លើកលែងមាន ករណីពិសេស។

បត្យាប័ន ជានីតិវិធីក្នុងការស្នើសុំចាប់បុគ្គលដែលបានប្រព្រឹត្តបទល្មើសរួចរត់គេចពីការទទួលខុសត្រូវ ដោយកំពុងស្នាក់នៅលើដែនដីមួយទៀត ឬជាការស្នើសុំជនណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសនៅលើដែនដី ផ្សេង ប៉ុន្តែការស្នើសុំនេះក្នុងករណីបុគ្គលនោះមានសញ្ជាតិរបស់រដ្ឋធ្វើសំណើ។ជារួមបត្យាប័ន គឺជានីតិវិធីក្នុងការ ប្រគល់ឬបញ្ជូនជនល្មើសពីប្រទេសមួយទៅប្រទេសមួយទៀត ដែលយើងហៅបានថារដ្ឋមួយជារដ្ឋដាក់សំណើ និងរដ្ឋមួយទៀតជារដ្ឋទទួលសំណើ ក៏ប៉ុន្តែបត្យាប័ន អាចធ្វើទៅបានលុះត្រាតែមានការព្រមព្រៀងឬការយល់ ព្រមរវាងរដ្ឋដែលជាគូភាគីនៃកិច្ចព្រមព្រៀង។ ចំណែកការព្រមព្រៀងនេះទៀតសោត ត្រូវតែជាការសម្រេចដោយ ឆន្ទៈពិតប្រាកដរបស់រដ្ឋទទួលសំណើ ក្នុងការបញ្ជូនបុគ្គលនោះមកឱ្យអាជ្ញាធរនៃរដ្ឋដាក់សំណើ ដើម្បីធ្វើការ ចោទប្រកាន់ ឬជំនុំជម្រះ និងផ្តន្ទាទោសបុគ្គលនោះទៅតាមច្បាប់របស់រដ្ឋធ្វើសំណើ។

ចំពោះការផ្ទេរឬបញ្ជូនជនល្មើសពីរដ្ឋទទួលសំណើមកកាន់រដ្ឋធ្វើសំណើ ត្រូវពឹងផ្អែកទៅលើសន្ធិសញ្ញា ។ចំណែកឯការស្នើសុំធ្វើបត្យាប័នទាំងអស់មិនមែនសុទ្ធតែទទួលបានជោគជ័យទាំងស្រុងនោះទេ ទោះបីក្នុង ករណីមានសន្ធិសញ្ញារវាងរដ្ឋធ្វើសំណើនិងរដ្ឋទទួលសំណើក៏ដោយ ហើយក៏មិនប្រាកដថាករណីមិនមាន សន្ធិសញ្ញា

អន្តរជាតិ រវាងរដ្ឋដាក់សំណើនិងរដ្ឋទទួលសំណើសុទ្ធតែមិនទទួលបានជោគជ័យនោះដែរ។ក្របខណ្ឌក្នុងការធ្វើបត្យាប័នដោយអនុលោមតាមសន្ធិសញ្ញាបត្យាប័ន,បទប្បញ្ញត្តិនៃច្បាប់ពិសេស និងក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ផ្នែកទី១ ការធ្វើបត្យាប័នផ្អែកតាមសន្ធិសញ្ញា

ការរៀបចំសន្ធិសញ្ញា អនុសញ្ញាឬកិច្ចព្រមព្រៀងមានការកំណត់នៅមាត្រា៧នៃអនុសញ្ញា Vienna Convention on the Law of Treaties ឆ្នាំ១៩៦៩។សន្ធិសញ្ញា ជាកិច្ចព្រមព្រៀងអន្តរជាតិដែលធ្វើឡើងរវាងរដ្ឋនិងរដ្ឋ នៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរហើយស្ថិតនៅក្រោមច្បាប់អន្តរជាតិ។សន្ធិសញ្ញា អនុសញ្ញាឬកិច្ចព្រមព្រៀង អាចធ្វើទៅតាមការព្រមព្រៀង និងការឯកភាពគ្នាថាត្រូវបង្កើតសន្ធិសញ្ញានោះជាទ្វេភាគី ឬពហុភាគី និងស្របតាមកម្មវត្ថុនៃសន្ធិសញ្ញា។ការរៀបចំសន្ធិសញ្ញា ត្រូវពឹងផ្អែកលើច្បាប់ដែលមានរដ្ឋធម្មនុញ្ញជាចម្បង អាចភ្ជាប់ទៅនឹងសន្ធិសញ្ញាអន្តរជាតិ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍រដ្ឋ ក្នុងករណីនេះច្បាប់រដ្ឋមិនអាចជំទាស់នឹងសន្ធិសញ្ញាដែលរដ្ឋបានផ្តល់សច្ចាប័នរួចរាល់នោះទេ ក៏ប៉ុន្តែក្នុងករណីសន្ធិសញ្ញាអន្តរជាតិ បានបង្កជាផលប៉ះពាល់ ដល់ផលប្រយោជន៍របស់រដ្ឋ រដ្ឋអាចស្នើសុំលុបចោល ឬដកខ្លួនចេញពីសន្ធិសញ្ញានោះបាន។

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជា បានចុះសន្ធិសញ្ញាអន្តរជាតិជាមួយបណ្តាប្រទេសផ្សេងៗ ដើម្បីបង្កើតទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋឱ្យកាន់តែមានភាពល្អប្រសើរឡើង។បន្ថែមពីលើនេះ ប្រទេសកម្ពុជាក៏បានចុះសន្ធិសញ្ញាដែលទាក់ទងទៅនឹងបត្យាប័នផងដែរ ហើយការចុះសន្ធិសញ្ញានេះបានផ្តល់ភាពងាយស្រួលជាច្រើនដល់រដ្ឋដែលជាគូភាគី តាមរយៈការឱ្យរដ្ឋជាភាគីបានដឹងជាមុន នូវនីតិវិធីក្នុងការធ្វើបត្យាប័ន ព្រមទាំងដែនអនុវត្តខ្លះដល់គូភាគី តាមការព្រមព្រៀងគ្នានៅក្នុងសន្ធិសញ្ញា។

សម្រាប់ករណីមានសន្ធិសញ្ញាស្តីពីបត្យាប័នគឺអនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញា ភាគីម្ខាងយល់ព្រមធ្វើបត្យាប័ននូវជនទាំងឡាយណាដែលមានវត្តមាននៅលើដែនដីរបស់ខ្លួន ដែលគូភាគីនៃសន្ធិសញ្ញាកំពុងស្វែងរក ដើម្បីធ្វើការចោទប្រកាន់ ជំនុំជម្រះ ឬអនុវត្តទោស ចំពោះបទល្មើសដែលអាចធ្វើបត្យាប័ន។

មួយវិញទៀតសន្ធិសញ្ញានេះមិនមានឥទ្ធិពលដល់សិទ្ធិនិងកាតព្វកិច្ចទាំងឡាយដែលមានចែង ក្នុងសន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា លិខិតុបករណ៍អន្តរជាតិផ្សេងទៀតដែលគូភាគីជាសមាជិកឡើយ។

### ១.១.ការបង្កើតសន្ធិសញ្ញាស្តីពីបត្យាប័ន

សន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិ ស្តីពីការធ្វើបត្យាប័ន បានចែងអំពីគំរូសម្រាប់ច្បាប់ជាតិ និងកិច្ចព្រមព្រៀងទ្វេភាគីដែលពាក់ព័ន្ធនឹងការធ្វើបត្យាប័ន ព្រមទាំង មានបំណងចែងអំពីប្រទេសដែលមានមូលដ្ឋាន បែបនេះ ដើម្បីធានាថាដំណើរការនៃការធ្វើបត្យាប័នឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។

សន្ធិសញ្ញា គឺជាកិច្ចព្រមព្រៀងអន្តរជាតិដែលធ្វើឡើងជាលាយលក្ខណ៍អក្សររវាងរដ្ឋនិងរដ្ឋ រវាងរដ្ឋនិងអង្គការអន្តរជាតិ និងរវាងអង្គការអន្តរជាតិនិងអង្គការអន្តរជាតិ ហើយស្ថិតក្រោមការគ្រប់គ្រងនៃនីតិអន្តរជាតិសាធារណៈ ដើម្បីបង្កើតអានុភាពគតិយុត្ត។

បត្យាប័នអាចធ្វើទៅបានលុះត្រាតែមានការព្រមព្រៀងរវាងរដ្ឋនិងរដ្ឋ ហើយការព្រមព្រៀងនេះទៀតសោត គឺត្រូវតែចេញពីឆន្ទៈរបស់រដ្ឋទទួលសំណើ ក្នុងការប្រគល់បុគ្គលនោះឱ្យទៅរដ្ឋដាក់សំណើ។សន្ធិសញ្ញាស្តីពីបត្យាប័នត្រូវធ្វើឡើងតាមរយៈការចរចា ដើម្បីកំណត់នូវនីតិវិធីសមស្របនិងកំណត់នូវបទល្មើសទាំងឡាយណាដែលអនុញ្ញាតឱ្យធ្វើបត្យាប័នបានឬមិនបាន។បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាបានចុះសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយរដ្ឋបរទេសមានដូចជាៈ ព្រះរាជាណាចក្រថៃ , សាធារណរដ្ឋប្រជាមានិតចិន , សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ , សាធារណរដ្ឋកូរ៉េ,សាធារណរដ្ឋសង្គមនិយមវៀតណាម , សាធារណរដ្ឋបារាំង , សហព័ន្ធរុស្ស៊ី។

នៅក្នុងមាត្រា និងប្រការនីមួយៗនៃសន្ធិសញ្ញាបត្យាប័ន បានបញ្ញត្តិពីៈកាតព្វកិច្ចធ្វើបត្យាប័ន,បទល្មើសដែលអាចធ្វើបត្យាប័ន,មូលដ្ឋានដាច់ខាតសម្រាប់ធ្វើការបដិសេធ,មូលដ្ឋាននៃការបដិសេធដោយឆន្ទានុសិទ្ធិ,ការធ្វើបត្យាប័នចំពោះពលរដ្ឋសាមី,វិធីផ្តល់ព័ត៌មាន,សំណើបត្យាប័ននិងឯកសារចាំបាច់ដែលត្រូវភ្ជាប់ជាមួយ,ព័ត៌មានបន្ថែម,ការចាប់ខ្លួនបណ្តោះអាសន្ន,ការធ្វើបត្យាប័នសាមញ្ញ,ការសម្រេចចិត្តទៅលើការស្នើ,ការប្រគល់ខ្លួនជនដែលត្រូវស្នើសុំ,ការពន្យារពេលនៃការប្រគល់ខ្លួនឬការប្រគល់ខ្លួនជាបណ្តោះអាសន្ន,សំណើបត្យាប័នធ្វើឡើងដោយរដ្ឋច្រើន,វិធានពិសេស,ការប្រគល់ទ្រព្យសម្បត្តិ,ដំណើរឆ្លងកាត់ ,ការជូនដំណឹងអំពីលទ្ធផល,ការឧបត្ថម្ភនិងការចំណាយ,ទំនាក់ទំនងជាមួយនឹងអនុសញ្ញាពហុភាគី,ដំណោះស្រាយនៃបញ្ហាវិវាទ,ការធ្វើវិសោធនកម្ម,ការចូលជាធរមាននិងការបញ្ចប់កិច្ចព្រមព្រៀង។

**ក.សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ**

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដែលធ្វើនៅទីក្រុងបាងកក នាថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៨ នឹងត្រូវបានរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី២ ហើយព្រឹទ្ធសភាបានអនុម័តយល់ស្រប នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី១។

គោលបំណងនៃការចុះសន្ធិសញ្ញានេះ ដើម្បីជម្រុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធភាព រវាងប្រទេសទាំងពីរក្នុងការកម្ចាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាពនិងផលប្រយោជន៍ទាំងសងខាង តាមការចុះសន្ធិសញ្ញាបត្យាប័ន។សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសទាំងពីរមាន២៤ប្រការ ។

**ខ.សន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន**

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលធ្វើនៅ ទីក្រុងប៉េកាំង នាថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ នឹងត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយព្រឹទ្ធសភាបានអនុម័តកាលយល់ស្រប កាលពី ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១។

គោលបំណងនៃសន្ធិសញ្ញានេះ គឺជម្រុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធភាព រវាងប្រទេសទាំងពីរ ក្នុងការកម្ចាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាពនិងផលប្រយោជន៍ទាំងសងខាងតាមការចុះសន្ធិសញ្ញា។សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសទាំងពីរមាន២២ប្រការ។

**គ.សន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលបានចុះហត្ថលេខានៅទីក្រុងវៀងច័ន្ទ នាថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៩ នឹងត្រូវរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៣ ហើយព្រឹទ្ធសភាបានអនុម័តយល់ស្រប កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១។

គោលបំណងនៃសន្ធិសញ្ញានេះ គឺជម្រុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធភាព រវាងប្រទេសទាំងពីរ ក្នុងការកម្ចាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាពនិងផលប្រយោជន៍ទាំងសងខាង តាមរយៈការចុះសន្ធិសញ្ញាបត្យាប័ន។សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសទាំងពីរមាន២៤ប្រការ។

**ឃ.កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋកូរ៉េ(ខាងត្បូង)**

កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២។

គោលបំណងជម្រុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធភាពរវាងប្រទេសទាំងពីរ ក្នុងការលុបបំបាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពគ្នាទៅវិញទៅមកនូវអធិបតេយ្យភាព សមភាពនិងផលប្រយោជន៍ទាំងសងខាង តាមការចុះកិច្ចព្រមព្រៀងបត្យាប័ន។កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងប្រទេសទាំងពីរមាន២៣មាត្រា។

**ខ.សន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម**

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចុះហត្ថលេខានៅរដ្ឋធានីហាណូយ នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣។

ការចុះសន្ធិសញ្ញានេះមានគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរវាងប្រទេសទាំងពីរក្នុងការបង្ក្រាបបទល្មើស ដោយឈរលើមូលដ្ឋានគោរពអធិបតេយ្យភាពទៅវិញទៅមក សមភាព និងផលប្រយោជន៍រួម តាមរយៈការចុះសន្ធិសញ្ញាបត្យាប័ន។សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសទាំងពីរមាន ២២មាត្រា។

**ច.អនុសញ្ញារវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋបារាំង**

អនុសញ្ញាស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដែលបានចុះហត្ថលេខានៅរដ្ឋធានីប៉ារីសនៃសាធារណរដ្ឋបារាំង នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ នឹងត្រូវរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤។

គោលបំណងនៃអនុសញ្ញានេះ បង្កើតឱ្យមានកិច្ចសហប្រតិបត្តិការ ឱ្យកាន់តែមានប្រសិទ្ធភាពរវាងប្រទេសទាំងពីរក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម។

គោលដៅ ព្រមព្រៀងរួមគ្នា ផ្តល់ដំណោះស្រាយលើទំនាក់ទំនងប្រទេសទាំងពីរ ក្នុងបញ្ហាបត្យាប័នដោយគោរពតាមគោលការណ៍រដ្ឋធម្មនុញ្ញរៀងៗខ្លួន អធិបតេយ្យភាព សមភាពនិងផលប្រយោជន៍គ្នាទៅវិញទៅមក។អនុសញ្ញាស្តីពីបត្យាប័នរវាងប្រទេសទាំងពីរមាន២៥មាត្រា។

**ឆ.សន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី**

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី ដែលបានចុះហត្ថលេខា នៅរដ្ឋធានីមូស្គូ នៃសហព័ន្ធរុស្ស៊ី នាថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ ហើយព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់កាលពីថ្ងៃទី២៩

ខែវិច្ឆិកា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៤។សន្ធិសញ្ញាស្តីពីបត្យាប័នរវាងរដ្ឋទាំងពីរមាន២០មាត្រា។

គោលបំណងនៃសន្ធិសញ្ញារវាងប្រទេសទាំងពីរគឺៈ

- ជួយសម្រួលដល់កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងបទល្មើស ឱ្យមានប្រសិទ្ធភាពរវាងគូភាគី
- ពង្រឹងទំនាក់ទំនងរវាងគូភាគី តាមការចុះហត្ថលេខាលើសន្ធិសញ្ញាបត្យាប័ននេះ
- ឈរលើគោលការណ៍អធិបតេយ្យភាព សមភាពនិងផលប្រយោជន៍ទៅវិញទៅមក។

## ១.២.ករណីមានចែងក្នុងអនុសញ្ញា

អនុសញ្ញា គឺជាលិខិតុបករណ៍អន្តរជាតិដែលមានអត្ថន័យស្រដៀងនឹងសន្ធិសញ្ញានិងកិច្ចព្រមព្រៀងដែរ ប៉ុន្តែតម្រូវឱ្យមានការចូលរួមពីប្រទេសជាច្រើន ឬសហគមន៍អន្តរជាតិទាំងមូល និងបម្រើផលប្រយោជន៍មនុស្សជាតិទាំងមូល។បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញាមួយចំនួនដែលទាក់ទងទៅនឹងវិស័យព្រហ្មទណ្ឌ ហើយក្នុងអនុសញ្ញានោះក៏មានបទប្បញ្ញត្តិពាក់ព័ន្ធក្នុងការធ្វើបត្យាប័នផងដែរ ប៉ុន្តែសម្រាប់ប្រទេសដែលមិនបានចុះសន្ធិសញ្ញាស្តីបត្យាប័នអាចយកអនុសញ្ញាទាំងនោះមកប្រើជាមូលដ្ឋានច្បាប់បាន។ អនុសញ្ញាអន្តរជាតិដែលកម្ពុជាបានចូលជាសមាជិកមានដូចជាៈអនុសញ្ញាអន្តរជាតិស្តីពីការទប់ស្កាត់និងការដាក់ទោសទៅលើឧក្រិដ្ឋកម្មទាំងឡាយប្រឆាំងនឹងបុគ្គលដែលត្រូវការពារជាអន្តរជាតិ រួមទាំងភ្នាក់ងារការទូត ឆ្នាំ១៩៧៣ ,អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងអំពើភេរវកម្ម,អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀន និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៨៨,និងសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌឆ្នាំ២០១០ ជាដើម។

### ក.អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងអំពើភេរវកម្ម

ការអនុម័តឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងអំពើភេរវកម្ម ដែលធ្វើនៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៧ នឹងត្រូវបានរដ្ឋសភាអនុម័ត កាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ ហើយព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២។

គោលបំណងនៃអនុសញ្ញានេះផ្តល់នូវក្របខណ្ឌសម្រាប់ធ្វើកិច្ចសហប្រតិបត្តិការនៅតាមតំបន់ ដើម្បីប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ក្រាបនូវរាល់លក្ខណៈ និងទម្រង់គ្រប់ប្រភេទនៃអំពើភេរវកម្ម និងដើម្បីធ្វើកិច្ចសហ

ប្រតិបត្តិការ ឱ្យកាន់តែខ្លាំងក្លាឡើងក្នុងចំណោមភ្នាក់ងារអនុវត្តច្បាប់ និងអាជ្ញាធរដែលពាក់ព័ន្ធរបស់ភាគីទាំងឡាយក្នុងការប្រឆាំងនឹងអំពើភេរវកម្ម។

អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងអំពើភេរវកម្មមាន២៣មាត្រា នៅក្នុងនោះក៏មានបទប្បញ្ញត្តិពីបត្យាប័នផងដែរ។ផ្អែកតាមមាត្រា១៣នៃអនុសញ្ញានេះ បានបញ្ញត្តិពីបត្យាប័ន ៖

១.ជនល្មើសដែលត្រូវបានចោទប្រកាន់មានវត្តមាន នៅក្នុងដែនដីរបស់ភាគីមួយត្រូវគោរពក្នុងករណីអនុវត្តទៅតាមមាត្រា៧ នៃអនុសញ្ញានេះ ប្រសិនបើភាគីនេះមិនបានធ្វើបត្យាប័នចំពោះជននោះ ដើម្បីដាក់ជូននូវករណីបទល្មើសដោយមិនបង្អែបង្អង់យូរទៅអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណងធ្វើការកាត់ទោស តាមរយៈចំណាត់ការក្តី ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ភាគីនោះ ទោះបីជាគ្មានការលើកលែង និងថាតើបទល្មើសត្រូវបានប្រព្រឹត្ត ឬក៏មិនបានប្រព្រឹត្តនៅក្នុងដែនដីរបស់ខ្លួន។ អាជ្ញាធរទាំងនោះ ត្រូវធ្វើការសំរេចចិត្តរបស់ខ្លួនស្ថិតក្នុងលក្ខណៈដូចគ្នាទៅតាមករណីនៃបទល្មើសណាមួយផ្សេងទៀត មានលក្ខណៈធ្ងន់ធ្ងរដោយផ្អែកទៅតាមច្បាប់ជាតិរបស់ភាគីនោះ។

២.បទល្មើសដែលមានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ត្រូវចាត់ទុកថាបានបញ្ចូលនូវរាល់បទល្មើសទាំងឡាយដែលអាចធ្វើបត្យាប័នបាននៅក្នុងសន្ធិសញ្ញាបត្យាប័នណាមួយ ដែលមានស្រាប់រវាងភាគីទាំងឡាយណាមុនពេលអនុសញ្ញានេះចូលជាធរមាន។ ភាគីទាំងឡាយត្រូវអនុវត្ត ដើម្បីបញ្ចូលបទល្មើសខាងលើ ដែលជាបទល្មើសអាចធ្វើបត្យាប័នបាននូវគ្រប់សន្ធិសញ្ញាបត្យាប័ន ត្រូវបានបញ្ចប់ជាបន្តបន្ទាប់រវាងភាគីទាំងឡាយនោះ។

៣.នៅពេលដែលភាគីមួយធ្វើលក្ខខណ្ឌបត្យាប័ន ដែលមាននៅក្នុងសន្ធិសញ្ញាទទួលនូវការស្នើសុំធ្វើបត្យាប័ន ពីភាគីមួយផ្សេងទៀត ដែលគ្មានសន្ធិសញ្ញាបត្យាប័ន ភាគីដែលត្រូវស្នើសុំពិចារណាទៅលើអនុសញ្ញានេះ ដោយផ្អែកលើច្បាប់សម្រាប់ធ្វើបត្យាប័នចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២នៃអនុសញ្ញានេះ ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន។

**ខ.អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ឆ្នាំ១៩៨៨**

ព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀន ខុសច្បាប់ និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៨៨ ដែលធ្វើនៅទីក្រុងវីយ៉ែននាថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៨៨ នឹងត្រូវរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៣ ហើយព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពី ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១។

វិសាលភាពនៃអនុសញ្ញានេះមាន ៖

១.គោលបំណង ធ្វើយ៉ាងណាដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងភាគីផ្សេងៗឱ្យមានប្រសិទ្ធភាពជាងមុន អាចប្រឆាំងទល់នឹងទ្រង់ទ្រាយផ្សេងៗនៃការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទដែលមានទំហំអន្តរជាតិ។ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របដាច់ខាតតាមអនុសញ្ញា ភាគីត្រូវប្រកាន់យកវិធានការចាំបាច់ រួមមានទាំងវិធានការច្បាប់និង វិធានការរដ្ឋបាលដោយឱ្យវិធានការទាំងនោះចុះសម្រុងនឹងបទបញ្ញត្តិគោលនៃប្រព័ន្ធច្បាប់ក្នុងប្រទេសនីមួយៗ។

២.ភាគីទាំងឡាយត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងនៅក្នុងអនុសញ្ញានេះ ឱ្យចុះសម្រុងជាមួយនឹងគោលការណ៍សមភាព ខាងអធិបតេយ្យ និង គោលការណ៍បូរណភាពដែនដីរបស់រដ្ឋ និងព្រមទាំងជាមួយគោលការណ៍ មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ។

៣.រាល់ភាគីទាំងអស់ មិនត្រូវអនុវត្តនៅលើទឹកដីរបស់ភាគីម្ខាងទៀត នូវដែនសមត្ថកិច្ច និងការបង្កើតមុខងារទាំងឡាយ ដែលជាមុខងារដាច់មុខរបស់អាជ្ញាធរនៃភាគីម្ខាងទៀត តាមច្បាប់ក្នុងប្រទេសរបស់ខ្លួនបានឡើយ។

### គ.សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដែលបានចុះហត្ថលេខានៅកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២។

សមាជិកនៃសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ មកពីបណ្តាប្រទេសដូចជា៖ ប្រទេសប្រ៊ុយណេដារ៉ូសាឡឹម,ព្រះរាជាណាចក្រកម្ពុជា,សាធារណរដ្ឋឥណ្ឌូណេស៊ី,សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ,ម៉ាឡេស៊ី,សហភាពមីយ៉ាន់ម៉ា,សាធារណរដ្ឋហ្វីលីពីន,សាធារណរដ្ឋសឹង្ហបុរី,ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

គោលបំណងនៃសន្ធិសញ្ញានេះ ដើម្បីកែលំអប្រសិទ្ធភាពរបស់អាជ្ញាធរអនុវត្តច្បាប់នៃបណ្តាភាគី ក្នុងការទប់ស្កាត់ ការស៊ើបអង្កេត និង ការចោទប្រកាន់បទល្មើស តាមរយៈកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌមាន៣២មាត្រា។សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ មិនមានការបញ្ជូន

ជនល្មើសពីប្រទេសមួយទៅកាន់ប្រទេសមួយទៀតដូចសន្ធិសញ្ញាបត្យាប័ននោះទេ ប៉ុន្តែសន្ធិសញ្ញានេះមានគោលបំណងជួយសម្រួលដល់ការស៊ើបអង្កេត ការស៊ើបសួរ និងការវិនិច្ឆ័យសេចក្តីឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ដោយសារតែមានភស្តុតាងខ្លះស្ថិតនៅក្នុងប្រទេសដទៃ ពោលគឺស្ថិតក្នុងអធិបតេយ្យភាពនៃរដ្ឋផ្សេង។

ជាងនេះទៀតប្រទេសកម្ពុជាក៏មានច្បាប់ស្តីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌផងដែរ នឹងត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៦។

## ផ្នែកទី២ ការធ្វើបត្យាប័នផ្អែកតាមច្បាប់ ឬករណីមិនមានសន្ធិសញ្ញា

បើយើងពិនិត្យទៅមើលបទប្បញ្ញត្តិមួយចំនួននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏មានចែងពាក់ព័ន្ធទៅនឹងសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិ ត្រង់មាត្រា៥៦៧ សម្រាប់យកមកអនុវត្តក្នុងករណីមានជនបរទេសមកប្រព្រឹត្តបទល្មើសឬចាប់ខ្លួននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។យោងតាមមាត្រា៥៦៧បានបញ្ញត្តិពី បត្យាប័នអាណិកជនបរទេស ដែលត្រូវបានចាប់ខ្លួននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិនៃសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលត្រូវបានទទួលសច្ចាប័នពីប្រទេសកម្ពុជា ក៏ប៉ុន្តែក្នុងករណី គ្មានសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជាទេ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកមកអនុវត្ត លើកលែងតែមានបទបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេងទៀត។

ចំពោះករណីដែលមិនមានសន្ធិសញ្ញាបែបនេះ រដ្ឋទទួលសំណើមិនមានកាតព្វកិច្ចក្នុងប្រគល់ឬបញ្ជូនបុគ្គលនោះតាមការស្នើសុំរបស់រដ្ឋដាក់សំណើនោះទេ ហើយក៏មិនមានន័យថាមិនប្រគល់ឬបញ្ជូនជនណាម្នាក់ដែលគេទាមទារនោះ ទៅឱ្យគ្រប់រដ្ឋដែលគ្មានសន្ធិសញ្ញាឬអនុសញ្ញានោះដែរ គឺមានករណីដែលរដ្ឋទទួលសំណើបានសម្រេចបញ្ជូនបុគ្គលនោះតាមការស្នើសុំរបស់រដ្ឋដាក់សំណើ តាមរយៈការព្រមព្រៀងនិងឆន្ទៈរវាងរដ្ឋទាំងពីរ។ ជារួមការមិនមានសន្ធិសញ្ញាក៏មិនបានន័យថាការធ្វើបត្យាប័នសុទ្ធតែបរាជ័យនោះទេ ហើយក៏មិនប្រាកដថាការធ្វើបត្យាប័នរបស់រដ្ឋមានសន្ធិសញ្ញាសុទ្ធតែជោគជ័យនោះដែរ។

### ២.១.ករណីមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ពិសេស

បើក្រឡេកទៅមើលបទប្បញ្ញត្តិនៃច្បាប់ពិសេសក៏មានបញ្ញត្តិពីនីតិវិធីក្នុងការធ្វើបត្យាប័ន ហើយបទប្បញ្ញត្តិនៃច្បាប់នេះ មានច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ,ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម។

## ក.ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២។

គោលបំណងនៃច្បាប់នេះគឺ បង្ការ ទប់ស្កាត់ប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ត្រួតពិនិត្យរាល់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងធានាការអនុវត្តកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាដែលជាភាគីនៃអនុសញ្ញា និងពិធីសាររបស់អង្គការសហប្រជាជាតិដែលទាក់ទងនឹងគ្រឿងញៀន។

ច្បាប់នេះមានគោលដៅដូចតទៅៈ

- បង្ក្រាបការដាំដុះ ការផលិត ការជួញដូរ ការចរាចរ ការរក្សាទុកនិងការចែកចាយនូវគ្រឿងញៀនខុសច្បាប់
- ទប់ស្កាត់ និងលុបបំបាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- ព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀនចូលក្នុងសង្គមវិញ
- ការពារ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ
- រួមចំណែកការពារសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសុវត្ថិភាពសង្គម។

ច្បាប់នេះមានវិសាលភាព រាល់សកម្មភាពពាក់ព័ន្ធគ្រឿងញៀននៅក្នុងព្រះរាជាណាចក្រកម្ពុជា។នៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបែងចែកជា៩ជំពូក ហើយបទបញ្ញត្តិពីបត្យាប័ននៅក្នុងជំពូកទី៧ក្នុងផ្នែកទី១ ដោយមាត្រា១១១ចែងពី បត្យាប័ននៃអាណិកជនបរទេសលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា "ព្រះរាជាណាចក្រកម្ពុជាអាចយល់ព្រមប្រគល់ដល់រដ្ឋបរទេស នូវអាណិកជនបរទេសដែលស្នាក់នៅដែនដីកម្ពុជា ហើយជាកម្មវត្ថុនៃនីតិវិធីចោទប្រកាន់តាមផ្លូវតុលាការនៅក្នុងរដ្ឋបរទេសនោះ ឬត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារដោយតុលាការនៃរដ្ឋបរទេសនោះ ចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះ"។ ចំពោះមាត្រា១១២បានចែងពី បទប្បញ្ញត្តិគ្រប់គ្រងការធ្វើបត្យាប័នចំពោះបទល្មើសទាក់ទងនឹងគ្រឿងញៀន "បត្យាប័នអាណិកជនបរទេសនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលទាក់ទងនឹងបត្យាប័ន ដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែក្នុងករណីគ្មានសន្ធិសញ្ញា ឬអនុសញ្ញាដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជាទេ លក្ខខណ្ឌនិង

នីតិវិធីនៃបត្យាប័នដែលស្នើសុំដោយរដ្ឋបរទេស ឬដោយព្រះរាជាណាចក្រកម្ពុជាចំពោះរដ្ឋបរទេស ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។រីឯ មាត្រា១១៣បានបញ្ញត្តិពី ការឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយបុគ្គលណាម្នាក់ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃនីតិវិធីបត្យាប័ន អាចត្រូវបានអនុញ្ញាត កាលណាបត្យាប័ននេះមិនទាក់ទងនឹងបទល្មើសនយោបាយទេ ពាក្យសុំឆ្លងកាត់ត្រូវធ្វើតាមផ្លូវទូត និងត្រូវតែមានភ្ជាប់នូវលិខិតបញ្ជាក់ភស្តុតាងថាត្រឹមត្រូវអមជាមួយផង។

**ខ.ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម**

ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២។

គោលបំណងនៃច្បាប់នេះ ដើម្បីផ្តល់បទប្បញ្ញត្តិដាក់ទោសឧក្រិដ្ឋចំពោះការប្រព្រឹត្ត ក្នុងកម្រិតមួយដែលច្បាប់នេះមិនមានចែង ចំពោះបញ្ហាទាំងឡាយសម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មនិងច្បាប់ដ៏ទៃទៀត ហើយផ្តល់ជាយន្តការតាមការកំណត់របស់អនុសញ្ញា ពិធីសារ សេចក្តីសម្រេច និងអនុសាសន៍។

ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្មបែងចែកជា១៣ជំពូកនិង១១១មាត្រា ដោយជំពូកទី១២ផ្នែកទី២បានបញ្ញត្តិពីបត្យាប័ន។បទប្បញ្ញត្តិស្តីពីបត្យាប័ននៅក្នុងច្បាប់នេះមាន៩មាត្រា ចាប់ពីមាត្រា៩៤ដល់មាត្រា១០២។

គោលដៅនៃជំពូកទី១២ក្នុងផ្នែកទី២ គឺជានីតិវិធីក្នុងការធ្វើបត្យាប័នទៅកាន់ឬមកពីរដ្ឋបរទេសដែលប្រទេសកម្ពុជាមានសន្ធិសញ្ញាបត្យាប័នជាមួយ និងករណីប្រទេសកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយ ប៉ុន្តែជាភាគីក្នុងអនុសញ្ញាឬពិធីសារពាក់ព័ន្ធ និងការរៀបចំឯកសារ,មូលហេតុចាំបាច់សម្រាប់បដិសេធ,បច្ច័យនៃការបដិសេធ,បត្យាប័នដោយស្ម័គ្រចិត្ត,ការចាប់ខ្លួននិងការឃុំខ្លួនបណ្តោះអាសន្ន។

**២.២.ការអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ**

ការធ្វើបត្យាប័នអាចធ្វើឡើងតាមរយៈឆន្ទៈរបស់រដ្ឋទទួលសំណើឬការព្រមព្រៀងរវាងរដ្ឋនឹងរដ្ឋផ្អែកតាមសន្ធិសញ្ញាបត្យាប័ន ក៏ប៉ុន្តែគ្មានគោលការណ៍ណាមួយហាមឃាត់មិនឱ្យរដ្ឋដែលគ្មានសន្ធិសញ្ញាស្តីពីបត្យាប័នមិនអាចធ្វើបត្យាប័នបាននោះឡើយ។ម្យ៉ាងទៀត ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏មានបញ្ញត្តិអំពីលក្ខខណ្ឌនិងនីតិវិធីក្នុងការធ្វើបត្យាប័ន នៅក្នុងជំពូកទី២នៃគន្ថីទី៩ដែលជានីតិវិធីដោយឡែក។បទប្បញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងទាក់ទងនឹងនីតិវិធីក្នុងការធ្វើបត្យាប័នសម្រាប់ព្រះរាជាណាចក្រកម្ពុជាជាការធានានូវនីត្យានុកូលភាពនិងនិយតភាពក្នុងការធ្វើបត្យាប័ន។

ដូចនេះការធ្វើបត្យាប័នរបស់រដ្ឋបរទេសដែលមិនមានសន្ធិសញ្ញាជាមួយកម្ពុជា ក្នុងករណីជនល្មើសបានមកស្នាក់នៅក្នុងប្រទេសកម្ពុជា អាចធ្វើទៅបានដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ប៉ុន្តែករណីរដ្ឋបរទេសបានស្នើសុំធ្វើបត្យាប័នជនល្មើសដែលជាពលរដ្ឋរបស់កម្ពុជា គឺមិនអាចធ្វើបត្យាប័នបានទេ ទោះបីក្នុងករណីរដ្ឋបរទេសនោះបានចុះសន្ធិសញ្ញាជាមួយកម្ពុជាក្តី។

សម្រាប់លក្ខខណ្ឌក្នុងការធ្វើបត្យាប័នមានៈលក្ខខណ្ឌពាក់ព័ន្ធនឹងបទល្មើស,លក្ខខណ្ឌពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស,លក្ខខណ្ឌពាក់ព័ន្ធនឹងទោសពន្ធនាគារ និងលក្ខខណ្ឌពាក់ព័ន្ធនឹងពាក្យសុំ។រីឯលក្ខខណ្ឌដែលមិនអាចធ្វើបត្យាប័នបានមានៈលក្ខខណ្ឌពាក់ព័ន្ធនឹងអំពើ(នយោបាយ),ការរលត់បណ្តឹងអាជ្ញា និងលក្ខខណ្ឌពាក់ព័ន្ធនឹងការជំនុំជម្រះនិងទស្សនៈវិស័យមនុស្សធម៌។

## ២.២.១.លក្ខខណ្ឌសម្រាប់ធ្វើបត្យាប័ន

### ក.លក្ខខណ្ឌពាក់ព័ន្ធនឹងបទល្មើស

បត្យាប័ន ជានីតិវិធីមួយក្នុងការបញ្ជូនឬប្រគល់ជនល្មើស ដែលបទល្មើសជាធាតុផ្សំសំខាន់ក្នុងការធ្វើបត្យាប័ន ដើម្បីធ្វើបត្យាប័នបានលុះត្រាតែបទល្មើសនោះមានចែងក្នុងច្បាប់របស់ប្រទេសធ្វើសំណើនិងប្រទេសទទួលសំណើផងដែរ។

បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះជាបទល្មើសតាមច្បាប់របស់រដ្ឋធ្វើសំណើផង និងតាមច្បាប់កម្ពុជាផង ទោះបីជា ៖

- អំពើដែលជាបទល្មើស ស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នា ឬ
- ឈ្មោះបទល្មើស ការប្រើបច្ចេកស័ព្ទ ឬនិយមន័យឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នាក្តី ឬ
- ធាតុផ្សំបទល្មើសនៃច្បាប់របស់រដ្ឋធ្វើសំណើ ខុសគ្នាពីធាតុផ្សំបទល្មើសដែលកំណត់ដោយច្បាប់កម្ពុជាក៏ដោយ ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋធ្វើសំណើគឺជាការប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមាននៅកម្ពុជា។[៩]

ចំពោះអំពើដែលត្រូវចោទប្រកាន់ មានលក្ខណៈនយោបាយ នឹងមិនអនុញ្ញាតឱ្យធ្វើបត្យាប័នទេ ក៏ប៉ុន្តែនៅក្នុងមាត្រា៥៧៣នៃក្រមនីតិវិធីព្រហ្មទណ្ឌមិនបានពន្យល់ថាអំពើដែលមានលក្ខណៈនយោបាយជាអំពើបែប

[៩]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៥៦៩

ណានោះទេ គ្រាន់តែបញ្ជាក់ប្រាប់ថាអំពើហិង្សាដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិត ដល់បូរណភាពខាងរូបកាយ ឬដល់សេរីភាពរបស់បុគ្គល មិនមែនជាបទល្មើសនយោបាយនោះទេ។

ដូចនេះបត្យាប័នអាចធ្វើទៅបានលុះត្រាតែបទល្មើសនោះមានចែងក្នុងច្បាប់របស់រដ្ឋទាំងពីរ ដើម្បីធ្វើការចោទប្រកាន់បុគ្គលដែលគេទាមទារ ទោះបីជាប្រភេទបទល្មើស ឬឈ្មោះបទល្មើស ការប្រើបច្ចេកស័ព្ទឬនិយមន័យឬការកំណត់លក្ខណៈបទល្មើស មិនដូចគ្នាក្តី ឬធាតុផ្សំបទល្មើសដែលកំណត់ដោយច្បាប់របស់ប្រទេសទាំងពីរខុសគ្នាក៏ដោយក៏អាចធ្វើបត្យាប័នបាន ប៉ុន្តែក្នុងករណីបទល្មើសមានលក្ខណៈនយោបាយមិនអនុញ្ញាតក្នុងការធ្វើបត្យាប័ននោះទេ។

**ខ.លក្ខខណ្ឌពាក់ព័ន្ធនឹងទោសពន្ធនាគារ**

បត្យាប័នអាចធ្វើបាន លុះត្រាតែអំពើដែលត្រូវចោទប្រកាន់ទៅលើបុគ្គលដែលគេទាមទារនោះមានកម្រិតអតិបរមានៃទោសពន្ធនាគារយ៉ាងតិចស្មើនឹង ២ (ពីរ) ឆ្នាំ តាមច្បាប់នៃរដ្ឋធ្វើសំណើ។ ប៉ុន្តែបត្យាប័នក៏អាចធ្វើបានដែរ ប្រសិនបើបុគ្គលដែលគេទាមទារនោះ ត្រូវបានតុលាការនៃរដ្ឋធ្វើសំណើផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចបំផុតស្មើនឹង ៦ (ប្រាំមួយ) ខែ ហើយសេចក្តីសម្រេចផ្តន្ទាទោសនេះបានចូលជាស្ថាពររួចហើយ ទោះបីជាទោសដែលកំណត់ដោយច្បាប់មានថិរវេលាប៉ុន្មានក៏ដោយ។[៦]

ចំណែកនៅក្នុងសន្ធិសញ្ញារវាងកម្ពុជានិងថៃ ក៏បានបញ្ញត្តិពី "បទល្មើសដែលអាចធ្វើបត្យាប័នបាន "ជាបទល្មើស ដែលអាចផ្តន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរដោយការដាក់ពន្ធនាគារ ឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំងសម្រាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬការផ្តន្ទាទោសណាមួយដែលធ្ងន់ជាងនេះ។[៧]

ឧទាហរណ៍៖ លោក ជូ មានសញ្ជាតិថៃ បានប្រព្រឹត្តបទល្មើសនៅប្រទេសថៃរួចរត់មកស្នាក់នៅប្រទេសកម្ពុជា។តាមច្បាប់ប្រទេសថៃត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំទៅ៣ឆ្នាំ។ក្រោយពីតុលាការប្រទេសថៃ បានជំនុំជម្រះផ្តន្ទាទោស លោក ជូ ដាក់ពន្ធនាគារចំនួន២ឆ្នាំ ហើយសេចក្តីសម្រេចនេះបានចូលជាស្ថាពរ។ដូចនេះព្រះរាជាណាចក្រកម្ពុជា អាចធ្វើបត្យាប័នបញ្ជូនលោកជូ ទៅឱ្យប្រទេសថៃបាន ក្នុងករណីមានការស្នើសុំ។

[៦] មាត្រា៥៧១នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[៧] ប្រការទី១ កថាខណ្ឌទី១នៃសន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជាជាមួយប្រទេសថៃ អនុម័តនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩

**គ.លក្ខខណ្ឌពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស**

ក្រមនីតិវិធីព្រហ្មទណ្ឌ ពុំមានបញ្ញត្តិចែងច្បាស់ពីការបដិសេធមិនធ្វើបត្យាប័នពលរដ្ឋខ្មែរនោះទេ ក៏ប៉ុន្តែតាមរយៈខ្លឹមសារនៃបទប្បញ្ញត្តិមួយចំនួនអាចបកស្រាយបានថា ការធ្វើបត្យាប័នពលរដ្ឋខ្មែរឱ្យទៅប្រទេសដទៃមិនអាចធ្វើបានទេ។

ជាធម្មតា រដ្ឋនីមួយៗពុំដែលធ្វើបត្យាប័នបញ្ជូនពលរដ្ឋសាមីរបស់ខ្លួន ឱ្យទៅអាជ្ញាធរនៃប្រទេសផ្សេងយកទៅវិនិច្ឆ័យសេចក្តី ឬអនុវត្តទោសនោះទេ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិជាក់លាក់ណាមួយបញ្ញត្តិផ្សេងពីនេះ។[៨]

ព្រះរាជាណាចក្រកម្ពុជាអាចយល់ព្រមប្រគល់ដល់រដ្ឋបរទេស នូវអាណិកជនបរទេសដែលស្នាក់នៅលើដែនដីកម្ពុជា ហើយដែល ៖

- ជាកម្មវត្ថុនៃនីតិវិធីចោទប្រកាន់តាមផ្លូវតុលាការនៅក្នុងរដ្ឋនេះ ឬ
- ត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារដោយតុលាការនៃរដ្ឋនេះ។[៩]

កាលណាអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ ត្រូវបានប្រព្រឹត្តនៅលើដែនដីនៃរដ្ឋធ្វើសំណើ បត្យាប័នក៏អាចធ្វើបានដែរ ទោះបីជាបុគ្គលដែលគេទាមទារមិនមានសញ្ជាតិរបស់រដ្ឋធ្វើសំណើក៏ដោយ។ កាលណាអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃរដ្ឋធ្វើសំណើ បត្យាប័នអាចនឹងត្រូវធ្វើបាន លុះត្រាតែបុគ្គលដែលគេទាមទារនោះមានសញ្ជាតិរបស់រដ្ឋធ្វើសំណើ។[១០]

សរុបមក បត្យាប័នអាចធ្វើទៅបានលុះត្រាតែបុគ្គលនោះបានប្រព្រឹត្តបទល្មើសហើយទោសដែលត្រូវទទួលជាទោសដាក់ពន្ធនាគារ។ មិនតែប៉ុណ្ណោះការធ្វើបត្យាប័នរបស់រដ្ឋដាក់សំណើអាចធ្វើឡើងក្នុងករណីបុគ្គលនោះជាពលរដ្ឋរបស់ខ្លួនហើយបានប្រព្រឹត្តបទល្មើសនៅក្រៅដែនដីនៃរដ្ឋទាំងពីរ ឬបានប្រព្រឹត្តបទល្មើសនៅក្នុងរដ្ឋទទួលសំណើ ឬជនល្មើសនោះមិនមែនជាពលរដ្ឋរបស់រដ្ឋធ្វើសំណើនិងរដ្ឋទទួលសំណើទេប៉ុន្តែបុគ្គលដែលគេទាមទារបានប្រព្រឹត្តបទល្មើសនៅក្នុងដែនដីនៃរដ្ឋដាក់សំណើហើយរត់មកស្នាក់នៅក្នុងរដ្ឋទទួលសំណើ។ សម្រាប់ករណីដែលមិនអាចធ្វើបត្យាប័នបាន គឺជាការស្នើសុំធ្វើបត្យាប័នជនល្មើសដែលមានសញ្ជាតិនៃរដ្ឋទទួលសំណើ ទោះបីបុគ្គលនោះបានប្រព្រឹត្តបទល្មើសក្នុងដែនដីនៃរដ្ឋដាក់សំណើក៏ដោយ ក៏មិនអាចធ្វើបត្យាប័នបានដែរ ប៉ុន្តែមិនមានន័យថាបុគ្គលនោះរួចខ្លួនពីការផ្តន្ទាទោសនោះទេ គ្រាន់តែផ្លាស់ប្តូរដែនសមត្ថកិច្ចនៃការជំនុំ

[៨] ដកស្រង់ចេញពីសៀវភៅសិក្សានីតិវិធីព្រហ្មទណ្ឌទូទៅ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ,ទំព័រទី១៥២

[៩] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៥៦៦

[១០]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៥៧២

ជម្រះតែប៉ុណ្ណោះ ដោយឱ្យរដ្ឋធ្វើសំណើបញ្ជូនឯកសារ ភស្តុតាងនិងសំណុំរឿងមកកាន់រដ្ឋទទួលសំណើ ដើម្បីអាជ្ញាធរនៃរដ្ឋសាមីធ្វើការចោទប្រកាន់ ឬជំនុំជម្រះនិងផ្តន្ទាទោសបុគ្គលនោះតាមផ្លូវច្បាប់។

ឧទាហរណ៍៖ អាជ្ញាធរនៃប្រទេសកម្ពុជាបានធ្វើសំណើសុំបត្យាប័នលើលោក យ៉ាវ ដែលមានសញ្ជាតិវៀតណាម ដោយសារលោក យ៉ាវ បានប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសកម្ពុជា។ករណីនេះការធ្វើបត្យាប័នលោក យ៉ាវ ទៅកាន់ប្រទេសកម្ពុជាអាចត្រូវបានអនុញ្ញាត យោងតាមមាត្រា៥៧២ វាក្យខណ្ឌទី១នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

អាជ្ញាធរនៃប្រទេសវៀតណាមបានធ្វើសំណើសុំបត្យាប័នលោក យ៉ាវ ដែលមានសញ្ជាតិវៀតណាម ដោយសារលោកយ៉ាវបានប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសកម្ពុជា ដើម្បីយកទៅធ្វើការចោទប្រកាន់ ឬជំនុំជម្រះនៅមុខយុត្តាធិការទៅតាមច្បាប់ជាតិនៃរដ្ឋធ្វើសំណើ។យោងតាមមាត្រា៥៧២វាក្យខណ្ឌទី២នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅក្នុងករណីនេះការធ្វើបត្យាប័នលោក យ៉ាវ ទៅកាន់ប្រទេសវៀតណាមអាចត្រូវបានអនុញ្ញាត។

**ឃ.លក្ខខណ្ឌពាក់ព័ន្ធនឹងពាក្យសុំ**

បត្យាប័នអាចធ្វើបាន លុះត្រាតែរដ្ឋធ្វើសំណើនោះសន្យាថា មិនធ្វើការចោទប្រកាន់ពីបទល្មើសណាមួយផ្សេងក្រៅពីបទល្មើសដែលមានចែងនៅក្នុងពាក្យស្នើសុំឱ្យធ្វើបត្យាប័ននោះទេ ហើយកាលណាបទល្មើសនោះបានប្រព្រឹត្តមុនពេលចាប់ខ្លួនបុគ្គលដែលគេទាមទារ។ប៉ុន្តែការចោទប្រកាន់អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមព្រះរាជាណាចក្រកម្ពុជា។ក្នុងករណីនេះ រដ្ឋធ្វើសំណើត្រូវជូនពាក្យស្នើសុំបន្ថែមមកអាជ្ញាធរកម្ពុជា។[១១]

ឧទាហរណ៍៖លោក ក (ជាជនជាតិឡាវ) គាត់បានប្រព្រឹត្តបទល្មើសនៅប្រទេសថៃ រួចមកស្នាក់នៅប្រទេសកម្ពុជា។ប្រទេសថៃបានស្នើសុំធ្វើបត្យាប័នបុគ្គលនោះពីប្រទេសកម្ពុជា ដោយចោទពីបទឆបោក។ ករណីមានការបន្ថែមបទចោទប្រកាន់ថ្មីពីសំណាក់ប្រទេសថៃ ដោយចោទលោក (ក) ពីបទលួច សម្រាប់ករណីនេះមិនអាចធ្វើការចោទប្រកាន់បន្ថែមបានទេ ដើម្បីអាចធ្វើការចោទប្រកាន់បន្ថែមបានទាល់តែមានការយល់ព្រមពី ព្រះរាជាណាចក្រកម្ពុជា និងត្រូវជូនពាក្យស្នើសុំបន្ថែមមកអាជ្ញាធរកម្ពុជា។

សម្រាប់ករណីមានរដ្ឋបរទេសជាច្រើនបានសុំបត្យាប័ន ផ្អែកតាមមាត្រា៥៧៦នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងពី"ពាក្យសុំធ្វើបត្យាប័នជាច្រើនទាក់ទងនឹងបុគ្គលតែម្នាក់" កាលណាមានរដ្ឋបរទេសច្រើនបានសុំបត្យាប័នលើបុគ្គលតែម្នាក់ដូចគ្នា ដើម្បីអាចធ្វើបត្យាប័នបានរដ្ឋទទួលសំណើនិងពិចារណាគ្រប់ស្ថានភាពដូចជា៖ កាតព្វកិច្ចសន្ធិសញ្ញាពាក់ព័ន្ធ,ភាពធ្ងន់ធ្ងរនៃបទល្មើស,ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តបទល្មើស,កាលបរិច្ឆេទ និងលំដាប់មកដល់នៃសំណើសុំ,សញ្ជាតិ លំនៅឋាន ទីសំណាក់នៃបុគ្គលដែលគេទាមទារ និងជនរងគ្រោះ,លទ្ធភាពប្រគល់មកវិញនូវបុគ្គលដែលគេទាមទាររបស់រដ្ឋធ្វើសំណើ។

[១១] មាត្រា៥៧៧នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

### ២.២.២.លក្ខខណ្ឌមិនអាចធ្វើបត្យាប័ន

ផ្អែកតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រជាពលរដ្ឋខ្មែរនឹងមិនត្រូវបានចាប់បញ្ជូនទៅកាន់រដ្ឋបរទេសនោះទេ ទោះបីជាបុគ្គលនោះបានប្រព្រឹត្តបទល្មើសនៅលើដែនដីនៃរដ្ឋបរទេសក៏ដោយ ក៏មិនអាចធ្វើបត្យាប័នបុគ្គលនោះឱ្យរដ្ឋបរទេសដែរ។នៅក្នុងករណីដែលពលរដ្ឋកម្ពុជាបានប្រព្រឹត្តបទល្មើសនៅលើរដ្ឋបរទេសហើយរត់ទៅរដ្ឋផ្សេង កម្ពុជាអាចស្នើសុំធ្វើបត្យាប័នបុគ្គលនោះដើម្បីធ្វើការចោទប្រកាន់ ឬអនុវត្តទោសតាមច្បាប់ជាតិ។ម្យ៉ាងទៀត កម្ពុជាអាចស្នើសុំភស្តុតាងពីរដ្ឋបរទេសដើម្បីដំណើរការនីតិវិធីរបស់ខ្លួន។

មិនតែប៉ុណ្ណោះ ការដែលមិនធ្វើបត្យាប័នជនណាម្នាក់ឱ្យទៅរដ្ឋបរទេសអាចមកពីច្បាប់របស់ប្រទេសនីមួយៗមិនដូចគ្នា ឬអាចមកពីស្ថានភាពក្នុងការផ្តន្ទាទោសរបស់រដ្ឋបរទេសមានសភាពធ្ងន់ធ្ងរដែលប៉ះពាល់ដល់វិស័យមនុស្សធម៌។សម្រាប់ករណីខាងលើបុគ្គលដែលគេទាមទារនោះមិនបានរួចខ្លួនពីការផ្តន្ទាទោសនោះទេ គឺត្រូវផ្តន្ទាទោសតាមច្បាប់របស់កម្ពុជា។

ឧទាហរណ៍៖លោក ច ដែលជាជនជាតិខ្មែរបានទៅប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសអង់គ្លេស ហើយបានរត់មកកាន់ប្រទេសកម្ពុជា បន្ទាប់មកប្រទេសអង់គ្លេសបានស្នើសុំធ្វើបត្យាប័នលោក ច ពីប្រទេសកម្ពុជា។ សម្រាប់ច្បាប់របស់អង់គ្លេសដែលត្រូវយកមកអនុវត្តលើលោក ច គឺជាទោសប្រហារជីវិត ប៉ុន្តែកម្ពុជាអាចបដិសេធមិនធ្វើបត្យាប័នពលរដ្ឋរបស់ខ្លួនទៅឱ្យរដ្ឋបរទេសបាន ដោយស្នើសុំយកបុគ្គលនោះមកផ្តន្ទាទោសតាមច្បាប់ជាតិ ហើយស្នើសុំឱ្យប្រទេសអង់គ្លេសបញ្ជូនឯកសារភស្តុតាងមកកម្ពុជា ដើម្បីរៀបចំដំណើរការនីតិវិធីទៅលើលោក ច តាមផ្លូវច្បាប់របស់កម្ពុជា។

#### ក.លក្ខខណ្ឌពាក់ព័ន្ធនឹងអំពើ

បត្យាប័នមិនអាចធ្វើបានទេ កាលណាអំពើដែលត្រូវចោទប្រកាន់មានលក្ខណៈនយោបាយ។ប៉ុន្តែចំពោះអំពើហិង្សាដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិត ដល់បូរណភាពខាងរូបកាយ ឬដល់សេរីភាពរបស់បុគ្គលមិនត្រូវបានចាត់ទុកជាបទល្មើសនយោបាយទេ។[១២]

#### ខ.លក្ខខណ្ឌពាក់ព័ន្ធនឹងការជំនុំជម្រះ

គោលការណ៍មិនជំនុំជម្រះពីរដងលើរឿងតែមួយ គឺជាគោលការណ៍ដ៏សំខាន់មួយនៅក្នុងរឿងព្រហ្មទណ្ឌ ហើយត្រូវបានទទួលស្គាល់យ៉ាងជាក់ច្បាស់ដោយមាត្រា១៤កថាខណ្ឌទី៧នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦ ដែលបានចែងថា យោងទៅតាមទម្រង់ការច្បាប់ព្រហ្មទណ្ឌនៃ

[១២] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៥៧៣

ប្រទេសនីមួយៗ គេមិនអាចយកជនណាម្នាក់ទៅកាត់ទោសសាជាថ្មី ចំពោះបទល្មើសដែលសាមីជនបានទទួលទណ្ឌកម្ម ឬបានទទួលការលើកលែងទោសរួចទៅហើយទេ។[១៣]

សម្រាប់ការអនុវត្តគោលការណ៍នេះក៏ត្រូវបានទាញចេញពីការបកស្រាយនៃបទប្បញ្ញត្តិស្តីពីអាជ្ញាអស់ជំនុំក្នុងមាត្រា១២នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិស្តីពីការមិនចោទប្រកាន់ត្រួតគ្នានិងទោសនៃមាត្រា២៣នៃក្រមព្រហ្មទណ្ឌផងដែរ។

បត្យាប័នមិនអាចធ្វើបានទេ កាលណាអំពើដែលត្រូវចោទប្រកាន់បានប្រព្រឹត្តនៅលើដែនដីកម្ពុជាហើយត្រូវបានជំនុំជម្រះជាស្ថាពររួចហើយនៅកម្ពុជា។[១៤]

ជាការសមហេតុផលហើយថា ប្រសិនបើប្រទេសកម្ពុជាដែលជារដ្ឋទទួលសំណើបានជំនុំជម្រះជាស្ថាពរលើបទល្មើស ដែលជាកម្មវត្ថុនៃសំណើបត្យាប័ននោះគឺមានន័យថា អំពើរបស់បុគ្គលដែលគេទាមទារត្រូវបានតុលាការធ្វើការវិនិច្ឆ័យរួចទៅហើយ ដូច្នេះសំណើសុំធ្វើបត្យាប័នក៏មិនមានអត្ថន័យអ្វីទៀតដែរ។ ម្យ៉ាងវិញទៀតប្រសិនបើប្រទេសកម្ពុជាយល់ព្រមធ្វើបត្យាប័នបុគ្គលនេះទៅឱ្យរដ្ឋធ្វើសំណើនោះគឺបានសេចក្តីថានឹងអនុញ្ញាតឱ្យមានការជំនុំជម្រះជាលើកទីពីរចំពោះអំពើដែលត្រូវបានវិនិច្ឆ័យដោយតុលាការកម្ពុជារួចទៅហើយ។[១៥]

ឧទាហរណ៍៖អ្នកស្រី ក (ថៃ) បានប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសកម្ពុជា ហើយតុលាការកម្ពុជាបានជំនុំជម្រះជាស្ថាពររួច បន្ទាប់មកប្រទេសថៃបានស្នើសុំធ្វើបត្យាប័នអ្នកស្រី ក។នៅក្នុងករណីនេះកម្ពុជាមិនអាចធ្វើបត្យាប័នបានទេ ពីព្រោះតុលាការរបស់ប្រទេសកម្ពុជាបានធ្វើការវិនិច្ឆ័យរួចរាល់លើបទល្មើសដែលជាកម្មវត្ថុនៃសំណើសុំបត្យាប័ន។

**គ.លក្ខខណ្ឌពាក់ព័ន្ធនឹងការរលត់បណ្តឹងអាជ្ញា**

មូលហេតុនៃការរលត់បណ្តឹងអាជ្ញាដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមាន៖

យោងតាមមាត្រា៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងពីការរលត់បណ្តឹងអាជ្ញាមានដូចតទៅ៖

- មរណភាពនៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ

[១៣] ដកស្រង់ពីសៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ,ទំព័រទី៧៦

[១៤]មាត្រា៥៧៤នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[១៥]ដកស្រង់ពីសៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ,ទំព័រទី១៥៤

- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ។

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេឬត្រូវតែបញ្ឈប់។

ផ្អែកតាមមាត្រា៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិពីមូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញាបន្ថែមពីលើមាត្រា៧ ៖

- ការសម្របសម្រួលជាមួយរដ្ឋ
- ការដកពាក្យប្តឹង នៅក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ
- ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។

បត្យាប័នមិនអាចធ្វើបានទេ នៅក្នុងករណីដែលបណ្តឹងអាជ្ញាបានផុតរលត់តាមច្បាប់របស់រដ្ឋធ្វើសំណើ។ កាលណាអំពើដែលត្រូវចោទប្រកាន់បានប្រព្រឹត្តនៅលើដែនដីកម្ពុជា បត្យាប័នមិនអាចធ្វើបានទេ នៅក្នុងករណីដែលបណ្តឹងអាជ្ញាត្រូវបានផុតរលត់តាមច្បាប់កម្ពុជា។[១៦]

ឧទាហរណ៍៖លោក ស ជាជនជាតិកូរ៉េ បានប្រព្រឹត្តបទល្មើសនៅប្រទេសបារាំងរួចរត់មកស្នាក់នៅក្នុងដែនដីនៃប្រទេសកម្ពុជា។ក្រោយមកប្រទេសបារាំងបានដាក់សំណើសុំធ្វើបត្យាប័នបុគ្គលនោះ ក៏ប៉ុន្តែប្រទេសកម្ពុជាបានពិនិត្យឃើញថា តាមច្បាប់របស់ប្រទេសបារាំងអាជ្ញាយុកាលនៃបទល្មើសបានផុតរលត់។ដូចនេះ ប្រទេសកម្ពុជាមិនអាចធ្វើបត្យាប័នបានទេ ទោះបីនៅក្នុងច្បាប់របស់ប្រទេសកម្ពុជាអាជ្ញាយុកាលនៃបទល្មើសមិនទាន់ផុតរលត់ក៏ដោយ។បន្ទាប់មកប្រទេសកូរ៉េបានដាក់សំណើសុំធ្វើបត្យាប័នបុគ្គលនោះដែលជាពលរដ្ឋរបស់ខ្លួនដោយពិនិត្យឃើញថាច្បាប់របស់ខ្លួនមិនទាន់ផុតរលត់នៃអាជ្ញាយុកាលនៃបទល្មើស។ផ្ទុយមកវិញបែបជាច្បាប់របស់ប្រទេសកម្ពុជាអាជ្ញាយុកាលនៃបទល្មើសបានផុតរលត់ ដែលជាហេតុធ្វើឱ្យប្រទេសកម្ពុជាមិនអាចធ្វើបត្យាប័នលោក ស បានដែរ ទោះបីតាមច្បាប់ប្រទេសកូរ៉េមិនទាន់ផុតរលុតអាជ្ញាយុកាលនៃបទល្មើសក៏ដោយ។

[១៦] មាត្រា៥៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

# ជំពូកទី៣
# នីតិវិធីក្នុងការធ្វើបត្យាប័ន

# ជំពូកទី៣
# នីតិវិធីក្នុងការធ្វើបត្យាប័ន

នីតិវិធីនៃការធ្វើបត្យាប័ន គឺធ្វើឡើងតាមការព្រមព្រៀងរវាងរដ្ឋពីរ ឬច្រើន និងស្ថិតក្រោមនីតិអន្តរជាតិ ប៉ុន្តែក៏ត្រូវស្របតាមច្បាប់របស់រដ្ឋដែលជាគូភាគីនៃសន្ធិសញ្ញាផងដែរ។សម្រាប់ការធ្វើបត្យាប័នរបស់ប្រទេសកម្ពុជា ក្នុងករណីមានសន្ធិសញ្ញាស្តីពីបត្យាប័ន គឺអនុវត្តទៅតាមកិច្ចព្រមព្រៀងរវាងគូភាគីដែលបានចុះរួមគ្នា។

ចំពោះករណីប្រទេសកម្ពុជាមិនបានចុះសន្ធិសញ្ញាទ្វេភាគីឬពហុភាគីជាមួយរដ្ឋបរទេស ក៏ព្រះរាជាណាចក្រកម្ពុជា អាចស្នើសុំធ្វើបត្យាប័នបាន ដោយផ្អែកតាមបត្យាប័នគំរូរបស់អង្គការសហប្រជាជាតិពីព្រោះប្រទេសកម្ពុជាក៏ជាសមាជិកនៃអង្គការសហប្រជាជាតិ។

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមិនទាន់មានច្បាប់ស្តីពីបត្យាប័ននោះទេ ប៉ុន្តែនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្មជាដើម មានបទប្បញ្ញត្តិពាក់ព័ន្ធនឹងបត្យាប័ន។

ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងយ៉ាងជាក់លាក់អំពីការចាប់ផ្តើមនីតិវិធីបត្យាប័ននៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែយើងអាចសន្និដ្ឋានបានថានីតិវិធីនេះប្រាកដជាចាប់ផ្តើមពីការដាក់ពាក្យសុំធ្វើបត្យាប័ន និងការបញ្ជូនពាក្យសុំតាមផ្លូវទូត។

## ផ្នែកទី១ នីតិវិធីនៃការដាក់សំណើរបស់ព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាអាចជារដ្ឋដាក់សំណើ ក្នុងករណីដែលកម្ពុជាបានស្នើសុំឱ្យរដ្ឋបរទេសបញ្ជូនជនណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសនៅក្នុងដែនដីនៃប្រទេសកម្ពុជាហើយរត់ទៅជ្រកកោននៅរដ្ឋទទួលសំណើ ឬករណីជននោះជាជនជាតិកម្ពុជាដែលបានប្រព្រឹត្តបទល្មើសនៅក្នុងដែនដីនៃរដ្ឋបរទេសប៉ុន្តែបានរត់គេចទៅប្រទេសមួយទៀត។

ចំពោះការដើរតួជារដ្ឋធ្វើសំណើ កម្ពុជាត្រូវបំពេញតាមលក្ខខណ្ឌក្នុងធ្វើបត្យាប័នដែលមានចែងក្នុងសន្ធិសញ្ញា និងច្បាប់ជាតិរបស់រដ្ឋទទួលសំណើ។ករណីរដ្ឋទទួលសំណើយល់ព្រមក្នុងការធ្វើបត្យាប័នបុគ្គលដែលកម្ពុជាទាមទារនោះ រដ្ឋទទួលសំណើនឹងបញ្ជូនបុគ្គលនោះមកឱ្យព្រះរាជាណាចក្រកម្ពុជា។សម្រាប់ករណីមានសន្ធិសញ្ញាស្តីពីបត្យាប័ននោះ ការអនុវត្តនីតិវិធីនៃការធ្វើបត្យាប័នត្រូវអនុលោមតាមសន្ធិសញ្ញារវាងគូភាគីដែលបានចុះរួមគ្នា។

## ១.១.ការដាក់ពាក្យសុំធ្វើបត្យាប័ន

ចំពោះនីតិវិធីក្នុងការដាក់សំណើបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជាទៅកាន់រដ្ឋបរទេសត្រូវអនុវត្តតាមកិច្ចព្រមព្រៀងរបស់គូភាគីទាំងពីរ។ក្នុងករណីព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើទៅកាន់ សាធារណរដ្ឋសង្គមនិយមវៀតណាម។

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាមក៏បញ្ញត្តិពីនីតិវិធីបត្យាប័ន និងឯកសារចាំបាច់ដែលត្រូវភ្ជាប់ជាមួយ៖

១.សំណើសុំធ្វើបត្យាប័នត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនតាមរយៈអាជ្ញាធរកណ្តាលរបស់គូភាគី។ ក្នុងករណីចាំបាច់ គូភាគីអាចធ្វើការទំនាក់ទំនងគ្នាតាមរយៈបណ្តាញការទូត។រាល់ឯកសារភ្ជាប់ជាមួយពាក្យសុំធ្វើបត្យាប័ន ត្រូវទទួលស្គាល់ថាត្រឹមត្រូវស្របតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០ នៃសន្ធិសញ្ញានេះ។ពាក្យសុំធ្វើបត្យាប័ន និងឯកសារភ្ជាប់ជាមួយ ត្រូវផ្តល់ចំនួន៣ (បី) ច្បាប់។ សេចក្តីចម្លងមិនទាមទារឱ្យបញ្ជាក់នីត្យានុកូលកម្មឡើយ។ពាក្យសុំធ្វើបត្យាប័នត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

ក.លិខិតអធិប្បាយអំពីអង្គហេតុនៃសំណុំរឿង ដែលជាកម្មវត្ថុនៃសំណើសុំធ្វើបត្យាប័ន ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែងប្រព្រឹត្តបទល្មើស និងឈ្មោះបទល្មើស

ខ.លិខិតពិពណ៌នាអំពីរូបរាងរបស់បុគ្គល ដែលជាកម្មវត្ថុនៃសំណើសុំធ្វើបត្យាប័ន និងព័ត៌មានពាក់ព័ន្ធដែលអាចបញ្ជាក់ពីអត្តសញ្ញាណ សញ្ជាតិ ហើយប្រសិនបើអាចទីកន្លែងរបស់បុគ្គលដែលគេទាមទារនោះ

គ.រាល់បទប្បញ្ញត្តិនៃច្បាប់ដែលកំណត់អំពីធាតុផ្សំសំខាន់ៗ និងឈ្មោះនៃបទល្មើស ដែលជាកម្មវត្ថុនៃការស្នើសុំធ្វើបត្យាប័ន និងទោសចំពោះបទល្មើស

ឃ.រាល់បទប្បញ្ញត្តិនៃច្បាប់ដែលចែងអំពីអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ឬអាជ្ញាយុកាលនៃទោសចំពោះបទល្មើសនោះ ប្រសិនបើមាន។

២.សំណើសុំធ្វើបត្យាប័នដែលទាក់ទងនឹងបុគ្គលដែលគេទាមទារ ដើម្បីចោទប្រកាន់ត្រូវភ្ជាប់បន្ថែមមកជាមួយនូវ ៖

ក.ដីកាចាប់ខ្លួនច្បាប់ដើម និងសេចក្តីចម្លងដីកាចាប់ខ្លួនចំនួន ២ (ពីរ) ច្បាប់ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីធ្វើសំណើ និង

ខ.លិខិតអធិប្បាយដែលអាចបកស្រាយបានសម្រាប់ការចាប់ខ្លួន និងការឃុំខ្លួនដើម្បីរង់ចាំការជំនុំជម្រះលើបុគ្គលនោះ ដោយរួមទាំងលិខិតអធិប្បាយដែលបញ្ជាក់ថាបុគ្គលដែលត្រូវគេទាមទារ ពិតជាបុគ្គលដែលកំណត់ក្នុងដីកាចាប់ខ្លួនមែន។

៣.កាលណាសំណើសុំធ្វើបត្យាប័នទាក់ទងទៅនឹងបុគ្គល ដែលត្រូវបានផ្តន្ទាទោសរួចហើយ ក្រៅពីឯកសារធ្វើសំណើដែលបានកំណត់ក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវភ្ជាប់បន្ថែមមកជាមួយនូវ ៖

ក.សាលក្រម ឬសាលដីកាចុងក្រោយច្បាប់ដើម និងសេចក្តីចម្លងនៃសាលក្រមឬសាលដីកាចុងក្រោយចំនួន ២ (ពីរ) ច្បាប់ ដែលផ្តន្ទាទោសដោយតុលាការនៃភាគីធ្វើសំណើ

ខ.លិខិតអធិប្បាយដែលបញ្ជាក់ថាបុគ្គលដែលគេទាមទារ គឺពិតជាបុគ្គលដែលកំណត់ក្នុងសាលក្រម ឬសាលដីកានោះមែន

គ.លិខិតអធិប្បាយអំពីពេលវេលាដែលបានអនុវត្តទោសរួចហើយ និង

ឃ.លិខិតអធិប្បាយអំពីមធ្យោបាយតាមផ្លូវច្បាប់ដែលមានស្រាប់ ដើម្បីបុគ្គលនេះរៀបចំបណ្តឹងឧបាស្រ័យ ឬបណ្តឹងសើរើដោយមានវត្តមានរបស់បុគ្គលនេះ ប្រសិនបើបុគ្គលនោះត្រូវបានផ្តន្ទាទោសដោយកំបាំងមុខ។

៤.រាល់ឯកសារទាំងអស់អមជាមួយសំណើសុំធ្វើបត្យាប័ន ត្រូវភ្ជាប់ជាមួយនូវអត្ថបទបកប្រែជាភាសាផ្លូវការរបស់ភាគីទទួលសំណើ។[១៧]

ចំពោះការបញ្ជូនសំណើសុំធ្វើបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម ត្រូវអនុលោមតាមមាត្រា៧នៃសន្ធិសញ្ញាបត្យាប័នរវាងប្រទេសទាំងពីរ។ក្នុងករណីភាគីផ្លាស់ប្តូរអាជ្ញាធរកណ្តាលរបស់ខ្លួន ត្រូវជូនព័ត៌មានអំពីការផ្លាស់ប្តូរទៅឱ្យភាគីម្ខាងទៀតតាមរយៈបណ្តាញការទូត។

ក្រោយពីសំណើសុំធ្វើបត្យាប័នបានមកដល់រដ្ឋទទួលសំណើ និងធ្វើការត្រួតពិនិត្យនិយតភាពលើពាក្យសុំធ្វើបត្យាប័នដែលកម្ពុជាដាក់ស្នើ ប៉ុន្តែការសម្រេចលើពាក្យសុំគឺអាស្រ័យលើសន្ធិសញ្ញានិងច្បាប់របស់រដ្ឋទទួលសំណើ។

ក្នុងករណីមានសំណើសុំធ្វើបត្យាប័នដែលធ្វើឡើងដោយរដ្ឋច្រើនលើបុគ្គលតែម្នាក់ ហើយក្នុងរដ្ឋដាក់សំណើក៏មានប្រទេសកម្ពុជាផងដែរ ដែលបានស្នើសុំឱ្យប្រទេសវៀតណាមបញ្ជូនជនល្មើសនោះមកកាន់ប្រទេសកម្ពុជា។ដូចនេះរដ្ឋទទួលសំណើត្រូវយកកិច្ចព្រមព្រៀងដែលគូភាគីបានចុះរួមគ្នាមកអនុវត្តដើម្បីធ្វើការសម្រេចក្នុងការធ្វើបត្យាប័នបុគ្គលនោះឱ្យរដ្ឋមួយណា។

[១៧] មាត្រា៨នៃសន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជាជាមួយប្រទេសវៀតណាម អនុម័តនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤

ផ្អែកតាមមាត្រា១៣នៃសន្ធិសញ្ញាស្តីបត្យាប័នរវាងកម្ពុជានិងវៀតណាម បានបញ្ញត្តិពី "សំណើសុំធ្វើបត្យាប័នធ្វើឡើងដោយរដ្ឋច្រើន"

១.នៅក្នុងករណីដែលសំណើត្រូវបានទទួលពីរដ្ឋពីរ ឬច្រើនសម្រាប់ការធ្វើបត្យាប័នបុគ្គលដដែល ភាគីទទួលសំណើត្រូវកំណត់ថាតើត្រូវធ្វើបត្យាប័នបុគ្គលនោះទៅឱ្យរដ្ឋណាមួយក្នុងចំណោមរដ្ឋទាំងនោះ ហើយត្រូវតែជូនដំណឹងទៅភាគីផ្ញើសំណើពីការសម្រេចចិត្តរបស់ខ្លួន។

២.ការកំណត់រដ្ឋណាមួយដែលបុគ្គលនោះត្រូវធ្វើបត្យាប័ន ភាគីទទួលសំណើត្រូវពឹងផ្អែកលើលក្ខខណ្ឌផ្សេងៗ ជាពិសេសគឺ ៖

ក.ប្រសិនបើមានសំណើពាក់ព័ន្ធនឹងបទល្មើសច្រើនផ្សេងៗគ្នា ភាពធ្ងន់ធ្ងរនៃបណ្តាបទល្មើស

ខ.ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តបទល្មើសនីមួយៗ

គ.កាលបរិច្ឆេទនៃសំណើសុំធ្វើបត្យាប័ន

ឃ.សញ្ជាតិរបស់បុគ្គលដែលត្រូវធ្វើបត្យាប័ន

ង.ទីលំនៅរបស់បុគ្គលដែលត្រូវធ្វើបត្យាប័ន និង

ច.លទ្ធភាពនៃការធ្វើបត្យាប័នទៅរដ្ឋណាមួយក្នុងចំណោមបណ្តារដ្ឋផ្ញើសំណើ។

ក្នុងករណីខាងលើ ប្រសិនបើភាគីវៀតណាម សម្រេចធ្វើបត្យាប័នបុគ្គលនោះមកឱ្យប្រទេសកម្ពុជា ក៏ប៉ុន្តែព័ត៌មានដែលភ្ជាប់មកជាមួយសំណើសុំមិនទាន់គ្រប់គ្រាន់ សម្រាប់អនុវត្តនីតិវិធីធ្វើបត្យាប័នតាមសន្ធិសញ្ញានេះ ភាគីនោះអាចស្នើសុំផ្តល់ព័ត៌មានបន្ថែម នៅក្នុងអំឡុងពេលសមស្របដែលបានកំណត់ដោយភាគីវៀតណាម ។ចំពោះការបញ្ជូនឯកសារដែលខ្វះខាតពីភាគីកម្ពុជា មកកាន់ភាគីវៀតណាមត្រូវតែស្ថិតក្នុងអំឡុងពេលដែលកំណត់។ក្នុងករណីប្រទេសកម្ពុជាមិនបានបញ្ជូនឯកសារឱ្យបានគ្រប់គ្រាន់ក្នុងថិរវេលាដែលបានកំណត់ទេនោះ មានន័យថាភាគីកម្ពុជាលះបង់សិទ្ធិក្នុងការធ្វើបត្យាប័ន ក៏ប៉ុន្តែបើកម្ពុជាបានបញ្ជូនព័ត៌មានដែលខ្វះខាត មកកាន់ប្រទេសវៀតណាមក្នុងថិរវេលាដែលបានកំណត់ហើយនោះ ការធ្វើបត្យាប័ននឹងកើតមានឡើង។

## ១.២.ការដាក់ពាក្យសុំចាប់ខ្លួនបណ្តោះអាសន្ន

ក្នុងករណីនេះព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិស្នើសុំចាប់ខ្លួនបណ្តោះអាសន្នចំពោះបុគ្គលដែលកម្ពុជាបានទាមទារ ក្នុងគោលដៅរារាំងនៃការរត់គេចរបស់ជននោះ។

បើក្រឡេកទៅមើលសន្ធិសញ្ញាស្តីពីបត្យាប័នរវាងកម្ពុជានិងវៀតណាម ត្រង់មាត្រា១២ ក៏បានបញ្ញត្តិពី "ការចាប់ខ្លួនបណ្តោះអាសន្ន"ដូចជា៖

១.ក្នុងករណីបន្ទាន់ អាជ្ញាធរមានសមត្ថកិច្ចនៃភាគីធ្វើសំណើអាចស្នើសុំទៅភាគីម្ខាងទៀតឱ្យធ្វើការចាប់ខ្លួនបណ្តោះអាសន្ននូវបុគ្គលដែលគេទាមទារ មុនការស្នើសុំធ្វើបត្យាប័នជាផ្លូវការដែលត្រូវធ្វើឡើងតាមរយៈអាជ្ញាធរកណ្តាល។

សំណើសុំចាប់ខ្លួនបណ្តោះអាសន្នត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលសំណើ តាមរយៈបណ្តាញការទូត ឬតាមរយៈអង្គភាពនគរបាលឧក្រិដ្ឋកម្មអន្តរជាតិ (អាំងទែរប៉ូល) ឬបញ្ជូនតាមមធ្យោបាយណាមួយ រួមទាំងប្រព័ន្ធអេឡិចត្រូនិចដែលទទួលស្គាល់ទៅវិញទៅមកដោយគូភាគី។

២.សំណើសុំខាងលើរួមមាន៖

ក.លិខិតអធិប្បាយអំពីមូលហេតុនៃការធ្វើសំណើជាបន្ទាន់

ខ.ការពិពណ៌នាអំពីបុគ្គលដែលគេទាមទារ រួមមានរូបថត និងស្នាមម្រាមដៃប្រសិនបើអាចធ្វើទៅបាន

គ.ទីកន្លែងដែលបុគ្គលនោះស្ថិតនៅ ប្រសិនបើដឹង

ឃ.លិខិតអធិប្បាយអំពីអង្គហេតុនៃបទល្មើសដែលបុគ្គលនោះបានប្រព្រឹត្ត

ង.រាល់បទប្បញ្ញត្តិនៃច្បាប់ដែលកំណត់អំពីធាតុផ្សំសំខាន់ៗ និងឈ្មោះនៃបទល្មើសដែលជាកម្មវត្ថុនៃការស្នើសុំចាប់ខ្លួនបណ្តោះអាសន្ន និងទោសចំពោះបទល្មើស

ច.ដីកាចាប់ខ្លួន ឬសាលក្រម ឬសាលដីកាចុងក្រោយផ្តន្ទាទោសចំពោះបុគ្គលដែលគេទាមទារ

ឆ.លិខិតអធិប្បាយអំពីទោសដែលអាច ឬត្រូវផ្តន្ទាទោសចំពោះបទល្មើស និង

ញ.សេចក្តីបញ្ជាក់យ៉ាងច្បាស់លាស់ថា សំណើសុំធ្វើបត្យាប័នលើបុគ្គលដែលគេទាមទារ នឹងត្រូវបញ្ជូនតាមក្រោយ។

៣.នៅពេលទទួលបានលិខិតស្នើសុំនោះ ប្រសិនបើស្របច្បាប់ជាតិរបស់ខ្លួន ភាគីទទួលសំណើត្រូវចាត់វិធានការចាំបាច់ក្នុងការចាប់ខ្លួនបុគ្គលដែលគេទាមទារ ហើយភាគីធ្វើសំណើត្រូវបានគេផ្តល់ដំណឹងដោយគ្មានការយឺតយ៉ាវអំពីលទ្ធផលនៃការស្នើសុំរបស់ខ្លួន។

៤.បុគ្គលដែលត្រូវចាប់ខ្លួនតាមការស្នើសុំនឹងត្រូវបានដោះលែង ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ ចាប់ពីថ្ងៃដែលបុគ្គលនោះត្រូវបានចាប់ខ្លួន ប្រសិនបើភាគីទទួលសំណើពុំបានទទួលសំណើសុំធ្វើបត្យាប័ន និងរាល់ឯកសារចាំបាច់ភ្ជាប់មកជាមួយដូចដែលបានចែងក្នុងមាត្រា ៨ នៃសន្ធិសញ្ញានេះ។

៥.ការដោះលែងបុគ្គលដែលត្រូវបានចាប់ខ្លួនបណ្ដោះអាសន្ន យោងតាមកថាខណ្ឌទី៤នៃមាត្រានេះ មិនរារាំងដល់ការធ្វើបត្យាប័នបុគ្គលដែលគេទាមទារនោះទេ ប្រសិនបើសំណើសុំធ្វើបត្យាប័នត្រូវបានទទួលនៅពេលក្រោយ។

## ១.៣.ការចូលទៅបង្ហាញខ្លួននៅជំណាក់កាលសភាស៊ើបសួរ

ចំពោះការពិនិត្យ និងការសម្រេចលើពាក្យសុំធ្វើបត្យាប័នដែលស្នើដោយប្រទេសកម្ពុជា គឺអាស្រ័យទៅលើសន្ធិសញ្ញាអន្តរជាតិ និងច្បាប់ជាតិរបស់រដ្ឋដែលបានទទួលសំណើពីប្រទេសកម្ពុជា។

នៅពេលដែលរដ្ឋទទួលសំណើ បានយល់ព្រមធ្វើបត្យាប័នបុគ្គលដែលបានទាមទារនោះមកឱ្យកម្ពុជា បុគ្គលនោះនឹងត្រូវបញ្ជូនមកកាន់ប្រទេសកម្ពុជាវិញ។ បុគ្គលដែលត្រូវបានធ្វើបត្យាប័ន មានសិទ្ធិក្នុងការដាក់ពាក្យសុំមោឃភាពនៃបត្យាប័ន ទៅកាន់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ចិរវេលាសម្រាប់ការដាក់ពាក្យបណ្ដឹងនេះមានរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃសាមីខ្លួនមកដល់ប្រទេសកម្ពុជា។

បុគ្គលនោះត្រូវតែទៅបង្ហាញខ្លួននៅចំពោះមុខសភាស៊ើបសួរ ដើម្បីឱ្យសភាស៊ើបសួរធ្វើការសម្រេចក្រោយពីបានស្ដាប់ចម្លើយរបស់បុគ្គលដែលត្រូវបានធ្វើបត្យាប័ន សេចក្ដីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្ដីសន្និដ្ឋានការពាររបស់មេធាវី។

ចំពោះនីតិវិធីនៅចំពោះមុខសភាស៊ើបសួរត្រូវបានបញ្ចប់ ហើយសភាស៊ើបសួរបានចេញសេចក្ដីសម្រេចជាស្ថាពរ ដោយឱ្យបុគ្គលដែលត្រូវបានធ្វើបត្យាប័ន ត្រូវដោះលែងឱ្យមានសេរីភាពវិញ និងមានលទ្ធភាពចាកចេញដោយសេរីពីដែនដីកម្ពុជា។ ប៉ុន្តែក្រោយពីផុតរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលត្រូវបានដោះលែងឱ្យមានសេរីភាពបុគ្គលដែលត្រូវបានធ្វើបត្យាប័ន អាចត្រូវបានចាប់ខ្លួនម្ដងទៀតនៅលើដែនដីកម្ពុជា និងត្រូវជាកម្មវត្ថុនៃនីតិវិធីចោទប្រកាន់ជាថ្មីចំពោះអំពើដែលនាំឱ្យមានការធ្វើបត្យាប័នបុគ្គលនេះបាន។

## ១.៤.ការអនុវត្តក្នុងអំឡុងពេលផ្ដល់បត្យាប័ន

សម្រាប់អំឡុងពេលផ្ដល់បត្យាប័ន គូភាគីនៃកិច្ចព្រមព្រៀងត្រូវអនុវត្តតាមការព្រមព្រៀងដែលចែងក្នុងសន្ធិសញ្ញាស្ដីពីបត្យាប័នរវាងរដ្ឋទាំងពីរ ដើម្បីទទួលបានប្រសិទ្ធភាពនិងភាពរលូនក្នុងការអនុវត្តបត្យាប័ន។

ចំពោះការចេញចំណាយលើនីតិវិធីក្រោយផ្ដល់បត្យាប័នគឺផ្អែកតាមការកំណត់ពីការចំណាយដែលមានចែងក្នុងសន្ធិសញ្ញារវាងគូភាគី ដើម្បីយកមកអនុវត្តក្នុងដែនសមត្ថកិច្ចរបស់រដ្ឋនីមួយៗដែលពាក់ព័ន្ធនិងការធ្វើបត្យាប័ន ។យោងតាមមាត្រា២០នៃសន្ធិសញ្ញាស្ដីបត្យាប័នរវាងកម្ពុជានិងវៀតណាម បានបញ្ញត្តិពីការចំណាយ" ការធ្វើបត្យាប័ននៅលើដែនដីរបស់ភាគីទទួលសំណើ ជាបន្ទុករបស់ភាគីទទួលសំណើរហូតដល់ការប្រគល់ខ្លួនបុគ្គលនោះ។រីឯការឆ្លងកាត់នៅលើដែនដីរបស់ភាគីទទួលសំណើជាបន្ទុករបស់ភាគី ធ្វើសំណើ។

ម្យ៉ាងទៀត ភាគីធ្វើសំណើត្រូវទទួលខុសត្រូវរាល់ការចំណាយ ដែលកើតឡើងក្នុងការដឹកជញ្ជូនបុគ្គលនោះពីដែនដីរបស់ភាគីទទួលសំណើ ។មិនតែប៉ុណ្ណោះ គូភាគីត្រូវពិគ្រោះយោបល់គ្នាដើម្បីកំណត់អត្ថន័យ និងលក្ខខណ្ឌ ប្រសិនបើមានការចំណាយពិសេសណាមួយ។"

ការអនុវត្តក្រោយពីការផ្តល់បត្យាប័នគឺការប្រគល់ជនដែលត្រូវស្នើសុំ និងការប្រគល់ទ្រព្យសម្បត្តិ។

**ក.ការប្រគល់ជនដែលត្រូវស្នើសុំ**

ក្នុងករណីព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីស្នើសុំបញ្ជូនបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជារួច រត់គេចទៅប្រទេសវៀតណាម ឬ បុគ្គលដែលព្រះរាជាណាចក្រកម្ពុជាស្នើសុំបានប្រព្រឹត្តបទល្មើសនៅក្នុងដែនដីនៃប្រទេសវៀតណាម ការស្នើសុំធ្វើបត្យាប័នក្នុងករណីនេះដោយសារបុគ្គលដែលកម្ពុជាស្នើសុំមានសញ្ជាតិខ្មែរ។

ផ្អែកតាមមាត្រា១៤នៃសន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជាជាមួយប្រទេសវៀតណាមបានបញ្ញត្តិពី"ការប្រគល់ខ្លួន"ថា៖

១.ភាគីទទួលសំណើត្រូវជូនព័ត៌មានឱ្យភាគីសំណើ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន អំពីការសម្រេចរបស់ខ្លួនលើសំណើសុំបត្យាប័ន។

២.ក្នុងករណីបត្យាប័នត្រូវបានផ្តល់ឱ្យ ភាគីទទួលសំណើត្រូវប្រគល់បុគ្គលដែលគេទាមទារ ចេញពីចំណុចចាកចេញពីក្នុងដែនដីដែលគូភាគីបានព្រមព្រៀងគ្នា។

៣.គូភាគីត្រូវពិគ្រោះយោបល់គ្នា ដើម្បីកំណត់កាលបរិច្ឆេទ និងទីកន្លែងនៃការបញ្ជូនខ្លួនបុគ្គលដែលត្រូវធ្វើបត្យាប័ន។ភាគីទទួលសំណើត្រូវជូនព័ត៌មានទៅភាគីធ្វើសំណើ អំពីថិរវេលានៃការឃុំខ្លួនបុគ្គលដែលត្រូវធ្វើបត្យាប័ន នៅលើដែនដីរបស់ភាគីទទួលសំណើ ប្រសិនបើមានការឃុំខ្លួននៅក្នុងដែនដីនៃភាគីទទួលសំណើ។

៤.ភាគីធ្វើសំណើត្រូវមកទទួលយកបុគ្គល ដែលស្នើសុំពីដែនដីនៃភាគីទទួលសំណើក្នុងរយៈពេលសមរម្យ តាមការកំណត់របស់ភាគីទទួលយកក្នុងពេលកំណត់នោះទេ ភាគីទទួលសំណើអាចបដិសេធការធ្វើបត្យាប័នបុគ្គលនោះចំពោះបទល្មើសដដែល។

៥.ប្រសិនបើមានហេតុការណ៍ណាមួយកើតឡើង ដែលហួសពីលទ្ធភាពគ្រប់គ្រងរបស់គូភាគី រារាំងដល់ការប្រគល់ ឬទទួលបុគ្គលដែលស្នើសុំធ្វើបត្យាប័ននោះ ភាគីត្រូវជូនព័ត៌មានទៅភាគីម្ខាងទៀត។ គូភាគីត្រូវពិភាក្សាគ្នា ដើម្បីកំណត់កាលបរិច្ឆេទថ្មីសម្រាប់ប្រគល់ខ្លួនបុគ្គលដែលស្នើសុំ ហើយបទប្បញ្ញត្តិក្នុងកថាខណ្ឌទី ៤ នៃមាត្រានេះ ត្រូវអនុវត្តផងដែរ។

**ខ.ការប្រគល់ទ្រព្យសម្បត្តិ**

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជានឹងប្រទេសវៀតណាម ត្រង់មាត្រា១៥បានបញ្ញត្តិពី“ការប្រគល់នូវទ្រព្យសម្បត្តិ” ថា៖

១.នៅក្នុងក្របខណ្ឌនៃច្បាប់របស់ភាគីទទួលសំណើដែលបានអនុញ្ញាត និងឈរលើមូលដ្ឋាននៃការគោរពសិទ្ធិរបស់តតិយជន គ្រប់ទ្រព្យសម្បត្តិដែលជាផលនៃបទល្មើស ឬដែលអាចធ្វើជាវត្ថុតាង ហើយដែលបានរកឃើញលើដែនដីនៃភាគីទទួលសំណើនឹងត្រូវបញ្ជូនតាមសំណើរបស់ភាគីធ្វើសំណើ ប្រសិនបើសំណើសុំធ្វើបត្យាប័នត្រូវបានផ្តល់ឱ្យ។

២.យោងតាមកថាខណ្ឌទី១ នៃមាត្រានេះ ទ្រព្យសម្បត្តិនឹងត្រូវបញ្ជូនទៅភាគីធ្វើសំណើប្រសិនបើភាគីធ្វើសំណើបានស្នើសុំ ទោះបីជាការធ្វើបត្យាប័នមិនអាចអនុវត្តបានដោយមូលហេតុបុគ្គលដែលគេទាមទារបានទទួលមរណភាព បាត់ខ្លួន ឬរត់គេចខ្លួន។

៣.នៅពេលដែលច្បាប់នៃភាគីទទួលសំណើបញ្ញត្តិ ឬដើម្បីសិទ្ធិរបស់តតិយជន ទ្រព្យសម្បត្តិទាំងអស់ដែលត្រូវបានបញ្ជូនត្រូវសងមកភាគីទទួលសំណើវិញ ដោយគ្មានការបង់ប្រាក់សោហ៊ុយ ប្រសិនបើភាគីទទួលសំណើបានស្នើសុំ។

៤.ក្នុងករណីទ្រព្យសម្បត្តិខាងលើ ជាទ្រព្យដែលត្រូវការចាំបាច់សម្រាប់បម្រើឱ្យការស៊ើបអង្កេត ឬចោទប្រកាន់ ឬជំនុំជម្រះបទល្មើសនៅលើដែនដីនៃភាគីទទួលសំណើ ការបញ្ជូនទ្រព្យសម្បត្តិនោះអាចពន្យាររហូតដល់ការស៊ើបអង្កេត ការចោទប្រកាន់ ឬការជំនុំជម្រះត្រូវបញ្ចប់ ឬអាចបញ្ជូនដោយមានលក្ខខណ្ឌថានឹងត្រូវប្រគល់មកវិញបន្ទាប់ពីបញ្ចប់នីតិវិធីរបស់ភាគីធ្វើសំណើ។

## ផ្នែកទី២ នីតិវិធីនៃការទទួលសំណើរបស់ព្រះរាជាណាចក្រកម្ពុជា

ក្នុងករណីព្រះរាជាណាចក្រកម្ពុជាដើរតួជារដ្ឋទទួលសំណើ សម្រាប់នីតិវិធីបត្យាប័នគឺចាប់ផ្តើមពីការទទួលពាក្យស្នើសុំពីសំណាក់រដ្ឋបរទេសតាមរយៈស្ថានទូត និងបញ្ចប់នីតិវិធិដោយការប្រគល់ឬបញ្ជូនបុគ្គលដែលគេទាមទារ ទៅឱ្យអាជ្ញាធររបស់រដ្ឋដាក់សំណើ ដើម្បីធ្វើការចោទប្រកាន់ ឬជំនុំជម្រះ និងផ្តន្ទាទោសតាមផ្លូវច្បាប់។

ក្រោយពីបំពេញតាមលក្ខខណ្ឌក្នុងការធ្វើបត្យាប័នរួចរាល់ រដ្ឋបរទេសដែលជារដ្ឋដាក់សំណើត្រូវចាប់ផ្តើមដំណើរការក្នុងការធ្វើបត្យាប័ន។ ចំពោះនីតិវិធីក្នុងការធ្វើបត្យាប័នរបស់ព្រះរាជាណាចក្រកម្ពុជា ទោះបីជាប្រទេសកម្ពុជាដើរតួជារដ្ឋដាក់សំណើ ឬរដ្ឋទទួលសំណើក្តី ក៏នីតិវិធីសម្រាប់ធ្វើបត្យាប័នមិនមានការប្រែប្រួល

ដែរ គ្រាន់តែផ្លាស់ប្តូរតួនាទីតែប៉ុណ្ណោះ។ម្យ៉ាងទៀត សម្រាប់នីតិវិធីក្នុងការទទួលសំណើគឺត្រូវអនុលោមតាមសន្ធិសញ្ញា ដែលគូភាគីបានព្រមព្រៀងគ្នា ប៉ុន្តែករណីរដ្ឋបរទេសគ្មានសន្ធិសញ្ញាស្តីបត្យាប័នជាមួយកម្ពុជាទេនោះ នីតិវិធីត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិនៃច្បាប់ពិសេស។

## ២.១.ការទទួលពាក្យសុំធ្វើបត្យាប័នតាមរយៈក្រសួងការបរទេស

ចំពោះនីតិវិធីក្នុងការដាក់សំណើសុំបត្យាប័នរបស់រដ្ឋបរទេសមកកាន់ព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យរដ្ឋបរទេសបញ្ជូនពាក្យស្នើសុំតាមរយៈស្ថានទូតបរទេសដែលប្រចាំនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

គ្រប់ពាក្យសុំធ្វើបត្យាប័នត្រូវតែបញ្ជូនទៅរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ពាក្យសុំនេះត្រូវមានលិខិតបញ្ជាក់ភស្តុតាងអមជាមួយផង រួមមាន៖

- ✓ ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ
- ✓ របាយការណ៍អំពីអង្គហេតុដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ
- ✓ អត្ថបទច្បាប់ដែលអនុវត្តទៅលើអំពើនោះ និងទោសដែលត្រូវទទួលរង
- ✓ លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន។

ឯកសារទាំងអស់ត្រូវចុះហត្ថលេខា បោះត្រាជាផ្លូវការ និងបិទស្រោម ហើយប្រសិនបើមិនមែនជាភាសាខ្មែរ បារាំង ឬអង់គ្លេស ត្រូវតែភ្ជាប់មកជាមួយនូវឯកសារបកប្រែ ជាភាសាមួយនៃភាសាទាំងបីនេះដោយមានសេចក្តីបញ្ជាក់ផង។[១៨]

នៅពេលលក្ខខណ្ឌសម្រាប់នីតិវិធីពាក់ព័ន្ធនឹងពាក្យសុំចប់សព្វគ្រប់អស់ហើយ រដ្ឋផ្ញើសំណើត្រូវដាក់ពាក្យសុំធ្វើបត្យាប័នមកកាន់ប្រទេសកម្ពុជាតាមរយៈផ្លូវទូត ដោយនៅក្នុងពាក្យសុំនេះត្រូវភ្ជាប់មកជាមួយឯកសារចំនួន៤ ដែលមានចែងក្នុងមាត្រា៥៧៩នៃក្រមនីតិវិធីព្រហ្មទណ្ឌៈទី១ជាឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ,ទី២ ជារបាយការណ៍អំពីអង្គហេតុដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ,ទី៣ ជាអត្ថបទច្បាប់ដែលអនុវត្តទៅលើអំពើនោះ និងទោសដែលត្រូវទទួលរង,ទី៤ ជាលិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន។ចំពោះឯកសារទី៤ ជាប្រភេទឯកសារសម្រេចផ្តន្ទាទោសបុគ្គលដែលគេទាមទារ។សម្រាប់ករណីខ្លះបុគ្គលនោះមិនទាន់សម្រេចផ្តន្ទាទោសនោះទេ ទើបតែរៀបចំដំណើរការនីតិវិធីនៃការចោទប្រកាន់ ដូចនេះឯកសារទី៤ ពេលខ្លះមិនចាំបាច់ភ្ជាប់មកជាមួយក៏បាន។ពេលដែលរៀបចំឯកសារបានគ្រប់គ្រាន់អស់ហើយ ឯកសារទាំងអស់ត្រូវមានចុះហត្ថលេខា បោះត្រាជាផ្លូវការនិងមានបិទស្រោមសម្រាប់ភាសាដែលត្រូវប្រើប្រាស់នៅក្នុងការធ្វើបត្យាប័នមាន ភាសាខ្មែរ ភាសាបារាំង និងភាសាអង់គ្លេស ករណី

[១៨] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៥៧៩

ឯកសារទាំងនោះមិនមានភាសាណាមួយក្នុងចំណោមភាសាទាំងបី ត្រូវភ្ជាប់មកជាមួយការបកប្រែដែលមានការបញ្ជាក់អមមកជាមួយ។

បន្ទាប់ពីទទួលបានពាក្យសុំធ្វើបត្យាប័នរួច រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា ត្រូវបញ្ជូនពាក្យសុំធ្វើបត្យាប័ន និងលិខិតបញ្ជាក់ភស្តុតាងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្ទៀងផ្ទាត់មើលនិយតភាពនៃពាក្យសុំ និងបញ្ជូនពាក្យសុំនោះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។

## ២.២.ការទទួលពាក្យស្នើសុំចាប់បុគ្គលដែលគេទាមទារ

សម្រាប់ការចាប់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្នដែលធ្វើឡើងរវាងរដ្ឋបរទេសជាមួយកម្ពុជាក្នុងករណីមានសន្ធិសញ្ញាស្តីពីបត្យាប័ន នោះនីតិវិធីក្នុងការចាប់ខ្លួនត្រូវអនុលោមតាមបទប្បញ្ញត្តិដែលមានចែងក្នុងសន្ធិសញ្ញានេះ។ចំពោះករណីរដ្ឋធ្វើសំណើមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយកម្ពុជានោះទេ នីតិវិធីនេះត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិពិសេសនៃច្បាប់ពិសេស។បើក្រឡេកទៅមើលមាត្រា១០១នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ក៏បញ្ញត្តិពីការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្ន ផងដែរ។

រដ្ឋធ្វើសំណើឱ្យធ្វើបត្យាប័ន អាចសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន នូវបុគ្គលដែលគេទាមទារបាន។ក្នុងករណីបន្ទាន់ពាក្យសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន អាចធ្វើមុនពាក្យសុំឱ្យធ្វើបត្យាប័នដែលមានចែងនៅក្នុងមាត្រា ៥៧៩ (ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន) នៃក្រមនេះ។

ពាក្យសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន ដែលមានគោលដៅរារាំងការគេចខ្លួនបុគ្គលដែលគេទាមទារមិនតម្រូវឱ្យគោរពទម្រង់បែបបទដោយឡែកឡើយ។បុគ្គលដែលត្រូវស្ថិតនៅក្រោមនីតិវិធីនៃការចាប់ខ្លួនបណ្តោះអាសន្ន ត្រូវតែបានដោះលែងឱ្យមានសេរីភាពឡើងវិញដោយឯកឯង ប្រសិនបើរាជរដ្ឋាភិបាលពុំបានទទួលឯកសារទាំងឡាយដូចដែលមានចែងនៅក្នុងមាត្រា ៥៧៩នៃក្រមនេះក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចាប់ខ្លួន ទេនោះ។[១៩]

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នៅភ្នំពេញអាចចេញបញ្ជាឱ្យចាប់ និងឃុំខ្លួនបុគ្គលដែលគេទាមទារ។ បញ្ជានេះមានចុះនិទ្ទេសដូចតទៅ ៖

- អត្តសញ្ញានៃបុគ្គលដែលគេទាមទារ
- ការយោងនៃពាក្យសុំឱ្យចាប់ខ្លួនជាបណ្តោះអាសន្នរបស់រដ្ឋបរទេស

[១៩] មាត្រា៥៨១នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

➢ ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញបញ្ជានេះ។

បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយអគ្គព្រះរាជអាជ្ញា និងមានបោះត្រាផង។បញ្ជាឱ្យចាប់ និងឃុំខ្លួនមានអានុភាពអនុវត្តនៅលើដែនដីកម្ពុជាទាំងមូល។[២០]

មិនតែប៉ុណ្ណោះ ក្នុងករណីចាប់ខ្លួនបុគ្គលដែលគេទាមទារ ត្រូវតែនាំទៅបង្ហាញខ្លួនក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី ដែលត្រូវឱ្យដំណឹងដល់បុគ្គលនោះ អំពីបញ្ជាឱ្យចាប់និងឃុំខ្លួន ហើយនិងទទួលចម្លើយពីបុគ្គលនេះ។មួយវិញទៀត បុគ្គលដែលគេទាមទារត្រូវផ្ទេរមកឃុំខ្លួននៅពន្ធនាគារភ្នំពេញ។បុគ្គលនោះ អាចសុំឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញស្តាប់ចម្លើយខ្លួន។

ចំពោះបុគ្គលដែលគេទាមទារ អាចសុំឱ្យគេដោះលែងឱ្យនៅក្រៅឃុំបាន។ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយពាក្យសុំត្រូវដាក់ជូនសភាស៊ើបសួរ ដែលសម្រេចក្រោយពីបានស្តាប់ចម្លើយបុគ្គលដែលគេទាមទារសេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី។

## ២.៣.នីតិវិធីនៅដំណាក់កាលសភាស៊ើបសួរ

ក្រោយពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្ទៀងផ្ទាត់មើលនិយតភាពនៃពាក្យសុំ និងបញ្ជូនពាក្យនោះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ជាសាលាជម្រះក្តីដែលមានសមត្ថកិច្ចក្នុងការផ្តល់យោបល់លើបត្យាប័ន ហើយអគ្គព្រះរាជអាជ្ញាជាអ្នករៀបចំសំណុំរឿងដើម្បីប្តឹងទៅសភាស៊ើបសួរ។

រីឯបុគ្គលដែលគេទាមទារ ត្រូវតែចូលមកបង្ហាញខ្លួននៅចំពោះមុខសភាស៊ើបសួរ អមដោយមេធាវីដែលខ្លួនជ្រើសរើស ឬករណីមិនមានមេធាវី នោះតុលាការត្រូវចាត់តាំងមេធាវីណាម្នាក់ជូន។ ចំពោះនីតិវិធីក្នុងការសួរដេញដោលត្រូវប្រព្រឹត្តនៅក្នុងបន្ទប់សម្ងាត់ មិនតែប៉ុណ្ណោះសភាស៊ើបសួរអាចរកអ្នកបកប្រែក្នុងករណីចាំបាច់។

បន្ទាប់ពីបានស្តាប់ចម្លើយរបស់បុគ្គលដែលគេទាមទាររួច ហើយអគ្គព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានសុំ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីរួចមក សភាស៊ើបសួរផ្តល់យោបល់ជាសាលដីកាដែលមានសំអាងហេតុស្តីពីពាក្យសុំឱ្យធ្វើបត្យាប័ននេះ។ការផ្តល់យោបល់របស់សភាស៊ើបសួរអាចជាយោបល់យល់ព្រម ឬយោបល់មិនឯកភាពឱ្យធ្វើបត្យាប័ន។ប្រសិនបើសភាស៊ើបសួរយល់ឃើញថាលក្ខខណ្ឌច្បាប់នៃបត្យាប័នមិនត្រូវបានបំពេញទេ នោះសភាស៊ើបសួរនឹងផ្តល់យោបល់មិនយល់ព្រមឱ្យធ្វើបត្យាប័ន។

ករណីសាលដីការបស់សភាស៊ើបសួរផ្តល់យោបល់យល់ព្រមឱ្យធ្វើបត្យាប័ន នោះបុគ្គលដែលគេទាមទារមានសិទ្ធិប្តឹងសាទុក្ខទៅតុលាការកំពូល ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ កាលណាសាលដីកាផ្តល់យោបល់របស់សភាស៊ើបសួរបានចូលជាស្ថាពរហើយ សាលដីកានេះត្រូវបានជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួង

[២០] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៥៨២

យុត្តិធម៌។យោបល់របស់សភាស៊ើបសួរក្នុងរឿងបត្យាប័ន មានអានុភាពចងជាកាតព្វកិច្ចដល់រាជរដ្ឋាភិបាលៈ (១) ប្រសិនបើសភាស៊ើបសួរផ្តល់យោបល់មិនយល់ស្រប រាជរដ្ឋាភិបាលកម្ពុជាមិនអាចធ្វើបត្យាប័នបានទេ ហើយបុគ្គលដែលគេទាមទារត្រូវបានដោះលែងឱ្យមានសេរីភាពវិញភ្លាម លើកលែងតែបុគ្គលនេះ ជាកម្មវត្ថុនៃសេចក្តីសម្រេចឱ្យឃុំខ្លួនពីរឿងផ្សេង។ (២) ប្រសិនបើសភាស៊ើបសួរផ្តល់យោបល់យល់ព្រម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចបញ្ជូនរឿងនេះទៅរាជរដ្ឋាភិបាល ដើម្បីចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នចំពោះបុគ្គលដែលគេទាមទារនោះ។

ចំពោះការធ្វើបណ្តឹងរបស់បុគ្គលដែលគេទាមទារអាចធ្វើតាមរបៀបដូចជាៈ

- ការធ្វើបណ្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាដំបូងខេត្តដែលចៅក្រមស៊ើបសួរតាំងនៅ ហើយក្រឡាបញ្ជីនៃសាលាដំបូង ត្រូវបញ្ជូនពាក្យសុំតវ៉ាមកការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរសាលាឧទ្ធរណ៍
- ធ្វើបណ្តឹងដោយផ្ទាល់ទៅកាន់ការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរសាលាឧទ្ធរណ៍
- ករណីបុគ្គលនោះជាប់ក្នុងពន្ធនាគារ ឬមន្ទីរឃុំឃាំង ត្រូវធ្វើតាមការប្រកាសប្តឹងចំពោះប្រធានពន្ធនាគារ ឬប្រធានមន្ទីរឃុំឃាំង ហើយប្រធានពន្ធនាគារ ឬប្រធានមន្ទីរឃុំឃាំង ត្រូវបញ្ជូនពាក្យសុំទៅសភាស៊ើបសួរសាលាឧទ្ធរណ៍ជាបន្ទាន់។

## ២.៤.សេចក្តីសម្រេចពីបត្យាប័ន

ប្រសិនបើបុគ្គលដែលគេទាមទារយល់ព្រមឱ្យគេបញ្ជូនខ្លួនតាមពាក្យសុំរបស់រដ្ឋធ្វើសំណើក្រោយពីបានទទួលព័ត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមចំពោះបត្យាប័ន សភាស៊ើបសួរត្រូវចុះនិទ្ទេសនេះនៅក្នុងសាលដីការបស់ខ្លួន។[២១]

នៅពេលដែលសាលដីកានៃការយល់ព្រមឱ្យធ្វើបត្យាប័នរបស់សភាស៊ើបសួរចូលជាស្ថាពរ នឹងត្រូវបានជូនដំណឹងភ្លាមទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចបញ្ជូនរឿងនេះទៅរាជរដ្ឋាភិបាលដើម្បីចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នចំពោះបុគ្គលដែលគេទាមទារនោះ។កាលណាបត្យាប័នត្រូវបានបង្គាប់ បុគ្គលដែលគេទាមទារត្រូវបានប្រគល់ឱ្យរដ្ឋធ្វើសំណើ។រីឯសោហ៊ុយក្នុងការធ្វើបត្យាប័នជាបន្ទុករបស់រដ្ឋធ្វើសំណើ។ នៅពេលដែលបុគ្គលដែលគេទាមទារនោះចាកចេញផុតពីដែនដីកម្ពុជា ក្បួនការពារត្រូវទទួលខុសត្រូវដោយរដ្ឋធ្វើសំណើ។ ប្រសិនបើរដ្ឋធ្វើសំណើមិនបានចាប់ផ្តើមនីតិវិធីមាតុភូមិនិវត្តន៍នៅក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ

[២១] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,មាត្រា៥៩៨

បន្ទាប់ពីការជូនដំណឹងអំពីអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នទេ បុគ្គលដែលគេទាមទារត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។[២២]

ចំណែកនៅក្នុងច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ក៏បានបញ្ញត្តិពី "បត្យាប័នដោយស្ម័គ្រចិត្ត"ថា៖

១.រាជរដ្ឋាភិបាលកម្ពុជា អាចយល់ព្រមដោយពុំចាំបាច់ធ្វើចំណាត់ការបត្យាប័នផ្លូវការឡើយ ចំពោះការធ្វើបត្យាប័នបុគ្គលណាមួយ ចំពោះបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះប្រសិនបើបុគ្គលនោះយល់ព្រមជាលាយលក្ខណ៍អក្សរ នៅចំពោះមុខតំណាងទទួលខុសត្រូវនៃអាជ្ញាធរទទួលបន្ទុកចោទប្រកាន់ថា សុខចិត្តទទួលរងការធ្វើបត្យាប័ន ទៅកាន់រដ្ឋធ្វើសំណើចំពោះបទល្មើសនោះ។

២.រាជរដ្ឋាភិបាលកម្ពុជា មិនត្រូវយល់ព្រមចំពោះបត្យាប័នតាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើឡើយ លុះត្រាណាតែ ៖

ក.រដ្ឋធ្វើសំណើបានធ្វើសំណើផ្លូវការ សុំធ្វើបត្យាប័នបុគ្គលនោះ និង

ខ.មុនពេលដែលការយល់ព្រមត្រូវបានផ្តល់ ជននោះត្រូវតែបានទទួលព័ត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមលើបត្យាប័ន។

មិនតែប៉ុណ្ណោះក៏មានការបដិសេធក្នុងការធ្វើបត្យាប័ន បើពិនិត្យក្នុងច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ក៏មានបទប្បញ្ញត្តិទាក់ទងពីមូលហេតុចាំបាច់សម្រាប់ការបដិសេធសំណើបត្យាប័ន និងបច្ច័យនៃការបដិសេធមិនធ្វើបត្យាប័ន។ផ្អែកតាមមាត្រា៩៨នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម បានបញ្ញត្តិពីមូលហេតុចាំបាច់សម្រាប់បដិសេធសំណើធ្វើបត្យាប័ន៖

១.រាជរដ្ឋាភិបាលកម្ពុជាមិនត្រូវយល់ព្រមតាមសំណើសុំធ្វើបត្យាប័នបុគ្គលណាម្នាក់ចំពោះបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេសដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះឡើយ ប្រសិនបើយល់ឃើញថា៖

ក.សំណើនោះត្រូវបានធ្វើឡើងដើម្បីកាត់ទោស ឬផ្តន្ទាទោសបុគ្គលណាម្នាក់ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ ដើមកំណើត ជាតិពន្ធ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះឬ

ខ.ស្ថានភាពរបស់បុគ្គលនោះ អាចត្រូវរងបុរេនិច្ឆ័យ ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ ដើមកំណើតជាតិពន្ធ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ

គ.បុគ្គលនោះ ត្រូវបានកាត់ទោសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬរដ្ឋបរទេសណាមួយ ចំពោះបទល្មើសនោះ ហើយសាលក្រមបានចូលជាស្ថាពរ និងត្រូវបានអនុវត្តចំពោះបុគ្គលនោះហើយ ឬ

---

[២២] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ,មាត្រា៥៨៩

ឃ.បុគ្គលនោះត្រូវបានផ្តន្ទាទោសពីបទល្មើសនោះដោយកំបាំងមុខ និង ៖

1. ដោយពុំមានការជូនព័ត៌មានគ្រប់គ្រាន់អំពីការកាត់ទោសនោះ ឬដោយបុគ្គលនោះពុំត្រូវបាន ផ្តល់ឱកាសឱ្យរៀបចំការការពារខ្លួន និង
2. ដោយបុគ្គលនោះពុំមាន ឬ នឹងពុំមានឱកាស សុំឱ្យមានការកាត់ទោសករណីនោះឡើងវិញ ដោយមានវត្តមានរបស់ខ្លួន។

២.រាជរដ្ឋាភិបាលកម្ពុជាមិនត្រូវយល់ព្រមតាមសំណើសុំធ្វើបត្យាប័នបុគ្គលណាម្នាក់ចំពោះបទល្មើស ក្រោមច្បាប់របស់រដ្ឋបរទេស ដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះឡើយ ប្រសិនបើយល់ ឃើញថានៅពេលប្រគល់ឱ្យទៅរដ្ឋបរទេសនោះ បុគ្គលនោះនឹងទទួលរងនូវការធ្វើទារុណកម្ម។

យោងតាមមាត្រា៩៩នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្មបានចែងពី"បច្ច័យនៃការបដិសេធមិនធ្វើបត្យាប័ន" ក្នុងករណីដែលរាជរដ្ឋាភិបាលកម្ពុជា ដោយមូលហេតុណាមួយបដិសេធការធ្វើបត្យាប័នបុគ្គលណាមួយ ទៅឱ្យ រដ្ឋធ្វើសំណើ ក្រោយការពិចារណាសមស្របលើសំណើបត្យាប័ន៖

ក.រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែបញ្ជូនសំណុំរឿងនេះ ទៅឱ្យអាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ដើម្បី គោលបំណងនៃការចោទប្រកាន់ និង

ខ.អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ត្រូវតែធ្វើសេចក្តីសម្រេចចិត្តលើសំណុំរឿង ដូចគ្នានឹងករណីនៃបទ ល្មើសតាមបញ្ញត្តិនៃច្បាប់នេះ។

ហេតុដូច្នេះ ក្នុងការសម្រេចធ្វើបត្យាប័នបុគ្គលណាម្នាក់ទៅឱ្យរដ្ឋស្នើសុំត្រូវតែប្រាកដថា បុគ្គលដែលគេ ទាមទារនោះមិនត្រូវបានយកទៅចោទប្រកាន់ឬផ្តន្ទាទោសពីបទល្មើសនយោបាយ សញ្ជាតិ សាសនា ជាតិពន្ធ ដើមកំណើតឬជាតិសាសន៍នោះឡើយ និងមិនត្រូវរងនូវការធ្វើទារុណកម្ម។ប្រសិនបើរកឃើញថារដ្ឋដាក់សំណើ ទាមទារជននោះព្រោះមានគោលបំណងចោទប្រកាន់បុគ្គលនោះពីបទល្មើសដែលបានរៀបរាប់ខាងលើ រដ្ឋ ទទួលសំណើមានសិទ្ធិក្នុងការបដិសេធមិនធ្វើបត្យាប័ន ដោយយល់ឃើញថាប៉ះពាល់ដល់វិស័យមនុស្សធម៌។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបជារួមមក បត្យាប័នសំដៅដល់នីតិវិធីដែលរដ្ឋមួយជារដ្ឋដាក់សំណើនិងរដ្ឋមួយទៀតជារដ្ឋទទួលសំណើ ដោយរដ្ឋទទួលសំណើធ្វើការសម្រេចក្នុងការបញ្ជូនជនល្មើសដែលកំពុងស្ថិតនៅលើដែនដីនៃរដ្ឋរបស់ខ្លួន មកឱ្យអាជ្ញាធរនៃរដ្ឋធ្វើសំណើដើម្បីធ្វើការចោទប្រកាន់ឬផ្តន្ទាទោសតាមផ្លូវច្បាប់។ក្របខណ្ឌក្នុងការធ្វើបត្យាប័នមានៈអនុលោមតាមសន្ធិសញ្ញា ,បទប្បញ្ញត្តិនៃច្បាប់ពិសេស និងក្រមនីតិវិធីព្រហ្មទណ្ឌ។បត្យាប័នអាចធ្វើឡើងតាមរយៈការព្រមព្រៀងរវាងរដ្ឋដាក់សំណើនឹងរដ្ឋទទួលសំណើ ឬអាចធ្វើឡើងតាមរយៈសន្ធិសញ្ញាបត្យាប័ន។ម្យ៉ាងទៀត បត្យាប័នអាចធ្វើទៅបានគឺអាស្រ័យលើកម្មវត្ថុនៃបទល្មើស ហើយបទល្មើសនោះជាប្រភេទបទល្មើសដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ។សម្រាប់លក្ខខណ្ឌដែលមិនអាចធ្វើបត្យាប័នបានមានៈបទល្មើសដែលមានលក្ខណៈនយោបាយ,បទល្មើសដែលបានជំនុំជម្រះរួច,ការរលត់បណ្តឹងអាជ្ញា,ពាក់ព័ន្ធនឹងសញ្ជាតិរបស់បុគ្គលដែលត្រូវបានស្នើសុំ និងទស្សនៈវិស័យមនុស្សធម៌។

ការបង្កើតនីតិវិធីនៃបត្យាប័នជាការធានានូវនីត្យានុកូលភាពនិងនិយតភាពក្នុងការធ្វើបត្យាប័ន។សម្រាប់ដំណើរការក្នុងការធ្វើបត្យាប័នរបស់ប្រទេសកម្ពុជាមានការចូលរួមពីសំណាក់ ក្រសួងការបរទេស ក្រសួងយុត្តិធម៌ និងសភាស៊ើបសួរនៃសាលាឧទ្ធរណ៍។នៅក្នុងការធ្វើបត្យាប័នសភាស៊ើបសួរមានតួនាទីជាអ្នកផ្តល់យោបល់លើបញ្ហាបត្យាប័ន ដោយយោបល់នោះអាចជាការយល់ព្រមនិងមិនយល់ព្រមក្នុងការធ្វើបត្យាប័ន។សម្រាប់នីតិវិធីនៃការធ្វើបត្យាប័នចាប់ផ្តើមពីការដាក់ពាក្យស្នើសុំតាមរយៈស្ថានទូត និងបញ្ចប់ដោយការបញ្ជូនបុគ្គលដែលគេទាមទារមកឱ្យរដ្ឋដាក់សំណើវិញ ដើម្បីធ្វើការចោទប្រកាន់ ជំនុំជម្រះ ឬផ្តន្ទាទោសតាមផ្លូវច្បាប់។

ចំពោះករណីដែលប្រទេសកម្ពុជាជារដ្ឋដាក់សំណើ នោះការបញ្ជូនពាក្យស្នើសុំនឹងធ្វើឡើងតាមរយៈផ្លូវទូត ហើយការសម្រេចធ្វើបត្យាប័នគឺអាស្រ័យលើសន្ធិសញ្ញានិងច្បាប់របស់រដ្ឋទទួលសំណើ។នៅពេលរដ្ឋទទួលសំណើធ្វើការសម្រេចធ្វើបត្យាប័នបុគ្គលនោះមកឱ្យប្រទេសកម្ពុជា បុគ្គលនោះនឹងត្រូវបញ្ជូនមកឱ្យកម្ពុជាវិញ។ប៉ុន្តែបុគ្គលនេះមានសិទ្ធិប្តឹងមោឃភាពនៃបត្យាប័នក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីបុគ្គលនេះមកដល់កម្ពុជា។រីឯករណីប្រទេសកម្ពុជាជារដ្ឋទទួលសំណើ នោះនីតិវិធីចាប់ផ្តើមពីការទទួលពាក្យសុំតាមរយៈស្ថានទូត ដោយរដ្ឋមន្ត្រីក្រសួងការបរទេសបញ្ជូនពាក្យសុំនិងលិខិតបញ្ជាក់ភស្តុតាងមកឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីធ្វើការផ្ទៀងផ្ទាត់មើលនិយតភាពលើពាក្យសុំ រួចបញ្ជូនទៅអគ្គព្រះរាជអាជ្ញា ដើម្បីរៀបចំសំណុំរឿងប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ។ក្នុងករណីនេះបុគ្គលដែលគេទាមទារត្រូវតែចូលទៅផ្តល់ចម្លើយនៅចំពោះមុខសភាស៊ើបសួរ អមដោយមេធាវី ក្រោយស្តាប់ចម្លើយរបស់បុគ្គលនេះរួច សភាស៊ើបសួរអាចផ្តល់យោបល់ជាការយល់ព្រម និងមិនយល់ព្រម។ករណីសភាស៊ើបសួរផ្តល់យោបល់យល់ព្រម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចបញ្ជូនរឿងនេះ

ទៅរាជរដ្ឋាភិបាល ដើម្បីចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នបុគ្គលដែលគេទាមទារនេះ ក៏ប៉ុន្តែបុគ្គលនេះមានសិទ្ធិប្តឹងសាទុក្ខទៅតុលាការកំពូល ក្នុងរយៈពេល៥ថ្ងៃ។

ដូចនេះការធ្វើបត្យាប័នពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការនាំយកជនល្មើសមកផ្តន្ទាទោស ទោះបីបុគ្គលនោះរត់គេចទៅដល់ទីណាក៏ដោយ  ហើយក៏ជាកិច្ចសហប្រតិបត្តិការមួយដែលលុបបំបាត់ការប្រព្រឹត្តបទល្មើសឆ្លងដែន ទោះបីមិនអាចលុបបំបាត់ទាំងស្រុងក៏អាចទប់ស្កាត់ឱ្យនៅចំនួនតិចជាងមុន។ម្យ៉ាងទៀត ការចុះសន្ធិសញ្ញាឬអនុសញ្ញាជាមួយបណ្តាប្រទេសនានា ក៏ជាការបង្កើតឱ្យមានចំណងមិត្តភាពនិងទំនាក់ទំនងក្នុងកិច្ចសហប្រតិបត្តិការ ផ្សេងៗឱ្យកាន់តែមានភាពល្អប្រសើរ  ប៉ុន្តែករណីសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិណាមួយដែលមានប៉ះពាល់ដល់ផលប្រយោជន៍ជាតិ រដ្ឋអាចស្នើសុំលុបចោល ឬដកខ្លួនចេញបាន។បន្ទាប់ពីបានសិក្សាលើប្រធានបទនេះរួច ខ្ញុំសង្កេតឃើញថាបញ្ហាក្នុងការធ្វើបត្យាប័ននៅក្នុងប្រទេសកម្ពុជា មានភាពខ្វះខាតវិធានគតិយុត្ត ហើយក៏ពុំទាន់មានច្បាប់ស្តីពីបត្យាប័នដែលចែងលម្អិតពីលក្ខខណ្ឌនិងនីតិវិធីឱ្យមានភាពច្បាស់លាស់នៅឡើយ មានតែក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនិងបទប្បញ្ញត្តិនៃច្បាប់ពិសេស និងសន្ធិសញ្ញា បត្យាប័នដែលបានចុះជាមួយគូភាគីតែប៉ុណ្ណោះ។ដើម្បីឱ្យការអនុវត្តក្នុងការធ្វើបត្យាប័នទទួលបានគុណភាពនិងប្រសិទ្ធភាព រាជរដ្ឋាភិបាលបន្តខិតខំប្រឹងប្រែងក្នុងការបង្កើតច្បាប់ដែលចែងពីដំណើរការក្នុងការធ្វើបត្យាប័ន និងកំណត់ពីសមត្ថកិច្ចរបស់ស្ថាប័នពាក់ព័ន្ធក្នុងការធ្វើបត្យាប័ន មិនតែប៉ុណ្ណោះ ក៏ត្រូវខិតខំចុះសន្ធិសញ្ញាស្តីបត្យាប័ន ជាមួយបណ្តាប្រទេសផ្សេងៗ ដើម្បីឱ្យមានភាពងាយស្រួលនៅពេលមានការធ្វើបត្យាប័នបុគ្គលណាម្នាក់ដោយធ្វើឡើងតាមរយៈសន្ធិសញ្ញាដែលជាការសហការគ្នាក្នុងការលុបបំបាត់បទល្មើសឆ្លងដែន ណាមួយអាចឱ្យគូភាគីបានដឹងអំពីនីតិវិធី ព្រមទាំងដែនអនុវត្តខ្លះដល់គូភាគី តាមការព្រមព្រៀងគ្នានៅក្នុងសន្ធិសញ្ញា។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទបត្យាប័នរួចមក នាងខ្ញុំទទួលបាននូវចំណេះដឹងពាក់ព័ន្ធនឹងវិធីសាស្ត្រក្នុងការធ្វើបត្យាប័ន ដោយដំណើការនៃការធ្វើបត្យាប័នចាប់ផ្ដើមពីនីតិវិធីក្នុងការបញ្ជូនពាក្យស្នើសុំធ្វើបត្យាប័នទៅកាន់រដ្ឋទទួលសំណើតាមរយៈស្ថានទូត ហើយរដ្ឋទទួលសំណើមានតួនាទីត្រួតពិនិត្យនិយតភាពលើពាក្យសុំនេះ។ចំណែកការសម្រេចធ្វើបត្យាប័នគឺអាស្រ័យលើសន្ធិសញ្ញានិងច្បាប់ជាតិរបស់រដ្ឋទទួលសំណើ ប្រសិនបើរដ្ឋទទួលសំណើសម្រេចធ្វើបត្យាប័នបុគ្គលដែលទាមទារនោះមកឱ្យរដ្ឋផ្ញើសំណើបុគ្គលនោះនឹងត្រូវបញ្ជូនមកកាន់រដ្ឋដាក់សំណើវិញ។បត្យាប័នអាចធ្វើឡើងតាមរយៈការព្រមព្រៀងរវាងរដ្ឋដាក់សំណើនឹងរដ្ឋទទួលសំណើ ឬផ្អែកតាមសន្ធិសញ្ញាស្តីពីបត្យាប័ន។ចំណែកឯលក្ខខណ្ឌក្នុងការធ្វើបត្យាប័ន គឺអាស្រ័យលើកម្មវត្ថុនៃបទល្មើស ប៉ុន្តែមិនមែនគ្រប់បទល្មើសសុទ្ធតែអាចធ្វើបត្យាប័នបាននោះទេ។

សម្រាប់នីតិវិធីនៃការធ្វើបត្យាប័ននៅក្នុងប្រទេសកម្ពុជា គឺត្រូវអនុលោមតាមសន្ធិសញ្ញា ,ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិនៃច្បាប់ពិសេស ក៏ប៉ុន្តែវិធានច្បាប់ទាំងនេះនូវតែមានភាពខ្វះចន្លោះសម្រាប់យកមកអនុវត្តក្នុងការធ្វើបត្យាប័នឱ្យមានប្រសិទ្ធភាព ជាពិសេសក្នុងករណីរដ្ឋបរទេសដែលមិនមានសន្ធិសញ្ញាជាមួយកម្ពុជា ដែលជាផលលំបាករបស់រដ្ឋបរទេសក្នុងការស្នើសុំធ្វើបត្យាប័នបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសរួចរត់មកស្នាក់នៅលើដែនដីនៃប្រទេសកម្ពុជា និងក្នុងករណីប្រទេសកម្ពុជាជារដ្ឋដាក់សំណើទៅកាន់រដ្ឋបរទេសដើម្បីស្នើសុំធ្វើបត្យាប័ន ពលរដ្ឋខ្មែរដែលបានប្រព្រឹត្តបទល្មើសនៅលើដែនដីនៃរដ្ឋផ្សេងឬបានប្រព្រឹត្តបទល្មើសនៅកម្ពុជារួចរត់មកស្នាក់នៅក្នុងរដ្ឋបរទេស។

មិនតែប៉ុណ្ណោះ ប្រទេសកម្ពុជាមិនទាន់មានច្បាប់ដែលចែងអំពីដំណើរការក្នុងការធ្វើបត្យាប័នដែលមានភាពលម្អិតនិងច្បាស់លាស់ (លក្ខខណ្ឌដែលអនុញ្ញាតនិងមិនអនុញ្ញាតឱ្យធ្វើបត្យាប័ន ,នីតិវិធីនៃបត្យាប័ន) នោះទេ។ដើម្បីឱ្យការអនុវត្តក្នុងការធ្វើបត្យាប័នទទួលបានប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាត្រូវតែបង្កើតច្បាប់ស្តីពីបត្យាប័នដែលចែងអំពីដំណើរការនៃការធ្វើបត្យាប័ន និងកំណត់នូវសមត្ថកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ ក្នុងការធ្វើបត្យាប័ន ហើយលម្អិតអំពីលក្ខខណ្ឌនិងនីតិវិធីឱ្យបានច្បាស់ផងដែរ។

ដូចនេះរាជរដ្ឋាភិបាលកម្ពុជាត្រូវតែបង្កើតច្បាប់ស្តីពីបត្យាប័ន និងបន្តខិតខំបង្កើតកិច្ចសហប្រតិបត្តិការជាមួយប្រទេសផ្សេងៗដើម្បីឱ្យការអនុវត្តច្បាប់ក្នុងការធ្វើបត្យាប័នទទួលបានប្រសិទ្ធភាពខ្ពស់។ចំណែកការផ្សព្វផ្សាយអំពីច្បាប់នៅក្នុងប្រទេសកម្ពុជា ដែលរៀបចំឡើងរវាងក្រសួងយុត្តធម៌និងទូរទស្សន៍ជាតិនៃកម្ពុជាដែលធ្វើឡើងក្នុងគោលបំណងឱ្យប្រជាជនយល់ដឹងអំពីច្បាប់ ជាពិសេសបញ្ហាបត្យាប័ន ដើម្បីឈានដល់ការលុបបំបាត់ការប្រព្រឹត្តបទល្មើសឆ្លងដែន។

# ឯកសារយោង

# ឯកសារយោង


១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

២.សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសចំនួនប្រាំមាន៖

- ព្រះរាជាណាចក្រថៃ អនុម័តនៅឆ្នាំ១៩៩៩
- សាធារណរដ្ឋប្រជាមានិតចិន អនុម័តនៅឆ្នាំ២០០០
- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ អនុម័តនៅឆ្នាំ២០០៥
- សាធារណរដ្ឋសង្គមនិយមវៀតណាម អនុម័តនៅឆ្នាំ២០១៤
- សហព័ន្ធរុស្ស៊ី អនុម័តនៅឆ្នាំ២០១៨

៣.អនុសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយសាធារណរដ្ឋបារាំង អនុម័តនៅឆ្នាំ២០២០

៤.កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយសាធារណរដ្ឋកូរ៉េ អនុម័តនៅឆ្នាំ២០១០

៥.សន្ធិសញ្ញាគំរូស្តីពីបត្យាប័នរបស់អង្គការសហប្រជាជាតិ ដែលអនុម័តនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០

៦.ច្បាប់ស្តីពីការអនុម័តយល់ព្រមក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ឆ្នាំ១៩៨៨

៧.ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងអំពើភេរវកម្ម ដែលអនុម័តនៅឆ្នាំ២០១០

៨.ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

៩.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

១០.ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

១១.ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១១

១២.ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្មឆ្នាំ២០០៧

១៣.សៀវភៅស្តីពីនីតិព្រហ្មទណ្ឌទូទៅ របស់លោកសាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ បោះពុម្ពផ្សាយលើកទី៣ឆ្នាំ២០២១

១៤.ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលនៃក្រសួងយុត្តិធម៌ឆ្នាំ២០១៧,លេខ១០០ កយ.ប្រក/១៧

១៥.កម្រងឯកសារស្តីពីការធ្វើចំណាត់ថ្នាក់ច្បាប់របស់ ម.ស.ម.ក វគ្គ៧ (ច្បាប់ស្តីពីការធ្វើបត្យាប័ន) ខែកក្កដា ឆ្នាំ២០១២

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

១.ឧបសម្ព័ន្ធទី១សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជាជាមួយព្រះរាជាណាចក្រថៃ អនុម័តនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩

២.ឧបសម្ព័ន្ធទី២សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជាជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម អនុម័តនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤

៣.ឧបសម្ព័ន្ធទី៣កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជាជាមួយសាធារណរដ្ឋកូរ៉េ អនុម័តនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០

៤.ឧបសម្ព័ន្ធទី៤អនុសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជាជាមួយសាធារណរដ្ឋបារាំង អនុម័តនៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០

៥.ឧបសម្ព័ន្ធទី៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើកាលពី ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧

៦.ឧបសម្ព័ន្ធទី៦ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧

៧.ឧបសម្ព័ន្ធទី៧ឯកសារបត្យាប័ន ដែលរៀបរៀងដោយ ឯកឧត្តម ផូវ សំភី នៅឆ្នាំ២០១៨

៨.ឧបសម្ព័ន្ធទី៨បទបង្ហាញស្តីពីបត្យាប័ន ដែលរៀបចំដោយក្រសួងយុត្តិធម៌ ឆ្នាំ២០២២

៩.ឧបសម្ព័ន្ធទី៩អនុក្រឹត្យស្តីពីការបង្គាប់ឱ្យធ្វើបត្យាប័ន ឆ្នាំ២០១១

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី២

## សន្ធិសញ្ញា
## ស្ដីពី
## បត្យាប័ន
## រវាង
## ព្រះរាជាណាចក្រកម្ពុជា
## និង
## សាធារណរដ្ឋសង្គមនិយមវៀតណាម

ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម (តទៅនេះហៅថា"ភាគី" សម្រាប់ភាគីនីមួយៗ ឬ "គូភាគី" សម្រាប់គូភាគី)

ដោយមានបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរវាងប្រទេសទាំងពីរក្នុងការបង្ក្រាបបទល្មើស ដោយឈរលើមូលដ្ឋានគោរពអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និងផលប្រយោជន៍រួមទាំងសងខាង តាមរយៈការចុះសន្ធិសញ្ញាបត្យាប័ន

បានព្រមព្រៀងគ្នាដូចតទៅ៖

### មាត្រា ១
### ភាតព្វកិច្ចធ្វើបត្យាប័ន

ដោយអនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ ភាគីយល់ព្រមធ្វើបត្យាប័នទៅឲ្យភាគីម្ខាងទៀតនូវបុគ្គលទាំងឡាយ ដែលមានវត្តមាននៅលើដែនដីរបស់ខ្លួនដែលភាគីម្ខាងទៀតស្នើសុំ ដើម្បីធ្វើការចោទប្រកាន់ ជំនុំជម្រះ ឬអនុវត្តទោសចំពោះបទល្មើសដែលអាចធ្វើបត្យាប័នបាន។

### មាត្រា ២
### បទល្មើសដែលអាចធ្វើបត្យាប័នបាន

១.បទល្មើសដែលអាចធ្វើបត្យាប័នបាន តាមបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ សំដៅដល់



S  Mg

បទល្មើសដែលអាចផ្តន្ទាទោសតាមច្បាប់ជាធរមានរបស់គូភាគី ដោយការដាក់ពន្ធនាគារ សម្រាប់រយៈពេលយ៉ាងតិចពី ២ (ពីរ) ឆ្នាំឡើងទៅ ឬដោយទោសណាមួយដែលធ្ងន់ធ្ងរជាងនេះ។

២.ករណីមានសំណើសុំធ្វើបត្យាប័នពាក់ព័ន្ធដល់បុគ្គលណាមួយ ដែលត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារដោយតុលាការនៃភាគីធ្វើសំណើ ចំពោះបទល្មើសដែលអាចធ្វើបត្យាប័នបាន បត្យាប័នត្រូវផ្តល់ជូនបាន លុះត្រាតែពេលវេលាអនុវត្តទោសនៅសល់យ៉ាងតិចបំផុត ៦ (ប្រាំមួយ) ខែ។

៣.អនុលោមតាមបញ្ញត្តិនៃមាត្រានេះ បទល្មើសដែលត្រូវបានចាត់ទុកថាជាបទល្មើសតាមច្បាប់នៃគូភាគី គឺភាគីធ្វើសំណើផង និងភាគីទទួលសំណើផង ទោះបីជា៖

ក.អំពើដែលជាបទល្មើសស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នាក្តី ឬ

ខ.ឈ្មោះបទល្មើស ការប្រើបច្ចេកសព្ទ ឬនិយមន័យ ឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នាក្តី ឬ

គ.ធាតុផ្សំបទល្មើសនៃច្បាប់របស់ភាគីធ្វើសំណើ ខុសគ្នាពីធាតុផ្សំបទល្មើសដែលកំណត់ដោយច្បាប់នៃភាគីទទួលសំណើក៏ដោយ ប្រសិនបើពិចារណាលើធាតុផ្សំទាំងអស់នៃបទល្មើស ដែលត្រូវបានបង្ហាញដោយភាគីធ្វើសំណើ គឺជាការប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមានរបស់ភាគីទទួលសំណើ។

៤.ក្នុងករណីបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃភាគីធ្វើសំណើ បត្យាប័នត្រូវបានផ្តល់ឲ្យ ប្រសិនបើច្បាប់នៃភាគីទទួលសំណើបានចែងអំពីការផ្តន្ទាទោសបទល្មើសនោះ ហើយបុគ្គលដែលគេទាមទារធ្វើបត្យាប័ន គឺជាពលរដ្ឋរបស់ភាគីធ្វើសំណើ។ ករណីច្បាប់នៃភាគីទទួលសំណើមិនមានចែងដូច្នេះ នោះភាគីទទួលសំណើអាចផ្តល់បត្យាប័នដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

## មាត្រា ៣
## ការបដិសេធធ្វើបត្យាប័ន

១.អនុលោមតាមសន្ធិសញ្ញានេះ ការធ្វើបត្យាប័នត្រូវបដិសេធ ក្នុងករណីណាមួយដូចខាងក្រោម ៖

ក.បទល្មើសដែលត្រូវបានចោទប្រកាន់ ជាបទល្មើសមានលក្ខណៈនយោបាយ។ ប៉ុន្តែមិនត្រូវចាត់ទុកថាជាបទល្មើសនយោបាយទេចំពោះអំពើហិង្សាដែលធ្វើឲ្យមានគ្រោះថ្នាក់ដល់ជីវិត ដល់បូរណភាពខាងរូបកាយ ឬដល់សេរីភាពរបស់បុគ្គល

ខ.បទល្មើសដែលជាកម្មវត្ថុនៃការស្នើសុំធ្វើបត្យាប័ន ជាបទល្មើសយោធា

គ.មានមូលដ្ឋានច្បាស់លាស់ថា សំណើសុំធ្វើបត្យាប័នចំពោះបទល្មើសណាមួយដែលបានធ្វើឡើងក្នុងគោលបំណងចោទប្រកាន់ ឬក៏ផ្តន្ទាទោសបុគ្គលដែលគេទាមទារដោយមូលហេតុពូជសាសន៍ ជាតិពន្ធុ ភេទ ភាសា សាសនា សញ្ជាតិ ទស្សនៈនយោបាយ ឬធ្វើឲ្យបុគ្គលនោះទទួលរងនូវឥទ្ធិពលដោយសារមូលហេតុទាំងនេះ

ឃ.បុគ្គលដែលគេទាមទារត្រូវបានសម្រេចថាគ្មានទោស ឬត្រូវបានលើកលែងទោស ឬបានអនុវត្តទោស ចំពោះបទល្មើសដែលបុគ្គលនេះត្រូវបានស្នើសុំឲ្យធ្វើបត្យាប័នតាមច្បាប់នៃភាគីទទួលសំណើ ឬរដ្ឋទីបី

ង.បុគ្គលដែលត្រូវធ្វើបត្យាប័ន ត្រូវបានលើកលែងពីការចោទប្រកាន់ ការជំនុំជម្រះ ឬការអនុវត្តទោស ដោយមូលហេតុផុតអាជ្ញាយុកាលដែលមានចែងក្នុងច្បាប់នៃគូភាគី គឺភាគីធ្វើសំណើ និងភាគីទទួលសំណើ

ច.ភាគីទទួលសំណើមានមូលដ្ឋានដែលនាំឲ្យមានការជឿជាក់ថា បុគ្គលដែលត្រូវធ្វើបត្យាប័ន ត្រូវបានធ្វើទារុណកម្ម ឬត្រូវបានដាក់ទណ្ឌកម្ម ឬផ្តន្ទាទោសបែបព្រៃផ្សៃ ឬអមនុស្សធម៌ ឬ

ឆ.ភាគីទទួលសំណើបានប្រកាសសាលក្រម ឬ សាលដីកាចុងក្រោយផ្តន្ទាទោសបុគ្គលដែលត្រូវធ្វើបត្យាប័នចំពោះបទល្មើសដដែល មុនពេលធ្វើសំណើសុំបត្យាប័ន។

២.បត្យាប័នអាចត្រូវបានបដិសេធក្នុងករណីណាមួយ ដូចខាងក្រោម ៖

ក.បុគ្គលដែលត្រូវបានស្នើសុំធ្វើបត្យាប័ន កំពុងត្រូវបានចោទប្រកាន់ក្នុងដែនដីនៃភាគីទទួលសំណើ ចំពោះបទល្មើសដែលបានលើកឡើងក្នុងសំណើសុំធ្វើបត្យាប័ន

ខ.យោងតាមច្បាប់របស់ខ្លួន ភាគីទទួលសំណើមានយុត្តាធិការលើបទល្មើសដែលជាកម្មវត្ថុនៃសំណើសុំធ្វើបត្យាប័ន។ ក្នុងករណីនេះអាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលសំណើត្រូវដំណើរការនីតិវិធីចំពោះបុគ្គលដែលគេទាមទារ

គ.ក្នុងករណីពិសេសទាំងឡាយ ដោយគិតពីភាពធ្ងន់ធ្ងរនៃបទល្មើស និងផល

ប្រយោជន៍នៃភាគីធ្វើសំណើ ភាគីទទួលសំណើអាចពិនិត្យឃើញថា បត្យាប័ននេះមានវិសមិតភាពទៅនឹងទស្សនវិស័យផ្នែកមនុស្សធម៌ ដោយសារស្ថានភាពផ្ទាល់របស់បុគ្គលដែលគេទាមទារ

ឃ.អនុលោមតាមសន្ធិសញ្ញានេះ បទល្មើសដែលបុគ្គលដែលគេទាមទារត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោស ឬបទល្មើសដទៃផ្សេងទៀតដែលបុគ្គលនោះបានប្រព្រឹត្ត អាចត្រូវបានឃុំខ្លួន ឬជំនុំជម្រះ ជាទោសប្រហារជីវិតតាមច្បាប់នៃភាគីធ្វើសំណើ លុះត្រាតែភាគីនោះសន្យាថាមិនដាក់ទោសប្រហារជីវិត ឬបើដាក់ទោសនោះ នឹងមិនត្រូវអនុវត្ត។

៣.ក្នុងករណីបដិសេធសំណើសុំធ្វើបត្យាប័ន ភាគីទទួលសំណើត្រូវជូនព័ត៌មានដល់ភាគីធ្វើសំណើជាលាយលក្ខណ៍អក្សរ នៅក្នុងអំឡុងពេលសមស្របណាមួយ ដោយបង្ហាញអំពីមូលហេតុនៃការបដិសេធឲ្យបានច្បាស់លាស់។

## មាត្រា ៤
## ការធ្វើបត្យាប័នចំពោះពលរដ្ឋសាមី

១.ភាគីនីមួយៗ មានសិទ្ធិបដិសេធការធ្វើបត្យាប័នពលរដ្ឋរបស់ខ្លួន។ សញ្ជាតិរបស់បុគ្គលដែលគេទាមទារ ត្រូវបានកំណត់នៅកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើស ដែលជាកម្មវត្ថុនៃសំណើសុំធ្វើបត្យាប័ន។

២.ប្រសិនបើភាគីទទួលសំណើបដិសេធការធ្វើបត្យាប័នពលរដ្ឋរបស់ខ្លួន ភាគីទទួលសំណើត្រូវបញ្ជូនសំណុំរឿងទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ឬជំនុំជម្រះ ដោយផ្អែកតាមច្បាប់របស់ខ្លួន និងតាមសំណើរបស់ភាគីធ្វើសំណើ។ ក្នុងករណីនេះ ភាគីធ្វើសំណើត្រូវបញ្ជូនឯកសារ និងភស្តុតាងដែលទាក់ទងនឹងសំណុំរឿងទៅភាគីទទួលសំណើ។

## មាត្រា ៥
## ទំនាក់ទំនងជាមួយនឹងលិខិតុបករណ៍អន្តរជាតិ

សន្ធិសញ្ញានេះ មិនមានឥទ្ធិពលដល់សិទ្ធិ និងកាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងសន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា លិខិតុបករណ៍អន្តរជាតិផ្សេងទៀតដែលគូភាគីជាសមាជិកឡើយ។

## មាត្រា ៦
## នីតិវិធី

លើកលែងតែមានបញ្ញត្តិផ្សេងក្នុងសន្ធិសញ្ញានេះ មានតែច្បាប់នៃភាគីទទួលសំណើប៉ុណ្ណោះ ដែលអាចអនុវត្តចំពោះនីតិវិធីនៃការចាប់ខ្លួនជាបណ្តោះអាសន្ន ការធ្វើបត្យាប័ន និងការឆ្លងកាត់។

## មាត្រា ៧
## អាជ្ញាធរកណ្តាល

អាជ្ញាធរកណ្តាល នៃព្រះរាជាណាចក្រកម្ពុជា គឺក្រសួងយុត្តិធម៌។

អាជ្ញាធរកណ្តាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម គឺក្រសួងសន្តិសុខសាធារណៈ។

ភាគីអាចផ្លាស់ប្តូរអាជ្ញាធរកណ្តាលរបស់ខ្លួន ប៉ុន្តែត្រូវជូនព័ត៌មានអំពីការផ្លាស់ប្តូរទៅឲ្យភាគីម្ខាងទៀត តាមរយៈបណ្តាញការទូត។

គូភាគីត្រូវធ្វើការទំនាក់ទំនងគ្នាដោយផ្ទាល់តាមរយៈអាជ្ញាធរកណ្តាល។

## មាត្រា ៨
## នីតិវិធីបត្យាប័ន និងឯកសារចាំបាច់ដែលត្រូវភ្ជាប់ជាមួយ

១.សំណើសុំធ្វើបត្យាប័នត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនតាមរយៈអាជ្ញាធរកណ្តាលរបស់គូភាគី។ ក្នុងករណីចាំបាច់ គូភាគីអាចធ្វើការទំនាក់ទំនងគ្នាតាមរយៈបណ្តាញការទូត។ រាល់ឯកសារភ្ជាប់ជាមួយពាក្យសុំធ្វើបត្យាប័ន ត្រូវទទួលស្គាល់ថាត្រឹមត្រូវស្របតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១០ នៃសន្ធិសញ្ញានេះ។ ពាក្យសុំធ្វើបត្យាប័ន និងឯកសារភ្ជាប់ជាមួយ ត្រូវផ្តល់ចំនួន ៣ (បី) ច្បាប់។ សេចក្តីចម្លងមិនទាមទារឲ្យបញ្ជាក់នីត្យានុកូលកម្មឡើយ។ ពាក្យសុំធ្វើបត្យាប័នត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

ក.លិខិតអធិប្បាយអំពីអង្គហេតុនៃសំណុំរឿង ដែលជាកម្មវត្ថុនៃសំណើសុំធ្វើបត្យាប័ន ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែងប្រព្រឹត្តបទល្មើស និងឈ្មោះបទល្មើស

ខ.លិខិតពិពណ៌នាអំពីរូបរាងរបស់បុគ្គល ដែលជាកម្មវត្ថុនៃសំណើសុំធ្វើ



5

បត្យាប័ន និងព័ត៌មានពាក់ព័ន្ធដែលអាចបញ្ជាក់ពីអត្តសញ្ញាណ សញ្ជាតិ ហើយប្រសិនបើអាច ទីកន្លែងរបស់បុគ្គលដែលគេទាមទារនោះ

គ.រាល់បទប្បញ្ញត្តិនៃច្បាប់ដែលកំណត់អំពីធាតុផ្សំសំខាន់ៗ និងឈ្មោះនៃបទល្មើស ដែលជាកម្មវត្ថុនៃការស្នើសុំធ្វើបត្យាប័ន និងទោសចំពោះបទល្មើស

ឃ.រាល់បទប្បញ្ញត្តិនៃច្បាប់ដែលចែងអំពីអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ឬ អាជ្ញាយុកាលនៃទោសចំពោះបទល្មើសនោះ ប្រសិនបើមាន។

២.សំណើសុំធ្វើបត្យាប័នដែលទាក់ទងនឹងបុគ្គលដែលគេទាមទារ ដើម្បីចោទប្រកាន់ ត្រូវភ្ជាប់បន្ថែមមកជាមួយនូវៈ

ក.ដីកាចាប់ខ្លួនច្បាប់ដើម និងសេចក្តីចម្លងដីកាចាប់ខ្លួនចំនួន ២ (ពីរ) ច្បាប់ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីធ្វើសំណើ និង

ខ.លិខិតអធិប្បាយដែលអាចបកស្រាយបានសម្រាប់ការចាប់ខ្លួន និងការឃុំខ្លួន ដើម្បីរង់ចាំការជំនុំជម្រះលើបុគ្គលនោះ ដោយរួមទាំងលិខិតអធិប្បាយដែលបញ្ជាក់ថាបុគ្គល ដែលត្រូវគេទាមទារ ពិតជាបុគ្គលដែលកំណត់ក្នុងដីកាចាប់ខ្លួនមែន។

៣.កាលណាសំណើសុំធ្វើបត្យាប័នទាក់ទងទៅនឹងបុគ្គល ដែលត្រូវបានផ្តន្ទាទោសរួច ហើយ ក្រៅពីឯកសារធ្វើសំណើដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវភ្ជាប់បន្ថែមមកជាមួយនូវៈ

ក.សាលក្រម ឬសាលដីកាចុងក្រោយច្បាប់ដើម និងសេចក្តីចម្លងនៃសាលក្រម ឬសាលដីកាចុងក្រោយចំនួន ២ (ពីរ) ច្បាប់ ដែលផ្តន្ទាទោសដោយតុលាការនៃភាគីធ្វើសំណើ

ខ.លិខិតអធិប្បាយដែលបញ្ជាក់ថាបុគ្គលដែលគេទាមទារ គឺពិតជាបុគ្គលដែលកំណត់ក្នុងសាលក្រម ឬសាលដីកានោះមែន

គ.លិខិតអធិប្បាយអំពីពេលវេលាដែលបានអនុវត្តទោសរួចហើយ និង

ឃ.លិខិតអធិប្បាយអំពីមធ្យោបាយតាមផ្លូវច្បាប់ដែលមានស្រាប់ ដើម្បីបុគ្គលនេះរៀបចំបណ្តឹងឧបាស្រ័យ ឬបណ្តឹងសើរើដោយមានវត្តមានរបស់បុគ្គលនេះ ប្រសិនបើបុគ្គលនោះត្រូវបានផ្តន្ទាទោសដោយកំបាំងមុខ។

៤.រាល់ឯកសារទាំងអស់អមជាមួយសំណើសុំធ្វើបត្យាប័ន ត្រូវភ្ជាប់ជាមួយនូវអត្ថបទ

បកប្រែជាភាសាផ្លូវការរបស់ភាគីទទួលសំណើ។

## មាត្រា ៩
## នីតិវិធីបត្យាប័នសាមញ្ញ

នៅក្នុងវិសាលភាពដែលច្បាប់នៃភាគីទទួលសំណើបានអនុញ្ញាត ការធ្វើបត្យាប័ន អាចប្រព្រឹត្តទៅបានតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ ប្រសិនបើបុគ្គលដែលគេស្នើសុំយល់ព្រមឲ្យគេបញ្ជូនខ្លួនតាមការស្នើសុំធ្វើបត្យាប័ន ក្រោយពីបានទទួលព័ត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមចំពោះការធ្វើបត្យាប័ន ពីអាជ្ញាធរមានសមត្ថកិច្ចនៃភាគីធ្វើសំណើ ទោះបីជាបណ្ដាសំណើដែលបានកំណត់ក្នុងមាត្រា ៨ នៃសន្ធិសញ្ញានេះ មិនទាន់ត្រូវបានបំពេញគ្រប់គ្រាន់ក្ដី។

## មាត្រា ១០
## នីត្យានុកូលកម្មនៃឯកសារយោងផ្សេងៗ

១.អនុលោមតាមមាត្រា ៨ នៃសន្ធិសញ្ញនេះ ឯកសារដែលបានភ្ជាប់មកជាមួយនឹងសំណើសុំធ្វើបត្យាប័ន ប្រសិនបើបានបញ្ជាក់នីត្យានុកូលកម្ម ដោយភាគីធ្វើសំណើនៅក្នុងដំណើរការនៃការធ្វើបត្យាប័នណាមួយ នឹងត្រូវទទួលស្គាល់នៅក្នុងដែនដីនៃភាគីទទួលសំណើ។

២.ឯកសារត្រូវបានបញ្ជាក់នីត្យានុកូលកម្ម ក្នុងគោលបំណងនៃសន្ធិសញ្ញានេះ ប្រសិនបើឯកសារនេះត្រូវបានចុះហត្ថលេខា ឬបញ្ជាក់ដោយត្រាជាផ្លូវការរបស់មន្ត្រី ឬអាជ្ញាធរមានសមត្ថកិច្ចនៃភាគីធ្វើសំណើ។

## មាត្រា ១១
## ព័ត៌មានបន្ថែម

ប្រសិនបើភាគីទទួលសំណើយល់ឃើញថា ព័ត៌មានដែលភ្ជាប់មកជាមួយសំណើសុំធ្វើបត្យាប័នមិនគ្រប់គ្រាន់ សម្រាប់អនុវត្តនីតិវិធីធ្វើបត្យាប័នតាមសន្ធិសញ្ញានេះ ភាគីនោះអាចស្នើសុំផ្ដល់ព័ត៌មានបន្ថែម នៅក្នុងអំឡុងពេលសមស្របដែលបានកំណត់ដោយភាគីទទួលសំណើ។

5

## មាត្រា ១២
## ការចាប់ខ្លួនបណ្ដោះអាសន្ន

១.ក្នុងករណីបន្ទាន់ អាជ្ញាធរមានសមត្ថកិច្ចនៃភាគីធ្វើសំណើអាចស្នើសុំទៅភាគីម្ខាងទៀតឲ្យធ្វើការចាប់ខ្លួនបណ្ដោះអាសន្ននូវបុគ្គលដែលគេទាមទារ មុនការស្នើសុំធ្វើបត្យាប័នជាផ្លូវការដែលត្រូវធ្វើឡើងតាមរយៈអាជ្ញាធរកណ្ដាល។

សំណើសុំចាប់ខ្លួនបណ្ដោះអាសន្នត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលសំណើ តាមរយៈបណ្ដាញការទូត ឬតាមរយៈអង្គភាពនគរបាលឧក្រិដ្ឋកម្មអន្តរជាតិ (អាំងទែរប៉ូល) ឬបញ្ជូនតាមមធ្យោបាយណាមួយ រួមទាំងប្រព័ន្ធអេឡិចត្រូនិចដែលទទួលស្គាល់ទៅវិញទៅមកដោយគូភាគី។

២.សំណើសុំខាងលើរួមមាន៖

ក.លិខិតអធិប្បាយអំពីមូលហេតុនៃការធ្វើសំណើជាបន្ទាន់

ខ.ការពិពណ៌នាអំពីបុគ្គលដែលគេទាមទារ រួមមានរូបថត និងស្នាមម្រាមដៃ ប្រសិនបើអាចធ្វើទៅបាន

គ.ទីកន្លែងដែលបុគ្គលនោះស្ថិតនៅ ប្រសិនបើដឹង

ឃ.លិខិតអធិប្បាយអំពីអង្គហេតុនៃបទល្មើសដែលបុគ្គលនោះបានប្រព្រឹត្ត

ង.រាល់បទប្បញ្ញត្តិនៃច្បាប់ដែលកំណត់អំពីធាតុផ្សំសំខាន់ៗ និងឈ្មោះនៃបទល្មើសដែលជាកម្មវត្ថុនៃការស្នើសុំចាប់ខ្លួនបណ្ដោះអាសន្ន និងទោសចំពោះបទល្មើស

ច.ដីកាចាប់ខ្លួន ឬសាលក្រម ឬសាលដីកាចុងក្រោយផ្ដន្ទាទោសចំពោះបុគ្គលដែលគេទាមទារ

ឆ.លិខិតអធិប្បាយអំពីទោសដែលអាច ឬត្រូវផ្ដន្ទាទោសចំពោះបទល្មើស និង

ញ.សេចក្ដីបញ្ជាក់យ៉ាងច្បាស់លាស់ថា សំណើសុំធ្វើបត្យាប័នលើបុគ្គលដែលគេទាមទារ នឹងត្រូវបញ្ជូនតាមក្រោយ។

៣.នៅពេលទទួលបានលិខិតស្នើសុំនោះ ប្រសិនបើស្របច្បាប់ជាតិរបស់ខ្លួន ភាគីទទួលសំណើត្រូវចាត់វិធានការចាំបាច់ក្នុងការចាប់ខ្លួនបុគ្គលដែលគេទាមទារ ហើយភាគីធ្វើ

សំណើត្រូវបានគេផ្តល់ដំណឹងដោយគ្មានការយឺតយ៉ាវអំពីលទ្ធផលនៃការស្នើសុំរបស់ខ្លួន។

៤.បុគ្គលដែលត្រូវចាប់ខ្លួនតាមការស្នើសុំនឹងត្រូវបានដោះលែង ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃចាប់ពីថ្ងៃដែលបុគ្គលនោះត្រូវបានចាប់ខ្លួន ប្រសិនបើភាគីទទួលសំណើពុំបានទទួលសំណើសុំធ្វើបត្យាប័ន និងរាល់ឯកសារចាំបាច់ភ្ជាប់មកជាមួយដូចដែលបានចែងក្នុងមាត្រា ៨ នៃសន្ធិសញ្ញានេះ។

៥.ការដោះលែងបុគ្គលដែលត្រូវបានចាប់ខ្លួនបណ្តោះអាសន្ន យោងតាមកថាខណ្ឌទី ៤ នៃមាត្រានេះ មិនរារាំងដល់ការធ្វើបត្យាប័នបុគ្គលដែលគេទាមទារនោះទេ ប្រសិនបើសំណើសុំធ្វើបត្យាប័នត្រូវបានទទួលនៅពេលក្រោយ។

## មាត្រា ១៣
## សំណើសុំធ្វើបត្យាប័នធ្វើឡើងដោយរដ្ឋច្រើន

១.នៅក្នុងករណីដែលសំណើត្រូវបានទទួលពីរដ្ឋពីរ ឬច្រើនសម្រាប់ការធ្វើបត្យាប័នបុគ្គលដដែល ភាគីទទួលសំណើត្រូវកំណត់ថាតើត្រូវធ្វើបត្យាប័នបុគ្គលនោះទៅឲ្យរដ្ឋណាមួយក្នុងចំណោមរដ្ឋទាំងនោះ ហើយត្រូវតែជូនដំណឹងទៅភាគីធ្វើសំណើពីការសម្រេចចិត្តរបស់ខ្លួន។

២.ការកំណត់រដ្ឋណាមួយដែលបុគ្គលនោះត្រូវធ្វើបត្យាប័ន ភាគីទទួលសំណើត្រូវពឹងផ្អែកលើលក្ខខណ្ឌផ្សេងៗ ជាពិសេសគឺៈ

ក.ប្រសិនបើមានសំណើពាក់ព័ន្ធនឹងបទល្មើសច្រើនផ្សេងៗគ្នា ភាពធ្ងន់ធ្ងរនៃបណ្តាបទល្មើស

ខ.ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តបទល្មើសនីមួយៗ

គ.កាលបរិច្ឆេទនៃសំណើសុំធ្វើបត្យាប័ន

ឃ.សញ្ជាតិរបស់បុគ្គលដែលត្រូវធ្វើបត្យាប័ន

ង.ទីលំនៅរបស់បុគ្គលដែលត្រូវធ្វើបត្យាប័ន និង

ច.លទ្ធភាពនៃការធ្វើបត្យាប័នទៅរដ្ឋណាមួយក្នុងចំណោមបណ្តារដ្ឋធ្វើសំណើ។

## មាត្រា ១៤
## ការប្រគល់ខ្លួន

១.ភាគីទទួលសំណើត្រូវជូនព័ត៌មានឲ្យភាគីផ្ញើសំណើ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន អំពីការសម្រេចរបស់ខ្លួនលើសំណើសុំធ្វើបត្យាប័ន។

២.ក្នុងករណីបត្យាប័នត្រូវបានផ្តល់ឲ្យ ភាគីទទួលសំណើត្រូវប្រគល់បុគ្គលដែលគេទាមទារ ចេញពីចំណុចចាកចេញពីក្នុងដែនដីដែលគូភាគីបានព្រមព្រៀងគ្នា។

៣.គូភាគីត្រូវពិគ្រោះយោបល់គ្នា ដើម្បីកំណត់កាលបរិច្ឆេទ និងទីកន្លែងនៃការបញ្ជូនខ្លួនបុគ្គលដែលត្រូវធ្វើបត្យាប័ន។ ភាគីទទួលសំណើត្រូវជូនព័ត៌មានទៅភាគីផ្ញើសំណើ អំពីថិរវេលានៃការឃុំខ្លួនបុគ្គលដែលត្រូវធ្វើបត្យាប័ននៅលើដែនដីរបស់ភាគីទទួលសំណើ ប្រសិនបើមានការឃុំខ្លួននៅក្នុងដែនដីនៃភាគីទទួលសំណើ។

៤.ភាគីផ្ញើសំណើត្រូវមកទទួលយកបុគ្គល ដែលស្នើសុំពីដែនដីនៃភាគីទទួលសំណើក្នុងរយៈពេលសមរម្យតាមការកំណត់របស់ភាគីទទួលសំណើ ហើយប្រសិនបើបុគ្គលដែលត្រូវធ្វើបត្យាប័ននោះ មិនត្រូវបានភាគីផ្ញើសំណើមកទទួលយកក្នុងពេលកំណត់នោះទេ ភាគីទទួលសំណើអាចបដិសេធការធ្វើបត្យាប័នបុគ្គលនោះ ចំពោះបទល្មើសដដែល។

៥.ប្រសិនបើមានហេតុការណ៍ណាមួយកើតឡើង ដែលហួសពីលទ្ធភាពគ្រប់គ្រងរបស់គូភាគី រារាំងដល់ការប្រគល់ ឬទទួលបុគ្គលដែលស្នើសុំធ្វើបត្យាប័ននោះ ភាគីត្រូវជូនព័ត៌មានទៅភាគីម្ខាងទៀត។ គូភាគីត្រូវពិភាក្សាគ្នា ដើម្បីកំណត់កាលបរិច្ឆេទថ្មីសម្រាប់ប្រគល់ខ្លួនបុគ្គលដែលស្នើសុំ ហើយបទប្បញ្ញត្តិក្នុងកថាខណ្ឌទី ៤ នៃមាត្រានេះ ត្រូវអនុវត្តផងដែរ។

## មាត្រា ១៥
## ការប្រគល់នូវទ្រព្យសម្បត្តិ

១.នៅក្នុងក្របខណ្ឌនៃច្បាប់របស់ភាគីទទួលសំណើដែលបានអនុញ្ញាត និងឈរលើមូលដ្ឋាននៃការគោរពសិទ្ធិរបស់តតិយជន គ្រប់ទ្រព្យសម្បត្តិដែលជាផលនៃបទល្មើស ឬដែលអាចធ្វើជាវត្ថុតាង ហើយដែលបានរកឃើញលើដែនដីនៃភាគីទទួលសំណើនឹងត្រូវ

បញ្ជូនតាមសំណើរបស់ភាគីធ្វើសំណើ ប្រសិនបើសំណើសុំធ្វើបត្យាប័នត្រូវបានផ្តល់ឲ្យ។

២.យោងតាមកថាខណ្ឌទី ១ នៃមាត្រានេះ ទ្រព្យសម្បត្តិនឹងត្រូវបញ្ជូនទៅភាគីធ្វើសំណើ ប្រសិនបើភាគីធ្វើសំណើបានស្នើសុំ ទោះបីជាការធ្វើបត្យាប័នមិនអាចអនុវត្តបានដោយមូលហេតុបុគ្គលដែលគេទាមទារបានទទួលមរណភាព បាត់ខ្លួន ឬរត់គេចខ្លួន។

៣.នៅពេលដែលច្បាប់នៃភាគីទទួលសំណើបញ្ញត្ត ឬដើម្បីសិទ្ធិរបស់តតិយជន ទ្រព្យសម្បត្តិទាំងអស់ដែលត្រូវបានបញ្ជូនត្រូវសងមកភាគីទទួលសំណើវិញ ដោយគ្មានការបង់ប្រាក់សោហ៊ុយ ប្រសិនបើភាគីទទួលសំណើបានស្នើសុំ។

៤.ក្នុងករណីទ្រព្យសម្បត្តិខាងលើ ជាទ្រព្យដែលត្រូវការចាំបាច់សម្រាប់បម្រើឲ្យការស៊ើបអង្កេត ឬចោទប្រកាន់ ឬជំនុំជម្រះបទល្មើសនៅលើដែនដីនៃភាគីទទួលសំណើ ការបញ្ជូនទ្រព្យសម្បត្តិនោះអាចពន្យារពេលរហូតដល់ការស៊ើបអង្កេត ការចោទប្រកាន់ ឬការជំនុំជម្រះត្រូវបានបញ្ចប់ ឬអាចបញ្ជូនដោយមានលក្ខខណ្ឌថានឹងត្រូវប្រគល់មកវិញបន្ទាប់ពីបញ្ចប់នីតិវិធីរបស់ភាគីធ្វើសំណើ។

## មាត្រា ១៦
## ការផ្អាកការប្រគល់ខ្លួន និងការប្រគល់ខ្លួនជាបណ្តោះអាសន្ន

១.ភាគីទទួលសំណើអាចផ្អាកការបញ្ជូនខ្លួនបុគ្គល ដែលគេស្នើសុំដើម្បីដំណើរការនីតិវិធីចំពោះបុគ្គលនោះ ឬដើម្បីឲ្យបុគ្គលនោះអនុវត្តទោសចំពោះបទល្មើសផ្សេងពីបទល្មើសដែលត្រូវបានស្នើសុំធ្វើបត្យាប័ន។ ក្នុងករណីនេះ ភាគីទទួលសំណើត្រូវជូនព័ត៌មានទៅភាគីធ្វើសំណើ។

២.នៅពេលបុគ្គលដែលគេទាមទារ កំពុងអនុវត្តទោសលើដែនដីនៃភាគីទទួលសំណើ ចំពោះបទល្មើសផ្សេងក្រៅពីបទល្មើសដែលត្រូវធ្វើបត្យាប័ន ភាគីទទួលសំណើអាចបញ្ជូនខ្លួនជាបណ្តោះអាសន្ននូវបុគ្គលនោះទៅភាគីធ្វើសំណើ ដើម្បីធ្វើការចោទប្រកាន់ និងជំនុំជម្រះចំពោះបទល្មើសដែលបានស្នើសុំធ្វើបត្យាប័ន។ បុគ្គលដែលត្រូវបញ្ជូនខ្លួនជាបណ្តោះអាសន្ន ត្រូវរក្សាទុកនៅលើដែនដីនៃភាគីធ្វើសំណើ និងត្រូវប្រគល់ត្រឡប់មកឲ្យភាគីទទួលសំណើវិញ បន្ទាប់ពីបានបញ្ចប់នីតិវិធីចំពោះបុគ្គលនោះតាមលក្ខខណ្ឌដែល

គូភាគីបានព្រមព្រៀងជាលាយលក្ខណ៍អក្សរ។

## មាត្រា ១៧
## វិធានពិសេស

១.អនុលោមតាមសន្ធិសញ្ញានេះ បុគ្គលដែលត្រូវធ្វើបត្យាប័នមិនត្រូវឃុំខ្លួន ចោទប្រកាន់ ជំនុំជម្រះ ឬអនុវត្តទោសនៅលើដែនដីនៃភាគីធ្វើសំណើ ចំពោះបទល្មើសដែលបានប្រព្រឹត្ត មុនការស្នើសុំធ្វើបត្យាប័ន លើកលែងតែក្នុងករណីៈ

ក.បទល្មើសនោះគឺជាបទល្មើសដែលបត្យាប័នត្រូវបានផ្តល់ឲ្យ

ខ.រាល់បទល្មើសដែលអាចធ្វើបត្យាប័នបង្ហាញនូវអង្គហេតុតែមួយហើយត្រូវផ្តន្ទាទោសដូចគ្នា ឬតិចជាងបទល្មើសដែលបត្យាប័នត្រូវបានផ្តល់ឲ្យ

គ.រាល់បទល្មើសដែលអាចធ្វើបត្យាប័នណា ដែលភាគីទទួលសំណើបានយល់ព្រម។ សំណើសុំការយល់ព្រម ត្រូវភ្ជាប់មកជាមួយនូវឯកសារដែលមានចែងនៅក្នុងមាត្រា ៨ នៃសន្ធិសញ្ញានេះ តាមសំណូមពររបស់ភាគីទទួលសំណើ ដោយភ្ជាប់មកជាមួយនូវឯកសារ ឬកំណត់ហេតុដែលធ្វើឡើងចំពោះបុគ្គលដែលគេទាមទារទាក់ទងនឹងបទល្មើសនោះ។

២.កថាខណ្ឌទី ១ នៃមាត្រានេះនឹងមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើៈ

ក.បុគ្គលដែលគេស្នើសុំមានលទ្ធភាពចាកចេញពីដែនដី នៃភាគីធ្វើសំណើ ប៉ុន្តែមិនបានចាកចេញក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតពីថ្ងៃដែលបុគ្គលនោះត្រូវបានលើកលែងពីការចោទប្រកាន់អំពីបទល្មើសដែលត្រូវបានស្នើសុំធ្វើបត្យាប័ន ឬ

ខ.បុគ្គលនោះបានត្រឡប់មកដែនដីនៃភាគីធ្វើសំណើវិញ ដោយស្ម័គ្រចិត្ត បន្ទាប់ពីខ្លួនបានចាកចេញរួចមក។

## មាត្រា ១៨
## ការធ្វើបត្យាប័នបន្តទៅរដ្ឋទីបី

ភាគីធ្វើសំណើមិនត្រូវធ្វើបត្យាប័នបុគ្គលដែលត្រូវធ្វើបត្យាប័ន បន្តទៅរដ្ឋទីបីបានឡើយ លើកលែងតែៈ



S

M/m

ក.ភាគីទទួលសំណើយល់ព្រមចំពោះការធ្វើបត្យាប័ននេះ។ សំណើសុំការយល់ព្រមនេះ ត្រូវភ្ជាប់មកជាមួយនូវឯកសារដែលមានចែងនៅក្នុងមាត្រា ៨ នៃសន្ធិសញ្ញានេះ ដូចដែលបានស្នើសុំដោយភាគីទទួលសំណើ ដោយភ្ជាប់មកជាមួយនូវឯកសារ ឬកំណត់ហេតុដែលធ្វើឡើងចំពោះបុគ្គលដែលគេស្នើសុំទាក់ទងនឹងបទល្មើសនោះ

ខ.បុគ្គលដែលគេស្នើសុំមានលទ្ធភាព ចាកចេញពីដែនដីនៃភាគីធ្វើសំណើ ប៉ុន្តែមិនបានចាកចេញក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតពីថ្ងៃដែលបុគ្គលនោះត្រូវបានលើកលែងពីការចោទប្រកាន់អំពីបទល្មើសដែលត្រូវបានស្នើសុំធ្វើបត្យាប័ន ឬ

គ.បុគ្គលនោះបានត្រឡប់មកដែនដីនៃភាគីធ្វើសំណើវិញ ដោយស្ម័គ្រចិត្ត បន្ទាប់ពីខ្លួនបានចាកចេញរួចមក។

## មាត្រា ១៩
## ការឆ្លងកាត់

១.អនុលោមតាមច្បាប់របស់ភាគី ការឆ្លងកាត់របស់បុគ្គលដែលត្រូវធ្វើបត្យាប័នដោយរដ្ឋទីបីទៅភាគីមួយតាមដែនដីនៃភាគីមួយទៀត ត្រូវបានអនុញ្ញាតតាមសំណើជាលាយលក្ខណ៍អក្សរតាមរយៈបណ្តាញការទូត ឬដោយផ្ទាល់រវាងអាជ្ញាធរកណ្តាលនៃគូភាគី ហើយការឆ្លងកាត់នេះត្រូវបានធ្វើឡើង បន្ទាប់ពីមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីភាគីដែលត្រូវបានឆ្លងកាត់។

២.ការអនុញ្ញាតសុំការឆ្លងកាត់នេះមិនតម្រូវឲ្យមានការស្នើសុំទេ ក្នុងករណីដែលមានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស ហើយគ្មានការសុំចុះចតលើដែនដីនៃភាគីដែលត្រូវឆ្លងកាត់។ ប្រសិនបើមានការចុះចតដោយមិនបានគ្រោងទុកនៅលើដែនដីនៃភាគីដែលត្រូវឆ្លងកាត់ ភាគីដែលត្រូវឆ្លងកាត់អាចតម្រូវឲ្យភាគីធ្វើសំណើស្នើសុំការឆ្លងកាត់តាមបញ្ញត្តិកថាខណ្ឌទី ១ នៃមាត្រានេះ។

៣.នៅពេលដែលទទួលបានសំណើសុំការអនុញ្ញាតឆ្លងកាត់ ភាគីទទួលសំណើត្រូវផ្តល់ការអនុញ្ញាតឲ្យឆ្លងកាត់ លើកលែងតែមានហេតុផលដែលជាមូលដ្ឋាននៃការបដិសេធសមស្រប។

៤.ការអនុញ្ញាតឲ្យឆ្លងកាត់នេះ ត្រូវយោងតាមច្បាប់នៃភាគីទទួលសំណើ ដោយរាប់បញ្ចូលទាំងការអនុញ្ញាតឲ្យឃុំខ្លួនបុគ្គលក្នុងអំឡុងពេលឆ្លងកាត់។

៥.ករណីដែលបុគ្គលត្រូវបានឃុំខ្លួន ដូចមានចែងនៅក្នុងកថាខណ្ឌទី ៤ នៃមាត្រានេះ ភាគីដែលបុគ្គលនេះត្រូវបានឃុំខ្លួនអាចចេញបញ្ជាឲ្យដោះលែងបុគ្គលនេះ ប្រសិនបើការដឹកជញ្ជូនមិនបានបន្តក្នុងពេលវេលាសមស្រប។

## មាត្រា ២០
## ការចំណាយ

១.រាល់ការចំណាយ ដែលកើតឡើងពីការធ្វើបត្យាប័ននៅលើដែនដីរបស់ភាគីទទួលសំណើ ជាបន្ទុករបស់ភាគីទទួលសំណើរហូតដល់ការប្រគល់ខ្លួនបុគ្គលដែលត្រូវធ្វើបត្យាប័ន។

២.រាល់ការចំណាយដែលកើតឡើងពីការឆ្លងកាត់នៅលើដែនដីរបស់ភាគីទទួលសំណើ ជាបន្ទុករបស់ភាគីធ្វើសំណើ។

៣.ភាគីធ្វើសំណើត្រូវទទួលខុសត្រូវរាល់ការចំណាយ ដែលកើតឡើងក្នុងការដឹកជញ្ជូនបុគ្គលដែលត្រូវធ្វើបត្យាប័នពីដែនដីរបស់ភាគីទទួលសំណើ ចាប់ពីពេលដែលមកទទួលយកបុគ្គលដែលត្រូវធ្វើបត្យាប័ន។

៤.គូភាគីត្រូវពិគ្រោះយោបល់គ្នាដើម្បីកំណត់អត្ថន័យ និងលក្ខខណ្ឌ ប្រសិនបើមានការចំណាយពិសេសណាមួយដែលតម្រូវឲ្យអនុវត្តសំណើសុំធ្វើបត្យាប័ន។

## មាត្រា ២១
## វិសោធនកម្ម និងការបំពេញបន្ថែម

សន្ធិសញ្ញានេះអាចធ្វើវិសោធនកម្ម ឬបំពេញបន្ថែមតាមការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់គូភាគី។

រាល់ការធ្វើវិសោធនកម្ម ឬការបំពេញបន្ថែមនឹងត្រូវក្លាយជាផ្នែកមួយនៃសន្ធិសញ្ញានេះ។

5

## មាត្រា ២២

## ការផ្តល់សច្ចាប័ន ការចូលជាធរមាន និងការបញ្ចប់អានុភាពនៃសន្ធិសញ្ញា

១.សន្ធិសញ្ញានេះ ត្រូវស្ថិតនៅជាកម្មវត្ថុនៃការសុំសច្ចាប័ន។ សន្ធិសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទី ៣០ (សាមសិប) គិតចាប់ពីថ្ងៃនៃការទទួលបាននូវលិខិតុបករណ៍ចុងក្រោយនៃការផ្តល់សច្ចាប័នតាមរយៈបណ្តាញការទូត។

២.ភាគីនីមួយៗ អាចបញ្ចប់សន្ធិសញ្ញានេះបាន តាមរយៈការជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតតាមរយៈបណ្តាញការទូត។ ការបញ្ចប់នឹងមានអានុភាពក្រោយ ៦ (ប្រាំមួយ) ខែ គិតពីថ្ងៃដែលភាគីម្ខាងទៀតទទួលបានការផ្តល់ព័ត៌មានស្តីពីការបញ្ចប់នេះ។ ការបញ្ចប់សន្ធិសញ្ញានេះ មិនត្រូវធ្វើឲ្យប៉ះពាល់ដល់នីតិវិធីនៃបត្យាប័ននានា ដែលផ្តើមអនុវត្តមុនការបញ្ចប់សន្ធិសញ្ញានេះ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ។

ធ្វើនៅរដ្ឋធានីហាណូយ ថ្ងៃទី ២៦.... ខែធ្នូ ឆ្នាំ ២០១៣ ធ្វើឡើងជា ២ (ពីរ) ច្បាប់ ដែលមួយច្បាប់មានភាសាខ្មែរ ភាសាវៀតណាម និងភាសាអង់គ្លេស ដែលអត្ថបទនីមួយៗមានតម្លៃស្មើៗគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នាអត្ថបទជាភាសាអង់គ្លេស ត្រូវយកប្រើប្រាស់ជាឯកសារគោល។

| **តំណាង** | **តំណាង** |
|---|---|
| **ព្រះរាជាណាចក្រកម្ពុជា** | **សាធារណរដ្ឋសង្គមនិយមវៀតណាម** |

# ឧបសម្ព័ន្ធទី៩



## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..១១..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី
## ការបង្គាប់ឱ្យធ្វើបត្យាប័ន

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញកំណត់ទូតលេខ ១-២/២០១០ ចុះថ្ងៃទី ២៩-៦ និង ០៦-៧-២០១០ របស់ស្ថានទូតស៊ុយអ៊ែតនៅទីក្រុងបាងកក

-បានឃើញសាលដីកាលេខ ៨៨ "ស" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្គាប់ឱ្យធ្វើបត្យាប័នចំពោះឈ្មោះ LITMANEN HANNU TAPANI ជនជាតិហ្វាំងឡង់ ភេទប្រុស អាយុ ៣១ឆ្នាំ កើតនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៩ ទីកន្លែងកំណើត ANGERED SWEDEN តាមការស្នើសុំរបស់ស្ថានទូតស៊ុយអែត ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច ✓
- ឯកសារ - កាលប្បវត្តិ